# ទស្សនាវដ្ដី កសិកម្ម




ឆ្នាំទី ១៤ ត្រីមាសទី ១ (មករា-មីនា) ឆ្នាំ ២០១៥ លេខ ៥៣

អាសយដ្ឋានលេខ:២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ២១១ ៣៥១/ទូរសារលេខ : (៨៥៥)២៣ ២១៧ ៣២០
គេហទំព័រ : http://www.maff.gov.kh
e-mail : info@maff.gov.kh

# មាតិកា ទំព័រ


- លិខិតឯកឧត្តមឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..........០១
- លិខិតឯកឧត្តមឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ផ្ញើជូនឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..........០៤
- សុន្ទរកថាឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យព្រៃឈើប្រចាំឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្ត..........០៥
- សុន្ទរកថាឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យកៅស៊ូឆ្នាំ២០១៤ និងលើកទិសដៅការងារបន្តឆ្នាំ២០១៥..........០៨
- សុន្ទរកថាឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី១០៤ ឆ្នាំ២០១៥ ក្រោមប្រធានបទ "ដំណើរឆ្ពោះទៅមុខ៖ ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោកឆ្នាំ១៩៩៥" ..........១០
- សុន្ទរកថាឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងពិធីបិទកិច្ចប្រជុំបូកសរុបការងារផលិតកម្មនិងបសុព្យាបាល ឆ្នាំ២០១៤ និងទិសដៅការងារផលិតកម្មនិងបសុព្យាបាល ឆ្នាំ២០១៥..........១៤
- បច្ចេកទេសដាំដំណាំម្ទេសប៉េលិន(តពីលេខ៥២)..........១៧
- បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ (តពីលេខ ៥២)..........២៥
- បច្ចេកទេសចិញ្ចឹមគោជាលក្ខណៈគ្រួសារ (តពីលេខ ៥២) ..........៣៨
- ច្បាប់ស្តីពីសហគមន៍កសិកម្ម (តពីលេខ ៥២) ..........៤៩
- សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..........៦១

ម.ក.ឯ.ក AIDOC
Code: 065-001
Date:
Donated by:

MAFF

Embassy of Japan

ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៤

សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ជាទីគោរពរាប់អានដ៏ខ្ពង់ខ្ពស់។

ទូលបង្គំជាខ្ញុំ-ខ្ញុំបាទ **គូម៉ាម៉ារ៉ូ យូជិ** ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា។

កាលពីពេលកន្លងទៅនេះ ទូលបង្គំជាខ្ញុំ-ខ្ញុំបាទបានទូលថ្វាយនិងជម្រាបជូនអំពីសកម្មភាពនៃការរួមចំណែករបស់រដ្ឋាភិបាលជប៉ុន ក្នុងដំណើរការស្តារឡើងវិញនិងអភិរក្សប្រាង្គប្រាសាទអង្គរនៅក្នុងប្រទេសកម្ពុជា ហើយទូលបង្គំជាខ្ញុំ-ខ្ញុំបាទពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដោយបានទទួលនូវសារលិខិតឆ្លើយតបពីសំណាក់ សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាជាច្រើន។ លើកនេះ ទូលបង្គំជាខ្ញុំ-ខ្ញុំបាទសូមក្រាបបង្គំទូលថ្វាយនិងជម្រាបជូនអំពីជំនួយរបស់រដ្ឋាភិបាលជប៉ុននៅក្នុងសកម្មភាពបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅក្នុងទឹកដីប្រទេសកម្ពុជាដែលសកម្មភាពទាំងនេះពុំសូវត្រូវបានគេដឹងនិងជ្រាបនោះទេ។

ចាប់តាំងពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១មកទល់នឹងបច្ចុប្បន្ននេះ ប្រទេសជប៉ុនបាននិងកំពុងផ្តល់ជំនួយសំរាប់ការស្តារឡើងវិញនិងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ហើយបើគិតទៅលើទំហំទឹកប្រាក់សរុបនៃជំនួយអភិវឌ្ឍន៍ផ្លូវការវិញនោះ ប្រទេសជប៉ុនគឺជាប្រទេសដែលផ្តល់ជំនួយទ្វេភាគីធំជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា។ ជំនួយរបស់រដ្ឋាភិបាលជប៉ុនមកកាន់ប្រទេសកម្ពុជាផ្តោតទៅលើវិស័យសំខាន់ៗជាច្រើនរួមមាន ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ការបណ្តុះបណ្តាលធនធានមនុស្ស ការជម្រុញលទ្ធិប្រជាធិបតេយ្យ និងការថែរក្សាសុខុមាលភាពមាតានិងទារកជាដើម ដោយឡែករដ្ឋាភិបាលជប៉ុនក៏បានយកចិត្តទុកដាក់ផងដែរ ក្នុងការផ្តល់ជំនួយយ៉ាងសកម្មសំរាប់សកម្មភាពបោសសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅក្នុងប្រទេសកម្ពុជា។

បើនិយាយពីបញ្ហាប្រឈមពាក់ព័ន្ធនឹងគ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះវិញ សកម្មភាពនៃការបោសសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនេះផ្ទាល់គឺពិតជាមានភាពចាំបាច់ខ្លាំងណាស់ ក៏ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺថា បើទោះបីជាមានដីដែលមានស្ថានភាពល្អប្រសើរឡើងនិងត្រូវបានបោសសម្អាតរួចក្នុងកំរិតណាក៏ដោយ ប៉ុន្តែប្រសិនបើប្រជាជនដែលរស់នៅក្នុងតំបន់នោះមិនបានធ្វើសកម្មភាពប្រើប្រាស់ដីធ្លីទាំងនោះទេ នោះជីវភាពរស់នៅរបស់ពួកគាត់ក៏មិនអាចវិវត្តន៍ទៅរកភាពរីកចំរើនល្អប្រសើរបាន

No.194, Moha Vithei Preah Norodom, Phnom Penh, Cambodia (P.O.BOX21, Phnom Penh)
Tel: 855 (23) 217 161~4, Fax: 855 (23) 216 162

ដែរ។ ដូចនេះទូលបង្គំជាខ្ញុំ-ខ្ញុំបាទគិតថាសកម្មភាពផ្តល់ជំនួយដោយភ្ជាប់ជាមួយនិងទស្សនៈវិស័យក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ និយាយជារួមគឺជាការអភិវឌ្ឍន៍សង្គមក្នុងរយៈពេលវែងគឺជាភាពចាំបាច់ដែលគួរតែពិចារណាផងដែរ។

ប្រទេសជប៉ុនបានផ្តល់ជំនួយមកកាន់ប្រទេសកម្ពុជា សំរាប់វិស័យបោសសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចាប់តាំងពីឆ្នាំ១៩៩៨ ហើយជំនួយនេះមានច្រើនយ៉ាងរួមទាំងជំនួយសំរាប់គម្រោងទ្រង់ទ្រាយតូច ការប្រគល់ជូននូវម៉ាស៊ីនគ្រឿងចក្រប្រើប្រាស់ក្នុងសកម្មភាពបោសសម្អាតគ្រាប់មីន ក៏ដូចជាការបញ្ជូនអ្នកជំនាញនិងទីប្រឹក្សាជនជាតិជប៉ុន ដើម្បីមកបណ្តុះបណ្តាលអ្នកជំនាញជនជាតិ កម្ពុជានៅក្នុងមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា (CMAC)ជាដើម។ជំនួយទាំងនេះមានទឹកប្រាក់សរុបកើនឡើងដល់ប្រមាណ ១៥៨០កោដិយ៉េនជប៉ុន។ ជាងនេះទៅទៀត ចាប់តាំងពីឆ្នាំ២០១៣មក ប្រទេសជប៉ុនក៏បាននិងកំពុងផ្តល់ជំនួយអភិវឌ្ឍន៍ក្នុងវិស័យកសិកម្មទៅដល់តំបន់ដែលធ្លាប់រងគ្រោះដោយការគំរាមកំហែងពីគ្រាប់មីនផងដែរ។

មួយវិញទៀត អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលត្រូវបានគេស្គាល់ថាជា អង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS) មិនត្រឹមតែបានធ្វើកិច្ចសហប្រតិបត្តិការជាមួយបុគ្គលិកនិងមន្ត្រីនៃមជ្ឈមណ្ឌលកំចាត់មីនកម្ពុជាលើសកម្មភាពបោសសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសាងសង់ផ្លូវថ្នល់រវាងតំបន់ដែលធ្លាប់តែរងគ្រោះដោយគ្រាប់មីននិងទីប្រជុំជនមួយដើម្បីឱ្យប្រជាជនក្នុងតំបន់នោះមានលទ្ធភាពប្រកបការងារកសិកម្មនិងដូញដូរផលិតផលរបស់ពួកគេបានដោយរលូន និងការសាងសង់សាលាបឋមសិក្សានៅក្នុងសហគមន៍ជាដើម។ ក្រុមហ៊ុនជប៉ុនមិនត្រឹមតែបានជួយឧបត្ថម្ភជាម៉ាស៊ីនគ្រឿងចក្របោសសម្អាតមីនប៉ុណ្ណោះទេ ពួកគេក៏បានរួមចំណែកដល់ការសាងសង់សាលាបឋមសិក្សានៅក្នុងតំបន់ ដែលធ្លាប់រងគ្រោះដោយការគំរាមកំហែងពីគ្រាប់មីនផងដែរ។

លើសពីនេះទៅទៀត ប្រទេសជប៉ុនក៏បាននិងកំពុងជួយដល់ប្រទេសកម្ពុជានៅក្នុងក្របខ័ណ្ឌនៃសហគមន៍អាស៊ានផងដែរ។ កាលពីថ្ងៃទី២ដល់ទី៣ខែវិច្ឆិកាឆ្នាំ២០១៤កន្លងទៅនេះ សិក្ខាសាលាស្តីអំពីការឈានទៅបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនតំបន់អាស៊ាន (ARMAC) ត្រូវបានធ្វើឡើងនៅក្រុងសៀមរាប ហើយប្រទេសជប៉ុនបានផ្គត់ផ្គង់ថវិកាចំណាយសំរាប់ការរៀបចំសិក្ខាសាលានេះដោយប្រើប្រាស់មូលនិធិសមាហរណកម្មជប៉ុន-អាស៊ាន (JAIF) ។ ប្រទេសជប៉ុនស្វាគមន៍ចំពោះការរួមចំណែករបស់ប្រទេសកម្ពុជាក្នុងដំណើរការរក្សាឱ្យបាននូវស្ថិរភាពនិងសន្តិភាពក្នុងតំបន់អាស៊ាន តាមរយៈការប្រើប្រាស់បទពិសោធន៍និងបច្ចេកវិទ្យាលអំពីសកម្មភាពបោសសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលប្រទេសកម្ពុជាផ្ទាល់ធ្លាប់បានឆ្លងកាត់។

ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាក៏បាននិងកំពុងបញ្ជូនកងកំលាំងទៅចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ (PKO) ក្នុងវិស័យបោសសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនេះផងដែរ។ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវសកម្មភាពទាំងអស់នេះរបស់ប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ២០១២មក

ក្រសួងការពារជាតិនិងកងកំលាំងស្វ័យការពារជប៉ុន បានបញ្ជូនទាហានកងកំលាំងស្វ័យការពារជប៉ុនមកកាន់មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកំលាំងរក្សាសន្តិភាព បោសសម្អាតមីន និង កាកសំណល់សង្គ្រាម (NPMEC) ដើម្បីផ្ទេរបច្ចេកទេសនិងបណ្តុះបណ្តាលដល់ក្រុមអ្នកជំនាញបង្វឹកបង្ហាត់កម្ពុជាដើម្បីបណ្តុះបណ្តាលប្រជាជនកម្ពុជាបន្តនៅក្នុងសកម្មភាពប្រតិបត្តិការរក្សាសន្តិភាពរបស់ PKO។ ប្រទេសកម្ពុជា ជាប្រទេសទីមួយដែលប្រទេសជប៉ុនសំរេចចិត្តបញ្ជូនកង កំលាំងស្វ័យការពាររបស់ខ្លួនមកចូលរួមក្នុងសកម្មភាព PKO ឥឡូវនេះកម្ពុជាបានក្លាយជាប្រទេសដែលបញ្ជូនកងកំលាំងដើម្បីទៅចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាព PKO ដោយរួមមានការធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយប្រទេសជប៉ុនក្នុងកិច្ចការងាររួមចំណែកដល់ការរក្សាសន្តិភាពសង្គមអន្តរជាតិ និងការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខមនុស្សជាតិនោះគឺជាសកម្មភាពមួយដ៏មានអត្ថន័យជ្រាលជ្រៅនិងគួរឱ្យស្ញប់ស្ញែង។

ចម្ការមីនមានទីតាំងនៅតំបន់ដែលមានចម្ងាយឆ្ងាយពីទីក្រុងសំខាន់ៗ។ ទូលបង្គំជាខ្ញុំ-ខ្ញុំបាទសូមសម្តែងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ ចំពោះប្រជាជនជប៉ុននិងប្រជាជនកម្ពុជាដែលបានរួមចំណែកក្នុងប្រតិបត្តិការបោសសម្អាតមីន ជាប្រតិបត្តិការដែលអាចប៉ះពាល់យ៉ាងខ្លាំងដល់សុវត្ថិភាពអាយុជីវិតរបស់ពួកគេផ្ទាល់ដើម្បីបុព្វហេតុការអភិវឌ្ឍប្រទេសជាតិនិងការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលជប៉ុនប្រកាន់នូវជំហរដ៏រឹងមាំមួយក្នុងការបន្តផ្តល់ជំនួយក្នុងវិស័យបោសសម្អាតមីននេះដោយហេតុថា រដ្ឋាភិបាលជប៉ុនចង់ឃើញប្រជាជនកម្ពុជានិងប្រជាជនដែលរស់នៅតាមបណ្តាប្រទេសមួយចំនួនផ្សេងទៀតនៅលើពិភពលោក បានរួចផុតពីភាពភ័យខ្លាចនៃមហន្តរាយដែលបណ្តាលមកពីគ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន។

ជាចុងក្រោយនេះ ទូលបង្គំជាខ្ញុំ-ខ្ញុំបាទ សូមអនុញ្ញាតថ្វាយនិងជូននូវសព្ទសាធុការពរបវរមហាប្រសើរសូម សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ប្រកបដោយសុភមង្គលយ៉ាងបរិបូរណ៍នាឱកាសឆ្នាំថ្មីឆ្នាំ២០១៥ខាងមុខនេះ។

**គូម៉ាម៉ារូ យូជិ**
**ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

H.E. Mr. Ouk Rabun
Minister of Agriculture, Forestry and Fisheries
Royal Government of Cambodia
Phnom Penh

Phnom Penh, 18 December 2014

Your Excellency,

As the New Year of 2015 is approaching, I have the great honour to extend to Your Excellency my season's greetings and best wishes.

In the past year, we have further developed the traditional friendship and the Comprehensive Strategic Partnership of Cooperation between China and Cambodia. I highly appreciate all the efforts that have been made by the Cambodian side, especially the unremitting efforts and strong support from Your Excellency and the competent authorities.

On this special occasion, I have the great honour to present Your Excellency a book *The Governance of China*, by H.E. Mr. XI Jinping, President of the People's Republic of China, as the New Year gift. I sincerely hope that the book will be helpful for Your Excellency to know better about China and its governance under the new leadership of President XI Jinping.

Again, I wish Your Excellency a happy and prosperous New Year!

Bu Jianguo
Ambassador Extraordinary and Plenipotentiary
People's Republic of China to the Kingdom of Cambodia

# សុន្ទរកថា

## ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យព្រៃឈើប្រចាំឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្ត

នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិស័យព្រៃឈើ-សត្វព្រៃភ្នំពេញថ្មី

ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥







*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យព្រៃឈើប្រចាំឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្ត*

- **សូមគោរពគណៈអធិបតី** !

- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងសមាជិក សមាជិកា នៃអង្គពិធីទាំងមូល ជាទីមេត្រី**!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយបានមកចូលរួម ជាអធិបតីក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យព្រៃឈើប្រចាំឆ្នាំ២០១៤និងទិសដៅអនុវត្តបន្ត ហើយក៏ជាឱកាសដែលបានជួបជាមួយឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់ទាំងអស់។

ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម លោកលោកស្រី នាងកញ្ញា ជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ គ្រប់ផ្នែកនៃរដ្ឋបាលព្រៃឈើដែលបានយកអស់ស្មារតីនិងកម្លាំងកាយចិត្តក្នុងការបំពេញភារកិច្ចរបស់ខ្លួនទទួលបានជោគជ័យរយៈពេល១ឆ្នាំកន្លងមកនេះ ទោះបីក្នុងរយៈពេលមួយឆ្នាំនេះជួបបញ្ហាលំបាកយ៉ាងណាក្តី ក៏ថ្នាក់ដឹកនាំនិងសមត្ថកិច្ចជំនាញរដ្ឋបាលព្រៃឈើដែលឈរជើងនៅតាមមូលដ្ឋានបានចុះស្រាវជ្រាវ ទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើគ្រប់ប្រភេទជាបន្តបន្ទាប់យ៉ាងសកម្មនិងទាន់ពេលវេលា ហើយត្រូវខិតខំអនុវត្តការងារនេះបន្តទៀតជាប្រចាំនិងដូចភ្លៀងរលឹម។

គោលនយោបាយសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់វិស័យព្រៃឈើជាតិ គឺការអភិវឌ្ឍនិងការគ្រប់គ្រងធនធានព្រៃឈើ ដោយធានាស្ថេរភាពនៃអេកូឡូស៊ី សង្គមនិងសេដ្ឋកិច្ចដែលជាសរសរគ្រឹះសំខាន់សម្រាប់ សុខុមាលភាពសាធារណៈ និងជាវិភាគទានដោយផ្ទាល់ចំពោះការការពារបរិស្ថាន ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព សម្រាប់ជំនាន់បច្ចុប្បន្ន និងទៅអនាគត ។ ជាក់ស្តែងរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់បង្កើតតំបន់ព្រៃការពារ តំបន់អភិរក្ស ធនធានសេនេទិក (Genetic) និងជីវចម្រុះជាច្រើនកន្លែងរួចមកហើយ។ ទន្ទឹមនោះ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ជំរុញការដាំដុះព្រៃឈើដើម្បីបង្កើនគម្របព្រៃឡើងវិញ និងជំរុញបង្កើត និងអភិវឌ្ឍន៍សហគមន៍ព្រៃឈើ កំណត់ព្រំប្រទល់ដែនព្រៃឈើ ការចាត់វិធានការចុះស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបល្មើស

ព្រៃឈើសត្វព្រៃគ្រប់ប្រភេទ ការទប់ស្កាត់ ការកាប់រុករានដីព្រៃឈើដើម្បីយកធ្វើកម្មសិទ្ធិ និងជំរុញដល់ការពង្រឹងសមត្ថភាពធនធានមនុស្សផងដែរ។

បន្ទាប់ពីបានស្តាប់ របាយការណ៍ បូកសរុបលទ្ធផលកិច្ចប្រជុំការងារវិស័យព្រៃឈើប្រចាំឆ្នាំ២០១៤ និងទិសដៅអនុវត្តការងារបន្តរបស់ឯកឧត្តមបណ្ឌិត **ឆេង គឹមស៊ុន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ ឃើញថា រដ្ឋបាលព្រៃឈើបានសម្រេចលទ្ធផលជាច្រើនគួរឱ្យកោតសរសើរតាមរយៈការអនុវត្តនូវកម្មវិធីព្រៃឈើជាតិ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៤កន្លងមកនេះ រដ្ឋបាលព្រៃឈើបានបោះបង្គោលព្រំដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍តាមផែនការកំណត់រួច ហើយសហគមន៍ព្រៃឈើជាង៤០កន្លែងបានស្នើសុំបង្កើតឡើង និងជាង២០សហគមន៍ត្រូវបានចុះកិច្ចព្រមព្រៀងរួច។

ការគ្រប់គ្រងការពារ អភិរក្ស និងអភិវឌ្ឍវិស័យព្រៃឈើ គឺជាការងារមួយដែលថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលព្រៃឈើទាំងអស់ត្រូវតែអនុវត្តជាប់ជាប្រចាំ។ ខ្ញុំសូមឯកភាពលើទិសដៅការងារសំខាន់ៗសម្រាប់ឆ្នាំ២០១៥ ដែលបានលើកឡើងនៅក្នុងរបាយការណ៍បូកសរុបកិច្ចប្រជុំ។ ទន្ទឹមនេះ ខ្ញុំសូមផ្តល់ជាអនុសាសន៍ បន្ថែមលើចំណុចមួយចំនួន ដូចតទៅៈ

១-ត្រូវបន្តរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុងនៅក្នុងអង្គភាពក៏ដូចជានៅតាមមូលដ្ឋាននានា។ ក្នុងន័យនេះត្រូវចងចាំថាកត្តាជ័យជំនះ និងលទ្ធផលដែលទទួលបានគឺ ចេញពីកត្តាសាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់យើងទាំងអស់គ្នា។

២-ត្រូវបន្តកិច្ចសហការល្អ ជាមួយអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ ព្រះរាជអាជ្ញា តុលាការគ្រប់ថ្នាក់ និងអង្គភាពពាក់ព័ន្ធ ដើម្បីឱ្យដំណើរការអនុវត្តការងារវិស័យព្រៃឈើទទួលបានលទ្ធផលល្អ និងមានប្រសិទ្ធភាព

៣-បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទបញ្ញត្តិ និងលិខិតបទបញ្ជានានា ដែលពាក់ព័ន្ធ ឱ្យបានកាន់តែស៊ីជម្រៅទៅដល់មូលដ្ឋានភូមិឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង ខេត្ត រាជធានីទូទាំងប្រទេស និងអប់រំសាធារណជនទូទៅ សិស្សនិស្សិតឱ្យចេះស្រឡាញ់ព្រៃឈើ និងថែរក្សាព្រៃឈើជាតិ

៤-បន្តប្រើប្រាស់កម្លាំងសរុប ដើម្បីចុះស្រាវជ្រាវ រុករក និងបង្ក្រាបបទល្មើសព្រៃឈើ និងការកាប់រានឈូសឆាយព្រៃឈើ យកដីធ្វើកម្មសិទ្ធិតាមគ្រប់រូបភាព ទាំងរដ្ឋបាលព្រៃឈើនៅថ្នាក់កណ្តាលក៏ដូចរដ្ឋបាលព្រៃឈើនៅថ្នាក់មូលដ្ឋាន





*ទិដ្ឋភាពភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យព្រៃឈើប្រចាំឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្ត*

៥-បង្កើនការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ ជំរុញការដាំឈើឱ្យបានយ៉ាងតិច២៥.០០០ហិកតាក្នុង១ឆ្នាំ

៦-បង្កើតព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃឱ្យបាន៥០.០០០ហិកតាក្នុង១ឆ្នាំ

**៧-ត្រូវបង្កើតសហគមន៍ព្រៃឈើ ឱ្យបាន២៥ សហគមន៍ក្នុង១ឆ្នាំ យ៉ាងតិច**

៨-បន្តអនុវត្ត កម្មវិធីព្រៃឈើជាតិ ឱ្យសម្រេចបានលទ្ធផលល្អ និងប្រសិទ្ធភាពខ្ពស់ ដើម្បីថែរក្សា ការពារ អភិរក្ស និងអភិវឌ្ឍន៍ព្រៃឈើឱ្យបានគង់វង្សសម្រាប់មនុស្សជាតិជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយៗទៀត

៩-សមត្ថកិច្ចរដ្ឋបាលព្រៃឈើមូលដ្ឋានត្រូវចូលរួមជាមួយអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដើម្បី





*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យព្រៃឈើប្រចាំឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្ត*

ទប់ស្កាត់ប្រជាពលរដ្ឋដែលលួចកាប់ឈើគ្រញូងខុសច្បាប់នៅក្នុងទឹកដីថៃ

១០-បន្តផ្សព្វផ្សាយ បង្ការ និងទប់ស្កាត់ភ្លើងឆេះព្រៃដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយមានការចូលរួមពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ប្រជាពលរដ្ឋ សិស្សានុសិស្ស ដើម្បីទប់ស្កាត់ និងការពារភ្លើងឆេះព្រៃ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា សមាជិក សមាជិកា នៃអង្គពិធីទាំងមូល ជាទីមេត្រី** !

ជាការពិតណាស់ ការរីកចម្រើននៃវិស័យព្រៃឈើក៏ជួយជំរុញឱ្យមានការវិវត្ត ដល់វិស័យកសិកម្មដែលជាកម្លាំងចលករដ៏មានឥទ្ធិពលខ្លាំងក្លាទៅលើស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជាដែរ។ម៉្យាងទៀតវិស័យព្រៃឈើនៅតែមាន



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញទស្សនាពិព័រណ៍ក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យព្រៃឈើប្រចាំឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្ត*

តួនាទីជាវិស័យដ៏មានអាទិភាពមួយយ៉ាងសំខាន់ក្នុងការចូលរួមចំណែក ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបរិស្ថានធម្មជាតិ ពោលគឺជាប្រភពផ្តល់នូវការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុង និងក្បែរតំបន់ព្រៃឈើ ព្រមទាំងផ្តល់នូវសុខុមាលភាពដល់ប្រជាពលរដ្ឋទូទៅផងដែរ។ ក្នុងន័យនេះ ខ្ញុំសូមឯកភាពទាំងស្រុង ចំពោះវិធានការ និងទិសដៅអនុវត្តបន្តរបស់រដ្ឋបាលព្រៃឈើដែលបានលើកឡើងនេះ ក្នុងគោលបំណងដើម្បីពង្រឹង និងពន្លឿនការអនុវត្តការងារ ឱ្យកាន់តែប្រសើរឡើង និងមានប្រសិទ្ធភាពខ្ពស់។

ខ្ញុំសូមថ្លែងអំណរគុណ ដ៏ជ្រាលជ្រៅចំពោះ ឯកឧត្តម លោក លោកស្រី នាងកញ្ញា និងមន្ត្រីរាជការទាំងអស់នៃរដ្ឋបាលព្រៃឈើ ដែលបានចូលរួមក្នុងកិច្ចប្រជុំ រយៈពេល២ថ្ងៃនេះរហូតដល់ទទួលបានជោគជ័យដ៏ត្រចះត្រចង់នៅពេលនេះ និងសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ដែលមានវត្តមាន នៅទីនេះ សូមទទួលបានជោគជ័យនៅក្នុងភារកិច្ចថ្មីៗបន្តទៀត និងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យព្រៃឈើឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្តចាប់ពីពេលនេះតទៅ។

**សូមអរគុណ** !

# សន្ទរកថា
## ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យកៅស៊ូឆ្នាំ២០១៤ និងលើកទិសដៅការងារបន្តឆ្នាំ២០១៥ នៅអគ្គនាយកដ្ឋានកៅស៊ូ

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥



ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យកៅស៊ូឆ្នាំ២០១៤ និងលើកទិសដៅការងារបន្តឆ្នាំ២០១៥

**សូមគោរព៖**

- គណៈអធិបតី
- ឯកឧត្តម លោក លោកស្រី សមាជិកសមាជិកានៃអង្គប្រជុំជាទីមេត្រី

ទី១- ថ្ងៃនេះ យើងទាំងអស់គ្នាបានមកចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារផ្នែកកៅស៊ូឆ្នាំ២០១៤ និងលើកទិសដៅការងារបន្តឆ្នាំ២០១៥ ស្របពេលជាមួយនឹងលោក **ម៉ុល សុផា** ដែលទើបត្រូវបានតែងតាំងជាអគ្គនាយករងទទួលបន្ទុករួមនៃអគ្គនាយកដ្ឋានកៅស៊ូ បន្ទាប់ពីឯកឧត្តម **លី ផល្លា** ត្រូវទទួលភារកិច្ចជាអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាពេលថ្មីៗនេះ។

ទី២- តើវិស័យកៅស៊ូមានសក្តានុពលយ៉ាងណាខ្លះក្នុងបរិបទនៃសាកលភាវូបនីយកម្ម ពិសេសក្នុងស្ថានភាពបច្ចុប្បន្ន នៅកម្ពុជា?

ខ្ញុំសូមអនុញ្ញាត រំលឹកអង្គប្រជុំទាំងមូលមេត្តាជ្រាបថា ដំណាំកៅស៊ូត្រូវបានប្រសិទ្ធភាពថាជា "មាស ស" ឬជាដំណាំឧស្សាហកម្មមួយដ៏មានសារៈសំខាន់ ចាប់តាំងពីសតវត្សរ៍ទី១៩មកម្លេះ ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងការស្តារនិងអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ឆ្លងកាត់ការវិវត្តរីកចម្រើនតាមដំណាក់កាលជាបន្តបន្ទាប់ក្នុងរយៈពេលជាងមួយសតវត្សរ៍កន្លងមកនេះ ដំណាំកៅស៊ូ បានផ្តល់នូវផលប្រយោជន៍ ដ៏សំខាន់បន្ទាប់ពីដំណាំស្រូវរួមមាន៖ (១) ផ្តល់ប្រាក់ចំណូលដល់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារកសិករ តាមរយៈនីហរណកម្មកៅស៊ូឬផលិតផលសម្រេចដែលផលិតពីកៅស៊ូ ដោយសារមុខទំនិញនេះមានតម្លៃខ្ពស់ និងមានតម្រូវការជាចាំបាច់នៅលើទីផ្សារអន្តរជាតិ (២) បង្កើតការងារនិងមុខរបរមានស្ថេរភាពជូនប្រជាពលរដ្ឋនៅតាមជនបទ រួមចំណែកជួយកាត់បន្ថយការធ្វើចំណាកស្រុក (៣) ផ្តល់ឈើសម្រាប់ប្រើប្រាស់ជាគ្រឿងសំណង់ គ្រឿងសង្ហារឹម និងជាឈើប្រើប្រាស់ដើម្បីជួយកាត់បន្ថយដល់ការកាប់បំផ្លាញព្រៃធម្មជាតិ (៤) ការពារការហូរច្រោះដី និងបង្កើតជាគម្របបៃតងឡើងវិញ ដែលបំពេញតួនាទីជានិយតករធម្មជាតិ ចូលរួមចំណែកយ៉ាងសកម្មក្នុងការជួយការពារបរិស្ថានទប់ទល់នឹងការឡើងកម្តៅផែនដីតាមរយៈការស្រូបយកឧស្ម័នកាបូនិចពីបរិយាកាស។

ទី៣. ដើម្បីឱ្យចម្ការកៅស៊ូឈានទៅរកវិបុលកម្មទំនើប និងក៏ជាឱកាសរបស់កម្ពុជាកំពុងតែមានក្នុងការអភិវឌ្ឍផ្នែកកៅស៊ូចាំបាច់ គឺត្រូវសម្រិតសម្រាំងពូជកៅស៊ូ ឱ្យមានគុណភាពល្អ



ទិដ្ឋភាពភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យកៅស៊ូឆ្នាំ២០១៤ និងលើកទិសដៅការងារបន្តឆ្នាំ២០១៥



ពិធីបំពាក់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីរាជការ
មានស្នាដៃក្នុងការបំពេញការងារ

ទាំងជំរ និងឈើកៅស៊ូ ដែលការងារនេះ អគ្គនាយកដ្ឋានកៅស៊ូបានចាប់ផ្ដើមអនុវត្តគម្រោងធម្មនិយាមកម្មច្បារពូជនៅទូទាំងប្រទេស ដែលមានស្រាប់ និងដែលត្រូវបង្កើតថ្មីក្នុងក្របខណ្ឌគម្រោង AFD ដើម្បីឱ្យសមស្របតាម បទដ្ឋានបច្ចេកទេស ដោយហេតុថា ពូជកៅស៊ូនៅច្បារនីមួយៗមានលក្ខណៈច្របូកច្របល់ (ពូជលាយឡំគ្នា) ដែលធ្វើឱ្យមានការលំបាកក្នុងការយកទៅដាំ ថែទាំ ប្រមូលផល និងកែច្នៃ ។ ចំណុចនេះ អគ្គនាយកដ្ឋានកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាត្រូវណែនាំ និងសហការជាមួយក្រុមហ៊ុនដែលទទួលដីសម្បទានសេដ្ឋកិច្ច ឱ្យធ្វើការនាំចូលពូជកៅស៊ូ ដែលមានទិន្នផលខ្ពស់ និងហ៊ានទាត់ចោលនូវពូជដែលមានទិន្នផលទាប ដោយប្រើប្រាស់ក្លូនកៅស៊ូដែលបានណែនាំតាមវិធានបច្ចេកទេសសមស្រប។ ម្យ៉ាងទៀត កម្ពុជាបានក្លាយជាសមាជិករបស់អង្គការកៅស៊ូអន្តរជាតិដូចជាសមាគមប្រទេសផលិតកៅស៊ូធម្មជាតិ និងក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ ក្នុងការផ្លាស់ប្ដូរបទពិសោធន៍ ការអប់រំ បណ្ដុះបណ្ដាល ការផ្ទេរបច្ចេកវិទ្យា ការសិក្សាអំពីទីផ្សារ និងតម្លៃកៅស៊ូ...។ល។ ដូច្នេះ ត្រូវខិតខំបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសជាសមាជិកលើវិស័យកៅស៊ូចាប់តាំងពីការដាំដុះរហូតដល់ការកែច្នៃផលិតផល ។

ទី៤. អគ្គនាយកដ្ឋានកៅស៊ូត្រូវយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍកៅស៊ូគ្រួសារ នៅតាមបណ្ដាខេត្ត ដោយត្រូវពង្រឹកមន្ត្រីជំនាញបន្ថែមដើម្បីចុះឱ្យដល់មូលដ្ឋានខេត្ត ស្រុកដែលមានសក្ដានុពលដំណាំកៅស៊ូដើម្បីធ្វើការផ្សព្វផ្សាយ ណែនាំ និងបណ្ដុះបណ្ដាលអំពីការដាំដុះ ការថែទាំ ការប្រមូលផល និងការកែច្នៃដល់ប្រជាពលរដ្ឋដែលមានដីអាចដាំដុះកៅស៊ូបាន ជាពិសេសប្រជាពលរដ្ឋ ដែលទើបនឹងទទួលបាន ដីកម្មសិទ្ធិពីរាជរដ្ឋាភិបាល តាមរយៈ “**គោលនយោបាយចាស់-សកម្មភាពថ្មី**” ។ ជាមួយគ្នានេះ ត្រូវគិតគូររៀបចំបង្កើតសមាគមកសិករដាំកៅស៊ូដើម្បី(១) ការពារផលប្រយោជន៍របស់កសិករដាំកៅស៊ូ (២) លើកកម្ពស់អំណាចទីផ្សាររបស់កសិករ តាមរយៈការធ្វើទីផ្សារកៅស៊ូរួមគ្នា (៣)ជំរុញកំណើនសហគ្រាសកសិកម្មធុនតូច និងមធ្យមនៅជនបទដោយត្រូវគិតគូរអំពីការធ្វើកសិកម្មតាមកិច្ចសន្យា (៤) បង្កើនប្រាក់ចំណូល បង្កើតការងារ កាត់បន្ថយភាពក្រីក្រ និងទប់ស្កាត់ការធ្វើចំណាកស្រុក។

**ទី៥.** - តាមមាត្រា ៣៣ នៃច្បាប់ សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី៥ អំពីវិន័យអ្នករាជការរាល់រូបត្រូវតែគោរព អនុវត្តច្បាប់ និងបទបញ្ជា ហើយនិងការណែនាំពីថ្នាក់លើរបស់ខ្លួន។ បានសេចក្ដីថា អ្វីដែលជាភារកិច្ច របស់មន្ត្រីរាជការ មានចែងយ៉ាងច្បាស់លាស់នៅក្នុងច្បាប់បទបញ្ជា និងការណែនាំរបស់ថ្នាក់លើ។ កាតព្វកិច្ចនេះ តម្រូវឱ្យមន្ត្រីរាជការត្រូវធ្វើដោយខានមិនបាន។ ក៏ប៉ុន្តែនៅមានកាតព្វកិច្ចមួយចំនួនទៀត ដែលមិនមានចែងនៅក្នុងច្បាប់ បទបញ្ជា និងការណែនាំរបស់ថ្នាក់លើ តែជាកាតព្វកិច្ចផ្នែកសីលធម៌តម្រូវឱ្យមានមនសិការវិជ្ជាជីវៈ ឬ មនសិការស្នេហាជាតិមាតុភូមិ របស់អ្នករាជការទូទៅ។ ស្មារតីសាមគ្គីភាព ឯកភាពផ្ទៃក្នុង ភាពអត់ធ្មត់ យោគយល់គ្នា ជួយគ្នាទៅវិញទៅមកជាកត្តាជ័យជម្នះនៃការងារ។

- ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះស្នាដៃទាំងឡាយដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានជាវិជ្ជមានក្នុងឆ្នាំកន្លងមក និងសូមជូនពរជ័យសព្ទសាធុការដល់អង្គពិធីទាំងមូល និងបិទកិច្ចប្រជុំ។

***សូមអរគុណ!***

# សន្ទរកថា
# ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យកៅស៊ូឆ្នាំ២០១៤ និងលើកទិសដៅការងារបន្តឆ្នាំ២០១៥ នៅអគ្គនាយកដ្ឋានកៅស៊ូ

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥



ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យកៅស៊ូឆ្នាំ២០១៤ និងលើកទិសដៅការងារបន្តឆ្នាំ២០១៥

**សូមគោរព៖**

- គណៈអធិបតី
- ឯកឧត្តម លោក លោកស្រី សមាជិកសមាជិកានៃអង្គប្រជុំជាទីមេត្រី

ទី១- ថ្ងៃនេះ យើងទាំងអស់គ្នាបានមកចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារផ្នែកកៅស៊ូឆ្នាំ២០១៤ និងលើកទិសដៅការងារបន្តឆ្នាំ២០១៥ ស្របពេលជាមួយនឹងលោក **ប៉ុល សុផា** ដែលទើបត្រូវបានតែងតាំងជាអគ្គនាយករងទទួលបន្ទុករួមនៃអគ្គនាយកដ្ឋានកៅស៊ូ បន្ទាប់ពីឯកឧត្តម **លី ផល្លា** ត្រូវទទួលភារកិច្ចជាអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាពេលថ្មីៗនេះ។

ទី២- តើវិស័យកៅស៊ូមានសក្ដានុពលយ៉ាងណាខ្លះក្នុងបរិបទនៃសាកលភាវូបនីយកម្ម ពិសេសក្នុងស្ថានភាពបច្ចុប្បន្ន នៅកម្ពុជា?

ខ្ញុំសូមអនុញ្ញាត រំលឹកអង្គប្រជុំទាំងមូលមេត្តាជ្រាបថា ដំណាំកៅស៊ូត្រូវបានប្រសិទ្ធភាពថាជា “មាស ស” ឬជាដំណាំឧស្សាហកម្មមួយដ៏មានសារៈសំខាន់ ចាប់តាំងពីសតវត្សរ៍ទី១៩មកម្លេះ ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងការស្ដារនិងអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ឆ្លងកាត់ការវិវត្តរីកចម្រើនតាមដំណាក់កាលជាបន្តបន្ទាប់ក្នុងរយៈពេលជាងមួយសតវត្សរ៍កន្លងមកនេះ ដំណាំកៅស៊ូ បានផ្ដល់នូវផលប្រយោជន៍ ដ៏សំខាន់បន្ទាប់ពីដំណាំស្រូវរួមមាន៖ (១) ផ្ដល់ប្រាក់ចំណូលដល់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារកសិករ តាមរយៈនីហរណកម្មកៅស៊ូឬផលិតផលសម្រេចដែលផលិតពីកៅស៊ូ ដោយសារមុខទំនិញនេះមានតម្លៃខ្ពស់ និងមានតម្រូវការជាចាំបាច់នៅលើទីផ្សារអន្តរជាតិ (២) បង្កើតការងារនិងមុខរបរមានស្ថេរភាពជូនប្រជាពលរដ្ឋនៅតាមជនបទ រួមចំណែកជួយកាត់បន្ថយការធ្វើចំណាកស្រុក (៣) ផ្ដល់ឈើសម្រាប់ប្រើប្រាស់ជាគ្រឿងសំណង់ គ្រឿងសង្ហារឹម និងជាឈើប្រើប្រាស់ដើម្បីជួយកាត់បន្ថយដល់ការកាប់បំផ្លាញព្រៃធម្មជាតិ (៤) ការពារការហូរច្រោះដី និងបង្កើតជាគម្របបៃតងឡើងវិញដែលបំពេញតួនាទីជានិយតករធម្មជាតិ ចូលរួមចំណែកយ៉ាងសកម្មក្នុងការជួយការពារបរិស្ថានទប់ទល់នឹងការឡើងកម្ដៅផែនដីតាមរយៈការស្រូបយកឧស្ម័នកាបូនិចពីបរិយាកាស។

ទី៣. ដើម្បីឱ្យចម្ការកៅស៊ូឈានទៅរកវិបុលកម្មទំនើប និងក៏ជាឱកាសរបស់កម្ពុជាកំពុងតែមានក្នុងការអភិវឌ្ឍផ្នែកកៅស៊ូចាំបាច់ គឺត្រូវសម្រិតសម្រាំងពូជកៅស៊ូ ឱ្យមានគុណភាពល្អ



ទិដ្ឋភាពភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យកៅស៊ូឆ្នាំ២០១៤ និងលើកទិសដៅការងារបន្តឆ្នាំ២០១៥

ទាំងជ័រ និងឈើកៅស៊ូ ដែលការងារនេះ អគ្គនាយកដ្ឋានកៅស៊ូបានចាប់ផ្តើមអនុវត្តគម្រោងធម្មនិយាមកម្មច្បារពូជនៅទូទាំងប្រទេស ដែលមានស្រាប់ និងដែលត្រូវបង្កើតថ្មីក្នុងក្របខណ្ឌគម្រោង AFD ដើម្បីឱ្យសមស្របតាម បទដ្ឋានបច្ចេកទេស ដោយហេតុថា ពូជកៅស៊ូនៅច្បារនីមួយៗមានលក្ខណៈច្របូកច្របល់ (ពូជលាយឡំគ្នា) ដែលធ្វើឱ្យមានការលំបាកក្នុងការយកទៅដាំ ថែទាំ ប្រមូលផល និងកែច្នៃ ។ ចំណុចនេះ អគ្គនាយកដ្ឋានកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាត្រូវណែនាំ និងសហការជាមួយក្រុមហ៊ុនដែលទទួលដីសម្បទានសេដ្ឋកិច្ច ឱ្យធ្វើការនាំចូលពូជកៅស៊ូ ដែលមានទិន្នផលខ្ពស់ និងហ៊ានទាត់ចោលនូវពូជដែលមានទិន្នផលទាប ដោយប្រើប្រាស់ក្លូនកៅស៊ូដែលបានណែនាំតាមវិធានបច្ចេកទេសសមស្រប។ ម៉្យាងទៀត កម្ពុជាបានក្លាយជាសមាជិករបស់អង្គការកៅស៊ូអន្តរជាតិដូចជាសមាគមប្រទេសផលិតកៅស៊ូធម្មជាតិ និងក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ ក្នុងការផ្លាស់ប្តូរបទពិសោធន៍ ការអប់រំ បណ្តុះបណ្តាល ការផ្ទេរបច្ចេកវិទ្យា ការសិក្សាអំពីទីផ្សារ និងតម្លៃកៅស៊ូ...។ល។ ដូច្នេះ ត្រូវខិតខំបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាសមាជិកលើវិស័យកៅស៊ូចាប់តាំងពីការដាំដុះរហូតដល់ការកែច្នៃផលិតផល ។

ទី៤. អគ្គនាយកដ្ឋានកៅស៊ូត្រូវយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍកៅស៊ូគ្រួសារ នៅតាមបណ្តាខេត្ត ដោយត្រូវពង្រឹកមន្ត្រីជំនាញបន្ថែមដើម្បីចុះឱ្យដល់មូលដ្ឋានខេត្ត ស្រុកដែលមានសក្តានុពលដំណាំកៅស៊ូដើម្បីធ្វើការផ្សព្វផ្សាយ ណែនាំ និងបណ្តុះបណ្តាលអំពីការដាំដុះ ការថែទាំ ការប្រមូលផល និងការកែច្នៃដល់ប្រជាពលរដ្ឋដែលមានដីអាចដាំដុះកៅស៊ូបាន ជាពិសេសប្រជាពលរដ្ឋ ដែលទើបនឹងទទួលបាន ដីកម្មសិទ្ធិពីរាជរដ្ឋាភិបាល តាមរយៈ "**គោលនយោបាយចាស់-សកម្មភាពថ្មី**" ។ ជាមួយគ្នានេះ ត្រូវគិតគូររៀបចំបង្កើតសមាគមកសិករដាំកៅស៊ូដើម្បី(១) ការពារផលប្រយោជន៍របស់កសិករដាំកៅស៊ូ (២) លើកកម្ពស់អំណាចទីផ្សាររបស់កសិករ តាមរយៈការធ្វើទីផ្សារកៅស៊ូរួមគ្នា (៣)ជំរុញកំណើនសហគ្រាសកសិកម្មខ្នាតតូច និងមធ្យមនៅជនបទដោយត្រូវគិតគូរអំពីការធ្វើកសិកម្មតាមកិច្ចសន្យា (៤) បង្កើនប្រាក់ចំណូល បង្កើតការងារ កាត់បន្ថយភាពក្រីក្រ និងទប់ស្កាត់ការធ្វើចំណាកស្រុក។

**ទី៥.** - តាមមាត្រា ៣៣ នៃច្បាប់ សហលក្ខន្តិកៈមន្ត្រីរាជការ



*ពិធីបំពាក់គ្រឿងឥស្សរិយសជូនដល់មន្ត្រីរាជការ មានស្នាដៃក្នុងការបំពេញការងារ*

ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី៥ អំពីវិន័យអ្នករាជការរាល់រូបត្រូវតែគោរព អនុវត្តច្បាប់ និងបទបញ្ជា ហើយ និងការណែនាំពីថ្នាក់លើរបស់ខ្លួន។ បានសេចក្តីថា អ្វីដែលជាភារកិច្ច របស់មន្ត្រីរាជការ មានចែងយ៉ាងច្បាស់លាស់នៅក្នុងច្បាប់បទបញ្ជា និងការណែនាំរបស់ថ្នាក់លើ។ កាតព្វកិច្ចនេះ តម្រូវឱ្យមន្ត្រីរាជការត្រូវធ្វើដោយខានមិនបាន។ ក៏ប៉ុន្តែនៅមានកាតព្វកិច្ចមួយចំនួនទៀត ដែលមិនមានចែងនៅក្នុងច្បាប់ បទបញ្ជា និងការណែនាំរបស់ថ្នាក់លើ តែជាកាតព្វកិច្ចផ្នែកសីលធម៌តម្រូវឱ្យមានមនសិការវិជ្ជាជីវៈ ឬ មនសិការស្នេហាជាតិមាតុភូមិ របស់អ្នករាជការទូទៅ។ ស្មារតីសាមគ្គីភាព ឯកភាពផ្ទៃក្នុង ភាពអត់ធ្មត់ យោគយល់គ្នា ជួយគ្នាទៅវិញទៅមកជាកត្តាជ័យជម្នះនៃការងារ។

- ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះស្នាដៃទាំងឡាយដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានជាវិជ្ជមានក្នុងឆ្នាំកន្លងមក និងសូមជូនពរជ័យសព្ទសាធុការដល់អង្គពិធីទាំងមូល និងបិទកិច្ចប្រជុំ។

***សូមអរគុណ!***

# សុន្ទរកថា

## ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី១០៤ ឆ្នាំ២០១៥ ក្រោមប្រធានបទ " ដំណើរឆ្ពោះទៅមុខៈ ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោកឆ្នាំ១៩៩៥ "

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី១០៤ ឆ្នាំ២០១៥*

សូមគោរពៈ

- គណៈអធិបតី

- លោកជំទាវ **ច័ន្ទ សូរិយ៍** រដ្ឋលេខាធិការក្រសួងកិច្ចការនារី

- លោកជំទាវ **កែវ ចរិយា** អនុរដ្ឋលេខាធិការតំណាងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុនិងលោកជំទាវ **សៅ សុគន្ធារី** អនុរដ្ឋលេខាធិការតំណាងក្រសួងមុខងារសាធារណៈ

- លោកជំទាវ ឯកឧត្តម លោកស្រី នាងកញ្ញា អស់លោក សមាជិក សមាជិកា នៃអង្គពិធីជាទីមេត្រី

១. ថ្ងៃនេះ ក្នុងនាមថ្នាក់ដឹកនាំក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខ្ញុំមានសេចក្ដីសោមនស្សរីករាយដោយបានចូលរួមអបអរសាទរខួបលើកទី១០៤ ទិវាអន្តរជាតិនារី៨មីនា ដែលយើងទាំងអស់គ្នាកំពុងប្រារព្ធធ្វើយ៉ាងមហោឡារិកនាពេលនេះ។ ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមសម្ដែងដោយក្ដីស្មោះសជាទីបំផុតចំពោះវត្តមានរបស់លោកជំទាវ ឯកឧត្តម លោកស្រី នាងកញ្ញា អស់លោក ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ដែលបានឆ្លៀតឱកាសដ៏មមាញឹកអញ្ជើញចូលរួមក្នុងពិធីដ៏មានអត្ថន័យនេះ ដែលញ៉ាំងឱ្យពិធីនេះប្រព្រឹត្តទៅក្នុងបរិយាកាសមួយដ៏កក់ក្ដៅ និងជាភាតរភាពយ៉ាងក្រៃលែង។

២. ជាមួយនេះដែរ ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមពាំនាំនូវការផ្ដាំផ្ញើសាកសួរសុខទុក្ខនិងសេចក្ដីនឹករលឹកដ៏ជ្រាលជ្រៅពី **សម្ដេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ជូនចំពោះបងប្អូននារីជាមន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលកំពុងប្រារព្ធខួបលើកទី១០៤ នៃទិវាអន្តរជាតិនារីដ៏ថ្លៃថ្លានេះ ដែល **សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត តែងតែយកចិត្តទុកដាក់យ៉ាងជ្រាលជ្រៅបំផុតការពារផលប្រយោជន៍ និងលើកកម្ពស់តម្លៃនៃនារីខ្មែរយើងដែលធ្លាប់មានប្រវត្តិតាំងពីយូរអង្វែងរៀងរហូតមកដល់បច្ចុប្បន្ននេះ ដោយផ្សារភ្ជាប់ទៅ នឹងចលនាដ៏សកម្មរបស់នារីទូទាំងពិភពលោក។

៣. ការប្រារព្ធទិវាអន្តរជាតិនារី៨មីនា គឺជាព្រឹត្តិការណ៍ប្រចាំឆ្នាំដែលមានអត្ថន័យយ៉ាងជ្រាលជ្រៅ ដើម្បីដាស់ស្មារតីដល់យើងទាំងអស់គ្នាដោយមិនត្រូវមើលរំលងអំពីតួនាទីដ៏សំខាន់របស់ស្ត្រីកម្ពុជា ដែលជាធនធានមនុស្សប្រកបដោយសក្ដានុពលនៅក្នុងគ្រួសារ និងសង្គមជាតិយើងលើការគ្រប់គ្រងការអប់រំសមាជិកគ្រួសារ រួមទាំងការលើកកម្ពស់សីលធម៌ សមធម៌ សេចក្ដីថ្លៃថ្នូរ និងតម្លៃរបស់មនុស្សជាដើម។ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំនេះ ត្រូវបានរៀបចំឡើងក្រោមប្រធានបទ **" ដំណើរឆ្ពោះទៅមុខៈ ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោកឆ្នាំ១៩៩៥ "** ក្នុងគោលបំណងបំផុស

ស្មារតីដល់យើងទាំងអស់គ្នា ធ្វើយ៉ាងណាឱ្យសម្រេចបាននូវសមភាពដ៏ពិតប្រាកដរវាងបុរសនិងស្ត្រីក៏ដូចជាការទទួលស្គាល់ថា ស្ត្រីគឺជាតួអង្គមួយដែលមានតួនាទីសំខាន់បំផុតធ្វើឱ្យសង្គមយើងទាំងមូលមានការផ្លាស់ប្តូរកែប្រែមុខមាត់ថ្មីជាអាលជ្ជី ឆ្ពោះទៅរកការអភិវឌ្ឍរីកចម្រើនគ្រប់កាលៈទេសៈ។

៤. យើងទាំងអស់គ្នាបានដឹងរួចមកហើយអំពីប្រវត្តិនៃទិវាអន្តរជាតិ៨មីនាដូចក្នុងរបាយការណ៍របស់ក្រុមការងារយេនឌ័របានរាយការណ៍ជូនអម្បាញ់មិញនេះ។ ទោះជាយ៉ាងណាឆ្លៀតក្នុងព្រឹត្តិការណ៍ដ៏មានសារសំខាន់នេះខ្ញុំសូមអនុញ្ញាតរំលឹកអំពីប្រវត្តិខ្លះៗបន្ថែមទៀតជុំវិញទិវាអន្តរជាតិនារី៨មីនាដូចតទៅ៖ ថ្ងៃទី៨មីនានេះ ត្រូវបានអង្គការសហប្រជាតិ និងប្រទេសជាច្រើននៅជុំវិញពិភពលោកចាត់ទុកថាជាថ្ងៃឈប់សម្រាករបស់ជាតិគេផងដែរ។ ជាការពិត ស្ត្រីនៅគ្រប់ទ្វីបទាំងអស់គឺគ្រាន់តែបែងចែកគ្នាដោយខ្សែបន្ទាត់ព្រំដែនជាតិ មានភាពខុសគ្នាខាងភាសា សេដ្ឋកិច្ច និងនយោបាយប៉ុណ្ណោះ តែគេបានចេញមកប្រារព្ធទិវានេះទាំងអស់គ្នាក្នុងថ្ងៃ៨មីនានេះ។ យើងអាចក្រឡេកទៅមើលប្រវត្តិ នៃទិវានេះដែលបង្ហាញឱ្យឃើញនូវការតស៊ូរបស់ស្ត្រីយ៉ាងហោចណាស់ប្រាំបួនទសវត្សរ៍មកហើយ ដើម្បីស្វែងរកសមភាព យុត្តិធម៌ សន្តិភាព និងការអភិវឌ្ឍ។ ទិវាអន្តរជាតិនារីគឺជាប្រវត្តិរឿងរ៉ាវរបស់ស្ត្រីធម្មតាដែលជាអ្នកបង្កើតប្រវត្តិសាស្ត្រនេះឡើង ដោយបង្ហាញអំពីការតស៊ូជាច្រើនសតវត្សរ៍របស់ស្ត្រី ដើម្បីចូលរួមក្នុងសង្គមដោយឈរលើគោលការណ៍សមភាពជាមួយនឹងបុរស។ ការតស៊ូរបស់ស្ត្រីបានកើតឡើងតាំងពីសម័យក្រិកបុរាណមកម្លេះ ដោយនៅសម័យនោះស្ត្រីម្នាក់ឈ្មោះថា **លីស៊ីស្ត្រាតាស** (Lysistrata) បានផ្តួចផ្តើម ឱ្យមានបាតុកម្មប្រឆាំងនឹងបុរស ដើម្បីបញ្ចប់សង្គ្រាម។ នៅអំឡុងបដិវត្តន៍បារាំង ក្រុមស្ត្រីនៅក្នុងទីក្រុងប៉ារីសដែលបានអំពាវនាវឱ្យមានសេរីភាព សមភាព និងភាតរភាពបានសម្រុកចូលទីក្រុងវែរសៃ (Versailles) ដើម្បីទាមទារសិទ្ធិបោះឆ្នោតសម្រាប់ស្ត្រី។ តើទិវាអន្តរជាតិនេះកើតឡើងដោយរបៀបណា? គំនិតស្ត្រីពីទិវាអន្តរជាតិនារីនេះបានកើតឡើងដំបូងនៅត្រង់ចំណុចរបត់នៃសតវត្សរ៍ដែលពិភពឧស្សាហូបនីយកម្មកំពុងផ្ទុះឡើង និងបំលាស់ប្តូរប្រកបដោយហិង្សាកំណើនប្រជាជន យ៉ាងឆាប់រហ័ស និងការផ្ទុះឡើងនូវទ្រឹស្តីមនោគមវិជ្ជាជ្រុលនិយម។ តមកទៀត នៅថ្ងៃទី៨ មីនា ១៩០៨ ក្រុមស្ត្រីនៅទីក្រុងញូវយ៉កមួយចំនួនធំបានសម្រុកចូលដើម្បីទាមទារឱ្យបន្ថយម៉ោងធ្វើការងារ ទាមទារឱ្យផ្តល់កម្រៃពលកម្មសមរម្យ ទាមទារសិទ្ធិបោះឆ្នោត និងទាមទារឱ្យបញ្ចប់ការធ្វើពលកម្មលើកុមារ។ល។ ក្រុមនារីទាំងនេះបានបង្កើតពាក្យស្លោកមួយក្រោមចំណងជើងថា "**នំប៉័ង និងផ្កាកុលាប**" ដែលនំប៉័ងតំណាងឱ្យសន្តិសុខសេដ្ឋកិច្ច (ស្បៀង) ហើយផ្កាកុលាបតំណាងឱ្យសមភាពដ៏ប្រសើរក្នុងជីវិតរស់នៅ។



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៤ ឆ្នាំ២០១៥*

មហាសន្និបាតអង្គការសហប្រជាតិ ដែលមានប្រតិភូមកពីរដ្ឋជាសមាជិកទាំងអស់បានប្រារព្ធពិធីបុណ្យអន្តរជាតិនារី ដើម្បីទទួលស្គាល់ថា សន្តិភាពនិងការរីកចម្រើនរបស់សង្គមតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មនិងសមភាពរបស់ស្ត្រីនៅក្នុងការកសាងសន្តិភាព និងសន្តិសុខអន្តរជាតិ។ ចំពោះនារីទូទាំងពិភពលោក ថ្ងៃនេះគឺជាព្រឹត្តិការណ៍មួយដែលរំលឹកឡើងវិញពីប្រវត្តិតស៊ូរបស់ស្ត្រីដើម្បីសមភាព សន្តិភាពនិងការអភិវឌ្ឍ។

៥. ក្រឡេកមើលមកកម្ពុជាយើងវិញតើមានការវិវត្តន៍យ៉ាងណាដែរ? ប្រទេសខ្មែរមានរបបគ្រប់គ្រងរបស់ខ្លួនតាំងពីសម័យហ្វូណនមកម្លេះគឺក្នុងរជ្ជកាលព្រះនាង **សោមា** ដែលជាបុត្រីព្រះច័ន្ទ។ របបគ្រប់គ្រងនាសម័យនោះជារបបមាតាធិបតេយ្យមានន័យថា ខ្មែរចេះរស់នៅជាសង្គមជាក្រុមដោយមានការរៀបចំត្រឹមត្រូវ ផ្ទុយពីការរស់នៅបែបកុលសម្ព័ន្ធ ហើយជារបបដែលយកស្ត្រីជាធំ ក្នុងកិច្ចដោះស្រាយបញ្ហាទូទៅ។ ដូចគ្នានេះដែរ នៅក្នុងសង្គមគ្រួសារគេតែងតែប្រើពាក្យ **មេ**






*សកម្មភាពនារីចូលរួមក្នុងពិធីទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៤ ឆ្នាំ២០១៥*

មុន **បា** ដូចជា ជីដូនជីតា មីងមា ម៉ែឪ ។ល។ សមនឹងសុភាសិតបុរាណបានពោលថា **សូវស្លាប់បាកុំឱ្យស្លាប់មេ សូវលិចទូកកណ្ដាលទន្លេ កុំឱ្យភ្លើងឆេះផ្ទះ** នេះមានន័យថា បា-ឪពុកមានការទទួលខុសត្រូវមិនសំខាន់ដូចមេ-ម្ដាយទេ។ តាមការសង្កេតតាំងពីសម័យហ្វូណន រហូតមកទល់សព្វថ្ងៃនេះ របបមាតាធិបតេយ្យរបស់ខ្មែរ នៅមានជីវិតរឹងប៉ឹងណាស់នៅក្នុងគ្រួសារខ្មែរភាគច្រើន។ របបនេះមានកម្លាំងខ្លាំងតាំងពីមុនសម័យបារាំងចូលស្រុក ហើយជំនាន់នោះស្ត្រីខ្មែរមានលក្ខណៈជាមាតុភរិយា-ប្រពន្ធទុកស្មើម្ដាយ។ រហូតមកដល់សម័យឥណ្ឌាចូលស្រុកខ្មែរ ព្រះនាង**សោមា ឬលីវយី** ឬនាងនាគព្រមរៀបចំអភិសេកជាមួយព្រះបាទ**កៅណ្ឌិន្យ**បានលុះត្រាតែគោរពរបបមាតាធិបតេយ្យរបស់ខ្មែរ។ ការគោរពនេះ ត្រូវបានរៀបចំជាពិធីមួយយ៉ាងឱឡារិក ដោយតម្រូវឱ្យព្រះបាទ**កៅណ្ឌិន្យ**តោងស្បៃដើរតាមក្រោយនាងសោមា ហើយហាមឃាត់ងាកឆ្វេងស្ដាំជានិម្មិតរូប និងជារូបិយកម្មនៃរបបមាតាធិបតេយ្យ ដែលតាមទំនៀមទម្លាប់យើងបានពោលថា **ព្រះថោងតោងស្បៃនាងនាគ** "។ ពិធីនេះ មានឆ្លាក់នៅជញ្ជាំងប្រាសាទបាយ័ន ដើម្បីរំលឹកឡើងវិញនូវរបបមាតាធិបតេយ្យ។

**អង្គពិធីទាំងមូលជាទីមេត្រី** !

**៦**. ការប្រារព្ធទិវានេះលើប្រធានបទស្ដីពី "**ដំណើរឆ្ពោះទៅមុខ៖ ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោកឆ្នាំ១៩៩៥**" ក៏ជាផ្នែកមួយនៃការរំលឹកខួបលើកទី២០ នៃសេចក្ដីប្រកាសទីក្រុងប៉េកាំងនិងផែនការសកម្មភាពទីក្រុងប៉េកាំង ( ទីក្រុងប៉េកាំង+២០ ) ដែលដាក់ចេញនៅក្នុងសន្និសីទស្ត្រីពិភពលោកលើកទី៤ ឆ្នាំ១៩៩៥ ដែលមានការចូលរួមពីតំណាងរាប់ពាន់នាក់របស់រដ្ឋាភិបាលនៃប្រទេសចំនួន ១៨៩ រួមទាំងសកម្មជនពីអង្គការសង្គមស៊ីវិលផងដែរ។ សេចក្ដីប្រកាសទីក្រុងប៉េកាំង និងផែនការសកម្មភាពទីក្រុងប៉េកាំង តំណាងឱ្យការប្ដេជ្ញាចិត្តដ៏ខ្ពស់ និងគ្រប់ជ្រុងជ្រោយមួយដែលគ្របដណ្ដប់លើចំណុចសំខាន់ៗចំនួន១២ចំណុចក្នុងការធ្វើឱ្យសម្រេចបាននូវសមភាពយេនឌ័រ និងការផ្ដល់ភាពអង់អាចដល់ស្ត្រី។ ប្រតិភូទាំងអស់បានរកឃើញនូវឧបសគ្គរារាំងការអភិវឌ្ឍនិងរក្សាការអភិវឌ្ឍ។ គណៈប្រតិភូបានធ្វើសេចក្ដីសម្រេចយល់ព្រមបន្ថែមទៀត ដើម្បីបន្តអនុវត្តគំនិតផ្ដួចផ្ដើមនៅក្នុងសន្និសីទស្ដីពីស្ត្រីនាឆ្នាំ១៩៩៥។ ឯកសារចុងក្រោយដែលផ្សព្វផ្សាយដោយកិច្ចប្រជុំនេះបានលើកឡើងថា "ការរីកចម្រើនរបស់ស្ត្រីនិងការសម្រេចបានសមភាពរវាងស្ត្រីនិងបុរសគឺជាបញ្ហាសិទ្ធិមនុស្សនិងជាលក្ខខណ្ឌសម្រាប់យុត្តិធម៌សង្គម ហើយគេមិនត្រូវចាត់ទុកថា នេះជាបញ្ហារបស់ស្ត្រីនោះទេ"។

**៧**. ជាការឆ្លើយតបទៅនឹងប្រធានបទខាងលើនេះ យើងអាចវាយតម្លៃជាវិជ្ជមានថា ក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ សមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ បន្ទាប់ពីបានស្ដាប់ខ្លឹមសារនៃរបាយការណ៍របស់ក្រុមការងារយេនឌ័រ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងចំណាប់អារម្មណ៍ដ៏មានអត្ថន័យរបស់លោកជំទាវតំណាងក្រសួងកិច្ចការនារី ក្នុងនាមថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះស្នាដៃនិងសមិទ្ធផលជាច្រើនដែលក្រសួងកិច្ចការនារី និងក្រុមការងារយេនឌ័រ ក្រសួងកសិកម្ម





*សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញផ្ដល់បាច់ផ្កាជូនតំណាងនារី ក្នុងឱកាសអន្តរជាតិនារី៨មីនា*

រុក្ខាប្រមាញ់ និងនេសាទសម្រេចបានគួរឱ្យកោតសរសើរយ៉ាងក្រៃលែង។ ខ្ញុំសង្ឃឹមថា ក្រុមការងារយេនឌ័រក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលមានអង្គភាពជំនាញទាំងអស់ជាសេនាធិការនឹងខិតខំប្រឹងប្រែងបន្តបេសកកម្មរបស់ខ្លួនឱ្យទទួលបានជោគជ័យថ្មីៗបន្ថែមទៀត ឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើងខាងលើនេះ។ ជារួមសមិទ្ធផលទាំងអស់នេះពិតជាបានបង្ហាញយ៉ាងប្រត្យក្ស អំពីការចូលរួមជាធ្លុងមួយរបស់យើងទាំងអស់គ្នានៅក្នុងជីវភាពនយោបាយក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងម៉ឺងម៉ាត់បំផុតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលកម្ពុជា**។ ពិតណាស់ថា ការចូលរួមរបស់ស្ត្រី បានធ្វើឱ្យមានភាពចម្រើន ជឿនលឿនទៅមុខយ៉ាងធំធេង។ ប៉ុន្តែយើងត្រូវធ្វើដំណើរនៅលើផ្លូវដ៏វែងឆ្ងាយទៀតដើម្បីសម្រេចឱ្យបាននូវពិភពលោកមួយដែលគ្មានការរើសអើងលើយេនឌ័រ និងនិយាយដោយឡែកនៅក្នុងបរិបទកម្ពុជានាពេលបច្ចុប្បន្ននេះ។ យ៉ាងណាក៏ដោយលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំ និងសេវាសុខភាព និងឱកាសក្លាយជាអ្នកចូលរួមពេញលេញនៅក្នុងជីវភាពនយោបាយគឺជាសិទ្ធិរបស់មនុស្សគ្រប់រូប និងជាកត្តារួមផ្សំដ៏សំខាន់ និងចាំបាច់នៃលទ្ធិប្រជាធិបតេយ្យ។ លើសពីនេះទៅទៀត ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពអាចបានសម្រេចបាន ដរាបណាអំពើហឹង្សា និងការរើសអើងចំពោះស្ត្រី ត្រូវបានដោះស្រាយ។

ដូច្នេះដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យ ក៏ដូចជាបញ្ហាប្រឈមទាំងឡាយដែលនៅសេសសល់ ពុំទាន់ត្រូវដោះស្រាយឱ្យបានគ្រប់ជ្រុងជ្រោយក៏ដោយ ក៏យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ស្ដីពីការជំរុញអនុវត្តគោលនយោបាយជាតិ ប្រជាជននិងសកម្មភាពយេនឌ័រជាមាគ៌ាមួយក្នុងការជួយបំភ្លឺផ្លូវដើម្បីពង្រឹងគុណភាពប្រជាជនលើកស្ទួយស្ថានភាពស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយយុវជន-យុវនារីឱ្យទៅជាកម្លាំងចលករដ៏មានសារសំខាន់សម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យនិងឱ្យស្របតាម " **ផែនការយុទ្ធសាស្ត្រនារីរតនៈទី៣** " ដែលជាត្រីវិស័យមួយដ៏ត្រចះត្រចង់ជួយតម្រង់ទិសយើងទាំងអស់គ្នាឆ្ពោះទៅរកភាពជោគជ័យតរៀងទៅ។

ជាថ្មីម្ដងទៀត ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនិងសូមអំពាវនាវដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងដល់គ្រប់ដៃគូអភិវឌ្ឍទាំងអស់ បន្តជួយគាំទ្រដល់សកម្មភាពនារីក្នុងវិស័យកសិកម្មក្នុងន័យស្ថាបនាដើម្បីឱ្យមានសមភាពរវាងបុរសនិងស្ត្រីឱ្យបានគ្រប់ទីកន្លែង និងគ្រប់កាលៈទេសៈ ព្រោះនារីគឺជាដៃគូជាមួយបុរសដែលពុំអាចខ្វះបាន ក្នុងការកសាងជាតិមាតុភូមិកម្ពុជាឱ្យបានរុងរឿង។

ជាទីបញ្ចប់ ខ្ញុំសូមឱ្យស្មារតីនៃទិវាអន្តរជាតិនារី៨មីនាដក់ជាប់នៅក្នុងដួងចិត្តខ្មែរគ្រប់រូប ចេះសាមគ្គីយោគយល់គ្នារួបរួមគ្នាកសាងសង្គមជាតិឱ្យមានភាពរុងរឿងថ្កុំថ្កើងជានិច្ចនិរន្តរ៍ដើម្បីចូលរួមលើកកម្ពស់សង្គមខ្មែរឱ្យមានវឌ្ឍនភាព សន្តិភាពនិងសុភមង្គលតរៀងទៅ។ សូមប្រសិទ្ធពរជ័យសិរីមង្គលជូនដល់គណៈអធិបតី លោកជំទាវ ឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ សូមទទួលនូវពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**

# សន្ទរកថា

## ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីបិទកិច្ចប្រជុំបូកសរុបការងារផលិតកម្មនិងបសុព្យាបាល ឆ្នាំ២០១៤ និងទិសដៅការងារផលិតកម្មនិងបសុព្យាបាល ឆ្នាំ២០១៥

(ភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥)





*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីបិទកិច្ចប្រជុំបូកសរុបការងារផលិតកម្ម និងបសុព្យាបាល ឆ្នាំ២០១៤ និងទិសដៅការងារផលិតកម្ម និងបសុព្យាបាល ឆ្នាំ២០១៥*

**- ឯកឧត្តមរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**- ឯកឧត្តម លោក លោកស្រី នាងកញ្ញា**

ថ្ងៃនេះខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងក្ដីសោមនស្សរីករាយឥតឧបមា ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោកស្រី អស់លោកជាថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្នាក់ដឹកនាំអង្គភាពនានាក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកសិកម្ម និងការិយាល័យផលិតកម្មនិងបសុព្យាបាល រាជធានី-ខេត្ត លោក លោកស្រីថ្នាក់ដឹកនាំ និងមន្ត្រីរាជការនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ក្នុងឱកាសនៃពិធីបិទកិច្ចប្រជុំបូកសរុប និងវាយតម្លៃលើការងារផលិតកម្មនិងបសុព្យាបាល ឆ្នាំ២០១៤ និងទិសដៅសម្រាប់ឆ្នាំ២០១៥ នាថ្ងៃនេះ។ តាមរបាយការណ៍បូកសរុប ការងារផលិតកម្មនិងបសុព្យាបាលឆ្នាំ២០១៤ បានឱ្យដឹងថា ចំនួនសត្វគ្រប់ប្រភេទសរុបនាឆ្នាំ២០១៤ មានចំនួន ៣៧.៩លានក្បាល កើនឡើង ១១.៦០ភាគរយធៀបឆ្នាំ២០១៣ លើសផែនការដែលមាន កំណត់ក្នុងសូចនាករចែងក្នុងឯកសារផែនការយុទ្ធសាស្ត្រកសិកម្ម២០១៤-២០១៨ ដែលកំណត់ថាការចិញ្ចឹមសត្វគ្រប់ប្រភេទត្រូវកើនយ៉ាងតិចចំនួន ៣ភាគរយក្នុងមួយឆ្នាំ។ ដូចដែលបានបញ្ជាក់រួចមកហើយថា ចំនួនសត្វដែលលើកឡើងនេះ ជាចំនួនសត្វដែលសល់ពីការពិឃាត និងការនាំចេញ។ សមិទ្ធផលជាវិជ្ជមាននេះ ជាមោទកៈភាពរបស់អង្គភាពផលិតកម្មនិងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជំនួសមុខឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមសម្ដែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនេះ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី បើពិនិត្យលើផលិតកម្មសត្វតាមប្រភេទសត្វបង្ហាញឱ្យយើងឃើញថា ប្រភេទសត្វមួយចំនួនមានការថយចុះដូចជាផលិតកម្មគោ និងក្របី មានការថយចុះយ៉ាងខ្លាំងគួរឱ្យមានការព្រួយបារម្ភ និងត្រូវយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លា។ ចំនួនគោ ក្របី នាឆ្នាំ២០១៤ មានចំនួនតែ ៣.៦លានក្បាល ថយចុះចំនួន ១១ភាគរយ។ ចំនួននេះនឹងចុះថយទៀតនាឆ្នាំខាងមុខ ប្រសិនបើមិនមានវិធានការជំរុញការចិញ្ចឹមឡើងវិញ ហើយកម្ពុជាអាចជួបវិបត្តិដោយសារការធ្លាក់ចុះផលិតកម្មគោ -ក្របីនេះ។ ផលិតកម្មជ្រូក ទោះបីជាតាមរបាយការណ៍បញ្ជាក់មានការកើនឡើងចំនួន ១២.៣ភាគរយនាឆ្នាំ២០១៤ ប៉ុន្តែនៅតែមិនអាចផ្គត់ផ្គង់តម្រូវការក្នុងស្រុក

ដែលមូលហេតុនេះ កម្ពុជានៅត្រូវការនាំចូលជ្រូកពីបរទេស ដើម្បីបំពេញ ការខ្វះខាតនេះ។ យើងមានការព្រួយបារម្ភថា នៅពេលដែលកិច្ចព្រមព្រៀងសហគមន៍សេដ្ឋកិច្ចអាស៊ាន ត្រូវបានអនុវត្តនាចុងឆ្នាំ២០១៥ នោះលទ្ធភាពលំហូរទំនិញ ដែលក្នុងនោះមានទាំងសត្វរស់ និងផលិតផលសត្វនឹងអាចត្រូវបាននាំចូលមកកម្ពុជា ដែលនឹងជាគ្រោះគម្រាមកំហែងដល់ផលិតកម្មក្នុងស្រុកជាក់ជាមិនខាន ប្រសិនបើផលិតកម្មក្នុងស្រុកនៅតែមិនអាចប្រកួតប្រជែងបានជាមួយទំនិញមកពីបរទេស។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

ខ្ញុំបានស្តាប់ដោយយកចិត្តទុកដាក់នូវរបាយការណ៍របស់ឯកឧត្តម **កៅ ផល** ប្រធាននាយកដ្ឋាន ផលិតកម្មនិងបសុព្យាបាល ដែលធ្វើការបូកសរុបលទ្ធផលកិច្ចប្រជុំការងារផលិតកម្មនិងបសុព្យាបាល រយៈពេល២ថ្ងៃនេះ ដែលរួមមាន ៣ចំណុចសំខាន់ៗៈ (១) បទបង្ហាញអំពីស្ថានភាពផលិតកម្មសត្វនាឆ្នាំ២០១៤ និងបទបង្ហាញស្តីពីការអនុវត្តថវិកានិងសកម្មភាពឆ្នាំ២០១៥ នៃកម្មវិធីទី២ស្តីពីការជំរុញផលិតកម្មសត្វ ដែលមាន៩អនុកម្មវិធីរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ដែលជំរុញឱ្យមានការរៀបចំថវិការដ្ឋ និងសកម្មភាពដ៏ជាក់លាក់នេះ គឺជាការធ្វើកំណែទម្រង់ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល (២) ការពិភាក្សាលើ ប្រធានបទចំនួន ៣សំខាន់ៗ ពាក់ព័ន្ធការងារផលិតកម្មសត្វ និងទីផ្សារសត្វ ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លងសត្វ និងប្រសិទ្ធភាពនៃការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់និងផលិតផលសត្វ និង (៣) វិធានការសម្រាប់ឆ្នាំ២០១៥។

ខ្ញុំសូមធ្វើការកោតសរសើរ នូវគំនិតឈ្លាសវៃ ដែលតម្រូវឱ្យមានបទបង្ហាញស្តីពីស្ថានភាពផលិតកម្មសត្វត្រូវបានយកមកបង្ហាញក្នុងកិច្ចប្រជុំនេះ បើទោះបីជាព័ត៌មានលម្អិតមានសរសេរយ៉ាងច្បាស់ក្នុង របាយការណ៍ក៏ដោយ ប៉ុន្តែជាការសំខាន់ណាស់ដែលឯកឧត្តម លោកជំទាវ លោក លោកស្រី ត្រូវបានជម្រាបជូនពិស្តារបន្ថែមទៀតនាពេលនេះ។ បន្ថែមលើសពីនេះការបង្ហាញពីថវិកាតាមកម្មវិធី និងសកម្មភាព តាមអនុកម្មវិធីសម្រាប់ឆ្នាំ២០១៥ ដែលនេះជាវិញ្ញាសារថ្មី សម្រាប់គ្រប់ៗគ្នានោះ ពិតជាផ្តល់ធាតុចូលដល់អ្នកដែលពាក់ព័ន្ធដែលភាគច្រើនមានវត្តមានក្នុងកិច្ចប្រជុំនេះ។ ខ្ញុំមានការចាប់អារម្មណ៍ចំពោះប្រធានបទទាំង៣ ដែលជាប្រធានបទសំខាន់និងប្រឈមចំពោះការងារផលិតកម្ម និងបសុព្យាបាល ដែលបានលើកយកមកពិភាក្សានិងឯកភាពជាក់ចេញនូវដំណោះស្រាយនោះ។





*សកម្មភាពសិក្ខាកាមចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបការងារផលិតកម្មនិងបសុព្យាបាល ឆ្នាំ២០១៤ និងទិសដៅការងារផលិតកម្មនិងបសុព្យាបាល ឆ្នាំ២០១៥*

បន្ថែមលើសពីនេះ ខ្ញុំក្នុងនាមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏មានអនុសាសន៍មួយចំនួនជូនដល់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល មន្ទីរកសិកម្ម និងការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានី-ខេត្ត លើការងារផលិតកម្មនិងបសុព្យាបាលដូចខាងក្រោមៈ

១. ធ្វើឱ្យសម្រេចបាននូវលទ្ធផលការងារចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ជំរុញការអនុវត្តផែនការ សកម្មភាព ដែលចែងក្នុងផែនការអភិវឌ្ឍយុទ្ធសាស្ត្រវិស័យកសិកម្មឆ្នាំ ២០១៤-២០១៨ និងការអនុវត្តការងារថវិកាតាមកម្មវិធីនិងអនុកម្មវិធីឆ្នាំ២០១៥។

២.ជំរុញនិងធ្វើឱ្យសម្រេចនូវច្បាប់ លិខិតបទដ្ឋានគតិយុត្តិ ទាក់ទងការងារផលិតកម្មនិងបសុព្យាបាល ជាពិសេសច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ឯកសារគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ស្តីពីសុខភាពសត្វនិង



*សកម្មភាពបំពាក់គ្រឿងឥស្សរិយយស់ដល់មន្ត្រីមានស្នាដៃបំពេញការងារក្នុងពិធីបិទកិច្ចប្រជុំបូកសរុបការងារផលិតកម្មនិងបសុព្យាបាល ឆ្នាំ២០១៤ និងទិសដៅការងារផលិតកម្មនិងបសុព្យាបាល ឆ្នាំ២០១៥*

ផលិតកម្មសត្វ។

៣.ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ ការរៀបចំតួនាទី និងភារៈកិច្ចរបស់មន្ត្រីរាជការ ជំរុញនិងលើកទឹកចិត្តការបណ្តុះបណ្តាលឱ្យមានសមត្ថភាព ចំណេះនិងជំនាញពិតប្រាកដ។

៤. ជំរុញនិងលើកទឹកចិត្តការចិញ្ចឹមសត្វតាមគ្រប់រូបភាព លើកកម្ពស់ការសិក្សាស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល ពូជសត្វនិងការបង្កាត់ពូជដើម្បីបង្កើនផលិតភាពសត្វ ធ្វើឱ្យប្រសើរឡើងគុណភាព សុវត្ថិភាព ផលិតផលសត្វ ដើម្បីលើកកម្ពស់ចំណូលពីការចិញ្ចឹមសត្វដល់កសិករ និងអ្នកផលិត និងផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងលទ្ធភាពក្នុងការនាំចេញ និងការប្រកួតប្រជែង។

៥.ធ្វើឱ្យមានប្រសិទ្ធភាពលើការបង្ការ ការពារជំងឺឆ្លងរាលដាលសត្វ ជំងឺសួណូស និងការពារសុខភាពសាធារណៈ។

៦. ជំរុញ និងលើកកម្ពស់ការត្រួតពិនិត្យ អនាម័យសត្វ ផលិតផលសត្វ គុណភាពនិងអនាម័យចំណីសត្វ និងបសុឱសថ ដើម្បីការពារជំងឺឆ្លងរាលដាល ធានាគុណភាពសុវត្ថភាពសាច់សត្វនិងផលិតផលសត្វ សម្រាប់អ្នកបរិភោគ។

៧. ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មផលិតកម្មនិងបសុព្យាបាល ដើម្បីជំរុញផលិតកម្មសត្វនិងការធ្វើពាណិជ្ជកម្ម។

៨. អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវការណែនាំទាំងឡាយរបស់រដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសបណ្តាគោលការណ៍និងនីតិវិធីទាំងឡាយលើការងារគណនេយ្យនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះដែរ ត្រូវខិតខំប្រមូលចំណូលទាក់ទងការងារផលិតកម្មនិងបសុព្យាបាល ព្រមទាំងអនុវត្តប្រកបដោយភាពឈ្លាសវៃ មានតម្លាភាព និងត្រឹមត្រូវតាមនីតិវិធីនូវការបែងចែកចំណូលសេវាកម្មផលិតកម្មនិងបសុព្យាបាល។

៩. មានគំនិតច្នៃប្រឌិតការងារ មានសាមគ្គីភាពស្រឡាញ់រាប់អានគ្នាក្នុងអង្គភាព ដើម្បីប្រសិទ្ធភាពការងារ និងការអភិវឌ្ឍក្នុងអង្គភាព មន្ទីរ និងការិយាល័យរបស់ខ្លួន។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

ជាទីបញ្ចប់ ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមធ្វើការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលការងារផលិតកម្មនិងបសុព្យាបាល ដែលបានសម្រេចនាឆ្នាំ២០១៤ និងរយៈពេលកន្លងមក ការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានបណ្តាលមកពីគ្រោះទឹកជំនន់ ជំងឺឆ្លងរាតត្បាតសត្វ ជាពិសេសការសម្រេចបាននូវសូចនាករដែលបានដាក់ចុះ ការរៀបចំច្បាប់ លិខិតបទដ្ឋាន ដូចដែលយើងទាំងអស់គ្នាបានដឹងរួចមកហើយ។

ជាទីបញ្ចប់និងជាថ្មីម្តងទៀត តាងនាមឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមប្រសិទ្ធពរជូនឯកឧត្តម លោក លោកស្រី នាងកញ្ញា ចូលរួមក្នុងកិច្ចប្រជុំនេះ សូមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ដោយមនោសញ្ចេតនារីករាយ ខ្ញុំសូមប្រកាសបិទកិច្ចប្រជុំបូកសរុប និងវាយតម្លៃការងារផលិតកម្មនិងបសុព្យាបាល ឆ្នាំ២០១៤ និងទិសដៅឆ្នាំ២០១៥ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**

# បច្ចេកទេសដាំដំណាំមៀនប៉ៃលិន



សហការរៀបចំដោយ:
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម និងការិយាល័យផ្សព្វផ្សាយកសិកម្ម នៃមន្ទីរកសិកម្មខេត្តប៉ៃលិន

បន្តពីលេខ ៤២

## ការដាក់ជីតាមរយៈស្លឹករបស់មៀន

ដោយសារក្នុងផ្ទៃដីខ្លះ សភាពដីដាំមៀន អាចមានបញ្ហា ឬ ដោយសារបច្ច័យបរិស្ថានផ្សេងៗដូចជាភ្លៀងមិនធ្លាក់ ដីមានសំណើមតិច ចំណាត់ការផ្តល់ទឹកមិនល្អ ធ្វើឱ្យការស្រូបយកសារធាតុចិញ្ចឹមរបស់ដំណាំមិនបានល្អ ឬមិនគ្រប់គ្រាន់ និងមិនទាន់តាមតម្រូវការ ការប្រើប្រាស់ជី តាមរយៈស្លឹកសម្រាប់ដំណាំមៀនគឺជាវិធីមួយដែលបានដោះស្រាយនូវបញ្ហាបាន ជាពិសេស ក្នុងចន្លោះពេលមុនចេញផ្កា ស្ថិតក្នុងអំឡុងខែវិច្ឆិកា ដើមមៀនគួរត្រូវមានសភាពរឹងមាំ មែក ធាង និងស្លឹកដោយមានសភាពចាស់ល្មម ក្នុងការសន្សំសារធាតុចិញ្ចឹមទុកសម្រាប់ផ្តល់ពេលមៀនចេញផ្កា បើសិនជាមានការលាស់ត្រួយខ្ចី ឬអាយុស្លឹកនៅខ្ចីពេក អាចមានផលអាក្រក់ ក្នុងការចេញផ្កា ផ្លែបាន ដូចនេះ ការប្រើជីតាមស្លឹក ត្រូវប្រើជីដែលមានរូបមន្ត (០-៥២-៣៤) ឬ (១០-២០-២០) ឬ (១០-២០-១០) បាញ់ទៅលើស្លឹកឱ្យសព្វពាសពេញចម្ការ ដើម្បីឱ្យស្លឹកមៀនបានទទួលធាតុផូស្វ័រ (P) ហើយនិងប៉ូតាស្យូម (k) បានគ្រប់គ្រាន់ ដើម្បីជាការជំរុញឱ្យស្លឹកមៀនវិវត្តន៍ទៅរកភាពចាស់លឿនរូបមន្តជីត្រូវប្រើគឺ(០-៥២-៣៤)ប្រើក្នុងអាត្រា១២០ក្រាម លាយទឹក២០ លីត្រ បាញ់ឱ្យសពដើម មែក ស្លឹក ៣ដង ក្នុង១សប្តាហ៍ ក្នុងករណីដែលស្លឹកមានសារធាតុចិញ្ចឹមខ្ពស់ និងជាតំបន់ដែលមានប្រភពទឹក ។ សម្រាប់ក្នុងតំបន់ដែលប្រព័ន្ធស្រោចស្រពអាស្រ័យលើទឹកភ្លៀង ហើយដីមានសារធាតុចិញ្ចឹមទាប គួរបាញ់ ៥ដង ហើយបាញ់នៅក្នុងចន្លោះខែតុលា ខណៈពេលដែលស្លឹកមានអាយុជិតចាស់និងចាស់ល្មម។

## វិធីសាស្ត្រដាក់ជីដល់ដើមមៀន

ជាទូទៅគេតែងដាក់ជីតាម២របៀបគឺ ការដាក់ដោយបាច និងវិធីជីកជុំវិញដើម។ ការផ្តល់ដោយបាច គឺត្រូវបាចពាសពេញម្លប់មែក ចំណុចល្អរបស់វិធីនេះ គឺងាយស្រួលរហ័ស ហើយសន្សំសំចៃ កម្លាំងពលកម្ម តែមានចំណុចមិនសូវល្អ គឺធាតុចិញ្ចឹមងាយបាត់បង់។ ដូច្នេះទើបគេត្រូវប្រើជីតិចៗតែច្រើនដង ។ ចំណែកការផ្តល់ជីតាមបែបជីកជុំវិញដើម គឺគេជីកជុំវិញត្រង់ចុងស្លឹកនៃមែក ជាចង្អូរ ទទឹងប្រមាណ ២០ស.ម ជម្រៅពី៥ ដល់១០ស.ម ដោយជីកបុកក្នុងចង្អូរដែលត្រូវជីកហើយលប់ដី ក្រោយពីនេះទើប ស្រោចទឹកតាមក្រោយ ។

**វិធីសាស្ត្រដាក់ជីសរីរាង្គ ៖** ការដាក់ជីសរីរាង្គធម្មជាតិដូចជា ជីលាមកសត្វ ជីកំប៉ុស ដល់ដើមមៀនភាគច្រើន គេដាក់ដោយបាច ឬរោយ ជុំវិញក្រោមម្លប់មែក ឬអាចដាក់ដោយជីកជាចង្អូរទទឹង ២០ cm ជម្រៅ ៥-១០ cm រោយជីរួចលប់ដីពីលើជីនោះម្តងទៀតរួចស្រោចទឹក ។

**វិធីសាស្ត្រការដាក់ជីគីមី:** ការដាក់ជីគីមីបានត្រឹមត្រូវដើម្បីឱ្យមៀនងាយស្រួលក្នុងការស្រូបយក និងមានភាពឆាប់រហ័ស ប៉ុន្តែក៏អាស្រ័យទៅតាមប្រភេទដី និងអាយុរបស់ដើមមៀនផងដែរ ។ សម្រាប់ជី អាសូត (N) ធាតុសកម្មមានប្រតិកម្មលឿនជាងជីគីមីផ្សេងទៀត និងអាចរលាយក្នុងទឹកបានងាយ បើសិនជាឫរុក្ខជាតិ ស្រូបយកទៅទុកមិនទាន់ ធ្វើឱ្យបាត់បង់សារធាតុចិញ្ចឹមច្រើនទៅក្នុងបរិយាកាស ។ ចំណែកធាតុផូស្វរ (P)ថ្វីបើអាចរលាយក្នុងទឹកបានងាយ តែពេលនៅក្នុងដី អាចមានប្រតិកម្មជាមួយធាតុរ៉ែផ្សេងៗ ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការរលាយក្នុងទឹក ធ្វើឱ្យបាត់បង់សារធាតុចិញ្ចឹមសម្រាប់ការស្រូបយករបស់រុក្ខជាតិ ដូច្នេះការដាក់ជីផូស្វាតដល់ដើមមៀនត្រូវដាក់ជិតឫសបំផុត។សម្រាប់ជីប៉ូតាស្យូម ធាតុសកម្មមានប្រតិកម្មលឿនដូចជីអាសូតដែរ តែដោយសារមានធាតុភ្លើង ទើបត្រូវបានស្រូបយកទៅក្នុងស្រទាប់នៃអនុភាពរបស់ដីស្អិត ហើយមានលក្ខណៈមិនងាយនឹងហូរច្រោះ ធ្វើឱ្យជីជាតិអាចស្ថិតនៅជាប្រយោជន៍ក្នុងរយៈ

ពេលយូរសម្រាប់ដើមមៀន ។ សម្រាប់អាយុរបស់មៀន ក៏មានសារៈសំខាន់ក្នុងការស្រូបយកសារធាតុចិញ្ចឹមទៅប្រើប្រាស់ជាប្រយោជន៍ផងដែរ ក្នុងចន្លោះពេលទើបដាំថ្មីប្រព័ន្ធឫសនៅមិនទាន់លូតលាស់បានច្រើន ទើបត្រូវដាក់ជីឱ្យនៅជិតៗឫសបំផុត ចំណែកមៀនមានដងដើមធំ ប្រព័ន្ធឫសសម្រាប់ស្រូបយកសារធាតុចិញ្ចឹមមានការរីកលូតលាស់ច្រើនក្នុងបរិវេណជុំវិញមែក។ វិធីដាក់ជីគីមីដល់ដើមមៀនធំ ត្រូវជីកជាចង្អូរទទឹងប្រមាណ២០ ស.ម ជុំវិញបរិវេណមែក ដោយសារបរិវេណទាំងនោះមានឫសអំបោះ ហើយនឹងឫសខ្មែងជាឫសដែលមានសារធាតុចិញ្ចឹមច្រើន ។ ក្រៅពីនេះការដាក់ក៏អាចធ្វើទៅបានតាមរយៈការដាក់ជា ៤ ចំណែកដោយដាក់ក្នុងចង្អូរជុំវិញមែក៣ចំណែក នៅសល់ ១ចំណែកត្រូវបាច ឬរោយលើដីនៅក្រោមមែក តែត្រូវប្រុងប្រយ័ត្នកុំដាក់ជីនៅជិតគល់ពេក ។ ត្រូវបាចពង្រាយ កុំឱ្យនៅជាគំនរព្រោះបើសិនជាជិតដើមខ្លាំង ឬជាគំនរវាធ្វើឱ្យដើម និងឫសទទួលផលប៉ះពាល់ដោយសារការបញ្ចេញសារធាតុប្រៃរបស់ជី ។ ក្រោយពីការដាក់ជីរួចហើយ ត្រូវយកដីលប់ក្នុងចង្អូរវិញ ដើម្បីឱ្យជីរលាយបានឆាប់ បន្ថយការបាត់បង់ដោយការត្រូវហូរច្រោះ និងត្រូវស្រោចទឹកក្រោយពីការដាក់ជី ឱ្យសមល្មម មិនច្រើនពេកព្រោះទឹកអាចធ្វើឱ្យជីខ្ចាត់ខ្ចាយទៅឆ្ងាយ ឬក្នុងស្រទាប់ដីដែលទាបជាងលំដាប់ឫស។ ក្រៅពីនេះគួរប្រើវត្ថុគ្របដីជានិច្ចដើម្បីរក្សាសំណើមក្នុងដី ឱ្យឫសមៀន អាចស្រូបយកជីជាតិបានក្នុងកម្រិតខ្ពស់ ។

## ៦-៤ ការកំចាត់ស្មៅចង្រៃពីចម្ការមៀន

ក្នុងខណៈពេលដែលដើមមៀន នៅមានទំហំតូចនៅឡើយ មានស្មៅដុះដណ្តើមជីជាតិក្នុងចំការច្រើន ជាពិសេសក្នុងខណៈពេលមៀនមានអាយុពី ១ដល់៣ ឆ្នាំ ជាអំឡុងពេលស្មៅកំពុងមានមានការថយចុះជាបណ្តើរៗ នៅពេលដើមមៀនមានទំហំធំ ពីព្រោះម្លប់មៀនធ្វើឱ្យរុក្ខជាតិចង្រៃមិនអាចទទួលពន្លឺគ្រប់គ្រាន់ សម្រាប់ធ្វើរស្មីសំយោគដើម្បីផ្គត់ផ្គង់ការីកលូតលាស់បាន។ រុក្ខជាតិចង្រៃ គឺជាសត្រូវដ៏សំខាន់ដែលមានការពាក់ព័ន្ធក្នុងការលូតលាស់ និងការផ្តល់ទិន្នផលរបស់មៀន ព្រោះថាស្មៅចង្រៃ ជាអ្នកប្រជែង ដណ្តើមទឹក និងសារធាតុចិញ្ចឹមពីដំណាំធ្វើឱ្យពន្លឺថ្ងៃចូលមិនដល់គល់ ជាជម្រកសត្វល្អិតចង្រៃ ធ្វើឱ្យកើតជម្ងឺ និងបង្ករោគផ្សេងៗបានដោយងាយ ដែលជាហេតុហើយធ្វើឱ្យកសិករខាតបង់ប្រាក់កាស ព្រមទាំងកម្លាំងពលកម្ម ក្នុងការកំចាត់ទៀតផង ។ ការកំចាត់ រុក្ខជាតិចង្រៃនៅក្នុងចំការមៀន ត្រូវធ្វើចន្លោះពេលដែលមៀននៅមានទំហំតូចនៅឡើយ ដោយធ្វើការកំចាត់ជាបន្តបន្ទាប់ តាំងពីចាប់ផ្តើមដាំ។ តែទោះជាយ៉ាងណាក៏ដោយ ការកំចាត់ស្មៅ ឬរុក្ខជាតិចង្រៃឱ្យអស់តែម្តងក៏មិនសូវល្អដែរ គួរឱ្យមានសល់ខ្លះដើម្បីជួយទប់ដីមិនឱ្យហូរច្រោះ រួមទាំងជួយការពារ ការហួតទឹកបានផងដែរតែស្មៅឬរុក្ខជាតិដែលទុកនេះត្រូវកាត់ឱ្យនៅខ្លីជានិច្ច ។

ការកំចាត់ស្មៅក្នុងចំការមៀនអាចធ្វើបានច្រើនយ៉ាងច្រើនវិធី ដូចជា ការជំរះដោយចបការភ្ជួរ ការកាត់ដោយម៉ាស៊ីនកាត់ស្មៅ ការប្រើវត្ថុគ្របដី ការដាំរុក្ខជាតិគ្របដី ការដាំដំណាំបន្ថែមនិងការប្រើប្រាស់សារធាតុគីមី ចំណែក ការកំចាត់រុក្ខជាតិវល្លិ៍នៅក្នុងចំការផ្អែកតាមវិធីណានោះអាស្រ័យជាមួយភាពសមស្រប ការត្រៀមជាស្រេច និងភាពងាយស្រួលរបស់កសិករម្នាក់ៗ សម្រាប់វិធីកំចាត់រុក្ខជាតិចង្រៃ នៅក្នុងចំការមៀន ដែលកសិករ អ្នកចំការ និយមមានច្រើនវិធីដូចជា ៖

ការកម្ចាត់ដោយវិធីគាស់រំលើង ៖ ជាវិធីកំចាត់វល្លិ៍និងស្មៅចង្រៃដែលធ្វើដោយខ្លួនឯងជាទូទៅ វិធីកសិករនិយមនាំគ្នាធ្វើជាយូរមកហើយ ការយកស្មៅមកគ្របក្នុងបរិវេណគល់មៀនការប្រើដែជក ការភ្ជួរប្រៃរវាងជួរដាំ ក្នុងខណៈពេលដែលដើមមៀននៅតូច ការជីកគាស់ជម្រុះការកាត់ ការកាប់ឆ្ការហើយរួមទាំងការគ្របរុក្ខជាតិវល្លិ៍ គឺជាវិធីងាយៗ មិនមានសារធាតុគីមីដក់ជាប់នៅក្នុងដី ហើយអាចរក្សាបាននូវវត្ថុមានពពួកសត្វជាកងការពារមិនទាក់ទ្រៃ។ វិធីទាំងអស់នេះជាធម្មតាគេធ្វើមួយឆ្នាំ ២ទៅ៣ ដង ក្នុងចន្លោះពេលដើមរដូវ និងចុងរដូវភ្លៀង អាស្រ័យលើបរិមាណរបស់រុក្ខជាតិវល្លិ៍ និងស្មៅនៅក្នុងចំការ។ ការកំចាត់ស្មៅចង្រៃដោយវិធីទាំងនេះ បើយើងប្រៀបធៀប ជាមួយវិធីផ្សេង អាចចាត់ទុកថាជាវិធីដែលទទួលបានផលពិតប្រាកដ តែត្រូវប្រើកម្លាំងពលកម្មច្រើន ត្រូវធ្វើញឹកញយ ឬច្រើដង ទើបបានផលសមស្រប ជាមួយការធ្វើចំការមៀនដែលមានផ្ទៃដីមធ្យម ការកំចាត់ស្មៅចង្រៃដោយវិធីនេះគេនិយមប្រើការកំចាត់ស្មៅចង្រៃ នៅបរិវេណក្រោមមែក

ចំណែកបរិវេណក្រៅមែកគេប្រើ ត្រាក់ទ័រកាត់ស្មៅ ឬ ម៉ាស៊ីនកាត់ស្មៅឱ្យខ្លីជានិច្ច ហើយនាំឱ្យកម្ទេចកម្ទីស្មៅមាននៅលើផ្ទៃដីច្រើន អាចគរជាគំនរទុក ហើយទុកឱ្យរលួយពុកផុយជាជីសម្រាប់ផ្តល់ឱ្យដំណាំនៅរដូវក្រោយៗទៀត ។

ការប្រើសាធាតុគីមី ៖ ថ្នាំសម្លាប់ស្មៅ ឬថ្នាំគ្រប់គ្រងស្មៅ ជាវិធីសាស្ត្រកំចាត់ ស្មៅចង្រៃដែលគេនិយមប្រើច្រើនក្នុងពេលបច្ចុប្បន្ននេះ ។ ដោយសារជាវិធីដែលបានផលឆាប់ៗ សន្សំសំចៃពេលវេលា និងពលកម្ម ធ្វើបានស្រួល ហើយមានប្រសិទ្ធភាពខ្ពស់ ពិសេសពេលគេប្រើកំចាត់ស្មៅចង្រៃក្នុងចម្ការមៀន ដែលមានទំហំធំៗ តែអ្នកប្រើត្រូវមានចំណេះដឹង និងការយល់ច្បាស់ ពីវិធីសាស្ត្រប្រើ និងជ្រើសរើស សាធាតុគីមីឱ្យបានត្រឹមត្រូវ និងសមស្របជាមួយវល្លិ៍ និងស្មៅ ដែលត្រូវកំចាត់ មិនធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់របស់មៀន។ត្រូវនឹកគិតដល់ភាពមហន្តរាយរបស់អ្នកប្រើ និងផលប្រយោជន៍រួម គួរប្រើក្នុងអាត្រាកំហាប់ទាប។ ប៉ុន្តែជាការគួរមិនត្រូវកំចាត់ស្មៅចង្រៃឱ្យអស់ពេកទេ គេត្រូវឱ្យស្មៅនៅមានខ្លះ ដើម្បីរក្សាសំណើមក្នុងដី និងបញ្ចៀសការហូរច្រោះ។ សម្រាប់សាធាតុគីមីដែលគេប្រើដើម្បីកំចាត់ស្មៅចង្រៃមានប្រើទូទៅដូចជា ៖

ក. គ្រៃហ្វូតសេប ៖ មានឈ្មោះពាណិជ្ជកម្មដូចជា រ៉ានអាប សៈប៉ាកថាត់ដាវ សិនលីតប្រេស អាប់ដានអេកហ្វេសឃីរអាប ស៊្រីអាប់ ៤៨ ផេន អាប់ ។ល។ ជាសារធាតុគីមីកំចាត់រុក្ខជាតិ និងស្មៅចង្រៃ ប្រភេទបឺតជ្រាប ប្រើកំចាត់ស្មៅចង្រៃទាំងស្មៅស្លឹកតូច និងស្មៅស្លឹកធំ រួមទាំងវល្លិ៍ជាច្រើនប្រភេទ ដោយសារគ្រៃហ្វូតសេប ជាសាធាតុគីមីជាប្រភេទថ្នាំជ្រាបទៅផ្នែកបណ្តុលបំផ្លាញគ្រប់ផ្នែក របស់រុក្ខជាតិ សមស្របក្នុងការកំចាត់ស្បូវ និងវល្លិ៍គ្រប់ប្រភេទ ក៏ប៉ុន្តែចំពោះប្រភេទវល្លិ៍នេះ នឹងទទួលបានលទ្ធផលក្រោយពីបាញ់រយៈពេលប្រមាណ ២-៣ សប្តាហ៍បរិមាណទឹកត្រូវប្រើក្នុងការលាយជាមួយថ្នាំបាញ់លើផ្ទៃដី ១ រ៉ៃ ឬ ១៦០០ ម២ គឺ ពី៦០ ទៅ៨០ លីត្រ ក្នុងអាត្រាថ្នាំ គ្លៃហ្វូសេដ ៤៨% SL ឬ ពី៥០០ ទៅ ៦០០ ml សម្រាប់ចន្លោះពេលហើយនឹងចំនួនដងត្រូវប្រើ អាស្រ័យទៅតាមបរិមាណស្មៅចង្រៃ ក្នុងចំការ ក្រោយពីបាញ់រួចថ្នាំគ្រៃហ្វូតសេប ត្រូវមានការជៀសវាង ឬមិនត្រូវមានការប៉ះពាល់ទឹកស្រោចស្រព ឬ ទឹកភ្លៀងក្នុងចន្លោះពេលប្រមាណពី៦ ទៅ ៨ម៉ោង ។

- ការដាំដំណាំគម្របដី ក្នុងចន្លោះដែលដើមមៀននៅមានទម្រង់មែកមិនសូវធំប៉ុន្មានបើសិនមិនមានការដាំដំណាំបន្ថែមក្នុងចន្លោះជួរមៀន គួរត្រូវដាំគម្របដីចោល រុក្ខជាតិគម្របដីដែលគេនិយមដាំគឺ រុក្ខជាតិអំបូរសណ្តែក ដូចជា សណ្តែកបាយ សណ្តែកទ្រើង សណ្តែកធូន់ សណ្តែកអង្គុយ សណ្តែកអាចម៍កណ្តុរ សណ្តែកខ្មៅ សណ្តែកខ្មោចជាដើម ដោយយកគ្រាប់មកបាច ក្នុងបរិវេណចន្លោះជួរនៃដើម នៅចន្លោះរដូវភ្លៀង។ ដំណាំគម្របដី អាចបង្អាក់ការលូតលាស់របស់ស្មៅចង្រៃដោយអាចឱ្យស្មៅឬវល្លិ៍មិនអាចទទួលបានពន្លឺគ្រប់គ្រាន់ ក្នុងការធ្វើរស្មីសំយោគ នៅទីបំផុតវល្លិ៍ស្មៅចង្រៃទាំងនោះក៏ត្រូវងាប់អស់ តែក៏ត្រូវមានការប្រុងប្រយ័ត្ន កុំឱ្យដំណាំគម្របដីឡើងទៅគ្របដើមមៀន បរិវេណគល់ពិសេសបរិវេណទម្រង់មែក ត្រូវកាត់ទ្រួសត្រាយ ជាប្រចាំ ព្រោះអាចធ្វើឱ្យដើមមៀនលូតលាស់យឺត ឬ អាចងាប់ ។ ការដាំដំណាំគ្របដីដោយ ប្រើរុក្ខជាតិអំបូរសណ្តែក ក្រៅពីការគ្រប់គ្រងស្មៅចង្រៃ នៅបានជួយបន្ថែមសារធាតុចិញ្ចឹមឱ្យដី ព្រោះនៅលើដើមសណ្តែក សម្បូរទៅដោយសារធាតុអាសូត ដែលជួយកែប្រែគុណភាពដី ជួយឱ្យដីធូ រក្សាសំណើមឱ្យដី ស្លឹកដំណាំគម្របដី ដែលជ្រុះ ត្រូវបានបម្លែងជាជីតាមរយៈពពួកមីក្រូសរីរាង្គ ការពារការហូរច្រោះដែលជាហេតុធ្វើឱ្យបាត់បង់ដី សម្រាប់ដីស្រទាប់លើ ឬដីដែលបានដាក់បន្ថែមដល់ដី ។ ការដាំរុក្ខជាតិគម្របដីលើផ្ទៃដីរាបពេកអាចធ្វើឱ្យមានបញ្ហាជាមួយប្រព័ន្ធឫសរបស់មៀន ធ្វើឱ្យមៀនមានការលូតលាស់យឺត ដូចនេះក្នុងផ្ទៃដីរាប ត្រូវដាំរុក្ខជាតិគម្របដីឱ្យ ឆ្ងាយពីទម្រង់មែកមៀនយ៉ាងតិច ២ ម៉ែត្រ ។

- ការកំចាត់ដោយវិធីជម្រុះ ក្នុងពេលបច្ចុប្បន្នអាចចាត់ទុកថា ជាវិធីកំចាត់ស្មៅចង្រៃមានលក្ខណៈសមស្របបំផុត ដោយសារការកំចាត់ស្មៅចង្រៃក្នុងចំការមៀន បើប្រើតែមួយវិធី គឺមិនអាចកំចាត់ស្មៅចង្រៃឱ្យអស់បានទេ ការចាត់ចែងប្រព័ន្ធគ្រប់គ្រងបានត្រឹមត្រូវ ហើយមានលក្ខណៈសមស្របទើបចាំបាច់ត្រូវជ្រើសរើសឱ្យបានច្រើនវិធី ដើម្បីអនុវត្តចម្រុះគ្នា ដោយឡែកការប្រើសារធាតុគីមីសម្រាប់កម្ចាត់ជាប្រចាំមិនមែនជាវិធីគួរធ្វើឡើយ ពីព្រោះក្រៅពីមិនសេសសល់ស្មៅចង្រៃដែលអាចការពារស្រទាប់ដី គឺថែមទាំងបានផ្តល់លទ្ធផល

មិនល្អដល់សុខភាពរបស់កសិករខ្លួនឯងផងដែរ ដែលបានចូលទៅប្រកបការងារ និងជាពិសេសចំពោះសត្វចិញ្ចឹម ដូចនេះគួរប្រើសារធាតុគីមី កំចាត់សមាសធាតុចង្រៃ ចំពោះតែបរិវេណក្រោមទម្រង់មែកនិងបរិវេណគល់ដើមមៀនចំណែកផ្ទៃដីចន្លោះដើម និងចន្លោះជួរ ត្រូវប្រើម៉ាស៊ីនកាត់ស្មៅ ឬដាំដំណាំបន្ថែម ការដាំដំណាំគ្របដីគួបផ្សំជាមួយការប្រើប្រាស់សារធាតុគីមីក៏អាចចាត់ទុកថា ជាវិធីកំចាត់សមាសភាពចង្រៃដែលទទួលបានលទ្ធផលល្អ ។ តែទោះជាយ៉ាងណាក៏ដោយ ការចាត់ចែងប្រព័ន្ធគ្រប់គ្រងស្មៅចង្រៃ ដែលមានប្រសិទ្ធភាពនោះ ត្រូវគិតដល់សភាពផ្ទៃដី ប្រភេទដំណាំ ធនធានធម្មជាតិនៅក្នុងដី រហូតដល់សភាវៈ ទីផ្សារ អ្នកបរិភោគទៀតផង ទាំងអស់នេះ ដើម្បីឱ្យតម្លៃ ចំណាយទាបបំផុត ហើយទទួលបានទិន្នផលខ្ពស់។

## ៦.៥ ការកាត់តែងមែកមៀន

ការកាត់តែងមែកធ្វើឡើងក្នុងគោលបំណង ដើម្បីរក្សាទម្រង់មែកដែលមានលទ្ធភាពផ្ដល់ផ្កា ផ្លែច្រើន ការកាត់តែងមែកនេះ មានសារៈសំខាន់ណាស់ និងជាការចាំបាច់បំផុត ព្រោះអាចពាក់ពន្ធ័ដល់ការរីកលូតលាស់ ហើយនឹងការចេញផ្កា កាន់ផ្លែជាចំណុចសំខាន់បំផុត ។ ការកាត់តែងមែក ធ្វើឱ្យដើមមៀនរឹងមាំ ចេញផ្កា កាន់ផ្លែល្អ ហើយមានគុណភាព ។ ការកាត់តែងមែកមៀន ត្រូវចាប់ផ្ដើមអនុវត្ត ពីដាំ រហូតដល់ដើមមៀនងាប់ ។

### ផលប្រយោជន៍ក្នុងការកាត់តែងមែក ៖

- ធ្វើឱ្យទម្រង់មែកសមតាមសេចក្ដីត្រូវការ ដើមមានទំហំធំទម្រង់មែកមិនប៉ះគ្នាដែលនឹងផ្ដល់ផលល្អដល់ការចេញផ្កា កាន់ផ្លែ ធ្វើឱ្យមៀនចេញផ្កា ផ្លែបានរាល់ឆ្នាំ ដោយសារស្លឹកមៀនបានទទួលពន្លឺថ្ងៃ ពេញលេញ ងាយស្រួលក្នុងការធ្វើសំយោគរបស់ស្លឹក ជាពិសេសងាយស្រួលក្នុងការចូលទៅអនុវត្តន៍ កិច្ចការផ្សេងៗនៅក្នុងចំការដូចជា ការផ្ដល់ទឹក ដាក់ជី កាត់ស្មៅ ការបាញ់ថ្នាំការពារសត្វល្អិត និងប្រមូលផលជាដើម ។
- ការកាត់តែងមែក ដើម្បីធ្វើឱ្យដើមរឹងមាំ ត្រូវធ្វើការកាត់តែងមែក តាំងពីដើមនៅមានទំហំតូច ដើម្បីអាចរក្សាភាពរឹងមាំនៃដើមបានយូរអង្វែងសារធាតុបម្រុងដែលបានពីស្លឹកមិនត្រូវបាននាំយកទៅចិញ្ចឹមមែកដែលមិនមានប្រយោជន៍ ធ្វើឱ្យសារធាតុចិញ្ចឹមក្នុងមែក អាចជួយឱ្យមៀនចេញផ្កា កាន់ផ្លែបានច្រើន។
- ធ្វើឱ្យទម្រង់មែកក្រពុំ អាចទទួលពន្លឺថ្ងៃបានពេញលេញ ជួយឱ្យស្លឹកមៀន អាចធ្វើរស្មីសំយោគបានយ៉ាងល្អ មានខ្យល់អាកាសចេញចូលគ្រប់គ្រាន់ បំបាត់បាននូវជម្រកសត្វល្អិតនិងជំងឺ។
- កាត់បន្ថយការខូចខាតពីហេតុផលផ្សេងៗដូចជា បន្ថយការដួលរលំ និងរបេហកមែកពីខ្យល់ព្យុះ ឬភ្លៀងធ្លាក់ខ្លាំងពីព្រោះដើមមៀន បើទុកមែកឱ្យនៅទ្រុបរុបពេល ងាយទទួលរងកម្លាំងខ្យល់ដែលជាហេតុធ្វើឱ្យងាយបាក់មែក តែបើយើងកាត់តែងមែក ទម្រង់មែកក្រពុំ មិនសូវទាក់មុខខ្យល់អាចបញ្ចៀសបានពីការខូចខាតដោយខ្យល់ព្យុះក្នុងកម្រិតខ្ពស់។
- កាត់បន្ថយការរាតត្បាតពីពពួកសត្វល្អិតចង្រៃ និងជំងឺ ធ្វើឱ្យពន្លឺថ្ងៃចាំងចូលទៅក្នុងទម្រង់មែកបានគ្រប់គ្រាន់ មានខ្យល់អាកាស ចេញចូលបានល្អងាយស្រួលគ្រប់គ្រងកត្តាចង្រៃ។
- ជួយបន្ថែមគុណភាពផ្លែ ដោយហេតុថា ការកាត់តែងមែក ធ្វើឱ្យផ្លែត្រូវបានពង្រាយនៅគ្រប់បរិវេណដើម មិនមានលក្ខណៈប្រមូលផ្ដុំ ហើយការដែលទំរង់មែកក្រពុំ ស្លឹកមានលទ្ធភាពទទួលពន្លឺបានគ្រប់គ្រាន់ ស្លឹកមិនបញ្ច្រៀតគ្នាខ្លាំង អាចធ្វើរស្មីសំយោគ ចាប់យកសារធាតុចិញ្ចឹមបានច្រើនសម្រាប់ចិញ្ចឹមសរីរាង្គ ធ្វើឱ្យផ្លែមានគុណភាពល្អទាំងទំហំ និងរសជាតិ ។ ក្រៅពីនេះ ការកាត់តែងមែកនៅជួយឱ្យដើមមៀន មានអាយុវែងផងដែរ ។

### សម្ភារ និងឧបករណ៍សំរាប់ប្រើក្នុងការកាត់តែងមែក

មុននឹងធ្វើការកាត់តែងមែក គ្រប់ពេលត្រូវត្រៀមសម្ភារ ហើយនឹងឧបករណ៍គ្រប់ប្រភេទទុកជាស្រេច ដែលមានដូចតទៅ ៖

- កន្ត្រៃ ជាទូទៅដំណាំមៀន គឺជាប្រភេទដំណាំដែលមានមែក រឹងមាំ ដូច្នេះការកាត់តែងមែក គួរប្រើកន្ត្រៃដែលមានមុខស្តើង មួយផ្នែក និងមានមុខងរ មួយផ្នែក ដោយផ្នែកស្តើងសម្រាប់កាត់មែក ចំណែកផ្នែកមុខងរ សម្រាប់ទាញមែក កន្ត្រៃត្រូវមុតហើយស្អាត មិនមានស្នឹម ឬច្រេះរីឯការចាប់កន្ត្រៃ គួរចាប់ឱ្យផ្នែកមុខកាំបិត នៅផ្នែកមេដៃ ពេលកាត់ឱ្យយកផ្នែកងរ

របស់មុខកាំបិតចូលរកផ្នែកដើម ឬមែក ធ្វើបែបនេះធ្វើឱ្យស្នាមដែលត្រូវកាត់ជិតដើម និងមែកបំផុត ។ ទំហំមែកដែលសមស្រប ក្នុងការកាត់ដោយកន្ត្រៃ គឺជាមែកដែលមានទំហំមុខកាត់មិនលើសពីកន្លះនីវបើសិនជាមែកធំជាងនេះគួរប្រើរណារកាត់ ។

- រណា ត្រូវមានលក្ខណៈជារណារខ្នាតតូច មានធ្មេញល្អិត ទើបពេលអារមុតល្អ រណាអាចជារណារដងឈើ ដងជ័រប្លាស្ទិក និងប្រភេទជារណារបត់បាន ប្រភេទរណារដែលបត់បានគឺជាប្រភេទដែលមានតម្លៃថ្លៃ មុខរបស់រណារគួរកុំឱ្យមានស្នឹម ច្រេះកាន់ ហើយត្រូវមុត មែកដែលត្រូវកាត់តែង ត្រូវមានទំហំមុខកាត់ចាប់តាំងពី ០,៥-៤ នីវ រហូតដល់ធំជាង ៤ នីវ ក៏ប៉ុន្តែចំពោះមែកដែលមានទំហំធំជាង ៤ នីវ ត្រូវប្រើរណារធ្មុជំនួស គឺមិនប្រើកន្ត្រៃទេ។

- ជណ្ដើរ ក្នុងការកាត់តែងមែកមៀន នៅពេលខ្លះចាំបាច់ត្រូវប្រើជណ្ដើរជួយ ដើម្បីងាយស្រួលក្នុងការអនុវត្តការងារ ជណ្ដើរ គួរមានជើងទប់សម្រាប់ឡើង ទៅឈរកាត់តែងបរិវេណចុងមែក ដែលជាមែកតូចៗ មិនអាចធានាទ្រទម្ងន់មនុស្សបាន ជណ្ដើរអាចជាជណ្ដើរឈើ ឬដែកក៏បាន។ ចំណែកវត្ថុដែលប្រើធ្វើជណ្ដើរគួរ មានទម្ងន់ស្រាល តែរឹងមាំ អាចធានាទម្ងន់សង្កត់ ហើយងាយស្រួលក្នុងការលើកដាក់ផ្លាស់ប្ដូរទីកន្លែង ។

- ថ្នាំលាបស្នាមកាត់ ក្រោយពីការកាត់តែងមែកមករួចហើយ ត្រូវធ្វើការព្យាបាលស្នាមដោយការប្រើថ្នាំការពារមេរោគលាយទឹក ហើយលាបនៅបរិវេណស្នាមកាត់ ដើម្បីការពារមេរោគចូលបំផ្លាញស្នាមមុខកាត់ និងជួយឱ្យស្នាមកាត់បិទជិតបានឆាប់ ។ ក្រៅពីថ្នាំការពារមេរោគយើងក៏អាចប្រើប្រេងម៉ាស៊ីនខ្មៅថ្នាំលាបជ័រ កាកសំណល់ប្រេងម៉ាស៊ូត ឬកំបោរក្រហម (ហូបម្លូ)ក៏បាន ហើយកំបោរក្រហមនេះតម្លៃថោកបំផុត ។

### ការកាត់តែងមែក ដើម្បីបង្កើតទម្រង់មែក

ត្រូវចាប់ផ្ដើមធ្វើចាប់តាំងពីពេលសាកមែក (ក្រៀវ) ផ្សាំ ឬដាំ រហូតដល់ពេលផ្ដល់ផ្លែផ្កាត្រូវធ្វើជាបន្ទាន់ នៅពេលសង្កេតឃើញមានមែកខុសប្រក្រតី ការកាត់តែងមែកក្នុងខណៈពេលនេះ ក៏ដើម្បីរក្សាបានទម្រង់ម្លប់មែក បានសមស្របនៅពេលមៀនធំ។ សម្រាប់ការកាត់តែងមែកពូជ មុនយកមកដាំដូចជាមែកពូជដែល មានមែកធាងសាខាច្រើនពេក ឬមានមេរោគ និងសត្វល្អិតរាតត្បាត ត្រូវកាត់ចោល ដោយទុកតែមែកណាដែលចាំបាច់ ព្រោះថាបើ ទុកមែកធាងច្រើនពេកពេលយកទៅដាំ នាំឱ្យដើមពូជមិនងាយនឹងតាំងជំហរបាន (យឺត) ហើយអាចគ្រេះឬក្រិន មានការលូតលាស់យឺត ។ ការកាត់តែងមែកដើម្បីបានទម្រង់មែកនេះ ប្រជាកសិករ អ្នកចម្ការខ្លះ ហាក់មិនមានការចាប់អារម្មណ៍ ដោយបណ្ដោតបណ្ដោយ ឱ្យដើមមៀនលូតលាស់ទៅតាមធម្មជាតិ មិនមានការកាត់តែង ឬទៅកាត់តែងពេលដើមមៀនធំទៅវិញ តែបច្ចុប្បន្ន ប្រជាកសិករ អ្នកចម្ការកំពុងមានការចាប់អារម្មណ៍ និងបានអនុវត្តច្រើនហើយដែរ ដោយសារការមើលឃើញពីការខុសប្លែកគ្នារវាងការកាត់តែងមែក និងការបណ្ដោតបណ្ដោយឱ្យមៀនលូតលាស់តាមធម្មជាតិ ។ ម្យ៉ាងទៀតការមិនកាត់តែងមែក បានផ្ដល់នូវផលលំបាកច្រើនដូចជា ទម្រង់មែកខ្ពស់ធំហួសពេកបែកមែកធាងសាខាយ៉ាងច្រើន ទម្រង់ម្លប់មែកមិនស្របតាមតម្រូវការ អាច





មានការលូតលាស់តែមួយផ្នែក ងាយដួលរលំពេលមានខ្យល់ ឬភ្លៀងធ្លាក់ខ្លាំង មែកធាងងាយរហែក ពេលមានកម្លាំងសង្កត់មែក ពិសេសធ្វើឱ្យផ្លែតូច និងមិនសូវមានគុណភាព ។

ការកាត់តែងមែក ដើម្បីបានទម្រង់ម្លប់មែកនេះ មុននឹងធ្វើការកាត់តែង ត្រូវមានការគិតទុកជាមុន ថាតើត្រូវកំណត់ទម្រង់ដើមខ្ពស់ ឬទាបប៉ុណ្ណា និងត្រូវទុកប៉ុន្មានមែក តែសម្រាប់ចំនួនមែកដែលត្រូវទុកនោះ តែងមានខុសផ្លែកគ្នា អាស្រ័យតាមទម្រង់ដើម និងលក្ខណៈរបស់មែកពូជដែលនាំយកមកដាំ មែកដែលទុក គួរស្ថិតនៅក្នុងសភាពសមរម្យ ហើយឃ្លាតគ្នាសមស្របក្នុងការកាត់តែងមែកមៀនដើម្បីបានទម្រង់មែកស្របតាមលក្ខណៈទម្រង់ម្លប់មែកក្រពុំត្រូវមានមែកបែកពីដើមមិនច្រើនមែកត្រូវធ្វើឱ្យស្របមុំទូលាយដោយពង្រាយជុំវិញទម្រង់ដើម ហើយមិនត្រូវមានកំពូលទេ ។

មៀនដែលដាំដោយមែកសាក ចាំបាច់ត្រូវតែកាត់តែងមែកដើម្បីបានទម្រង់មែកតាំងពីនាំយកមែកសាកទៅផ្សាំដោយកាត់ទុកតែមែកត្រង់ វែងបំផុតតែមួយមែក ក្រោយពីដាំហើយ ទុកចោលឱ្យដើមខ្ពស់ប្រមាណ ១ ដល់ ១,២០ ម៉ែត្រ ទើបធ្វើការក្តិចត្រួយមៀនចេញ ដើម្បីឱ្យដើមមៀនបែកមែកខាងចេញមកឱ្យសមល្មមវិញ ហើយត្រូវរើសយកមែកដែលថ្លោស ហើយខ្ពស់ពីដីប្រមាណ ៥០ ស.ម ទុក ៣ ទៅ ៤ មែក ។ គោលការណ៍ក្នុងការជ្រើសរើសមែក ត្រូវទុក គួរនៅព័ទ្ធជុំវិញដើម ដោយឱ្យឃ្លាតពីគ្នាប្រមាណ ២០ ទៅ ៤០ នីវ ពេលជ្រើសរើសមែក ដែលត្រូវទុកជាទម្រង់ដើមបានពី ៣- ៤ មែកតាមតម្រូវការ ហើយបើមានមែកផ្សេងនៅ ត្រូវកាត់ចោលទាំងអស់ ជាពិសេសផ្នែក ត្រួយដែលបែកចេញមក ជាកញ្ចុំត្រូវកាត់ចោលឱ្យអស់ ដើម្បីឱ្យមែកដែលនៅសល់ មានឱកាសទម្លាយចេញជាមុំទូលាយជាមួយដើម ហើយអាចប្រើឈើតូចៗសម្រាប់ទល់មែកជំនួយៗ ឱ្យស្របទៅតាមទិស និងទល់មែកផ្សេងៗ ទៀតក៏បាន ពេលមែកគោល ៣ ទៅ៤ មែក បែកត្រួយចេញមកប្រវែង ១០ ស.ម ទើបកាត់ត្រួយ មែកគោលត្រឹមតែ ៦ស.ម ក្រោយបន្ទាប់មក មែកគោលចាប់ផ្តើមបែកមែកខ្នែងចេញមកច្រើន ត្រូវជ្រើសរើសមែក ខ្នែងនេះទុកត្រឹមតែ២មែក ដោយជ្រើសរើសមែកដែលមានមុំទូលាយ ចំណែកមែកដែលមានមុំចង្អៀត ឬមែកដែលមិនបានបែកពន្លកចេញពីទម្រង់មែកត្រូវកាត់ចោល ពេលមែកខ្នែងនេះ លូតចេញវែងពេក ក៏ត្រូវធ្វើការកាត់ត្រួយម្តងទៀត ប្រវែង៦ ស.ម ពេលបែកខ្នែងទើបជ្រើសរើសទុកតែ២ ខ្នែង ពេលនោះក៏បានមែករាយបែកចេញក្រៅទម្រង់រួម ២៤ មែករយ ឬ ៣២ មែករាយ តែត្រូវទុកឱ្យគ្រប់មែកលូតលាស់ទៅតាមធម្មជាតិ ។

ក្រោយពីនោះត្រូវឧស្សាហ៍សង្កេតមែកគោលទាំង ៣ ឬ ៤មែក បែកចេញត្រង់ពីដើម ដោយបានទម្លាយចេញ ទៅតាមគោលដៅឬនៅ ទើបកាត់ត្រួយលើបំផុត ដែលបែកជាកញ្ចុំ ដោយកាត់ឱ្យគៀកជាមួយគល់មែកគោល ដែលនៅលើបំផុតចុងក្រោយក៏នឹងបានដើមមៀនមួយដើម មានមែកគោល ៣ ទៅ ៤មែក ហើយព្រមជាមួយមែកខ្នែងរាយ ២៤-៣២ មែកទៀតទើបបានទម្រង់ដើម ដែលសំបូរបែបគឺមានមែកធាងដែលសមស្រប គល់ដើមទូលាយ ទម្រង់ម្លប់មែកទាបក្រពុំ កន្លាក់ជំពាមមែកផ្សេងៗ ស្ងួត មិនទ្រុបរុប ជាហេតុនាំឱ្យមេរោគអាចជ្រាតចូលបំផ្លាញដំណាំបានអាចផ្តល់ផលជាប្រចាំគ្រប់ៗដើម។ ការកាត់តែងមែកដើម្បីសាងទម្រង់មែកនេះ អាចរួចរាល់នៅឆ្នាំទី ៣ ឬ ទី៤ ។ មៀនដែលសាងទម្រង់មែក នៅទំហំតូចតែងតែរឹងមាំជាងដើមដែលមិនបានកាត់តែងសាងទម្រង់មែកនៅទំហំធំ តែការថែទាំមែកបែបនេះ បើសិនជាមិនមានការទល់មែកឱ្យបានល្អទេ ឱកាសនៃការរហែកមែក ឬបាក់មែកស្ថិតក្នុងអត្រាខ្ពស់ ។



## ៦.៦. ការតែងមែកក្រោយពេលប្រមូលផល

ជាការកាត់តែងមែកមៀន ដែលបានផ្តល់ផលរួចហើយ កិច្ចការនេះប្រជាកសិករជាអ្នកចម្ការចាំបាច់ត្រូវធ្វើជាប្រចាំ។ មុនធ្វើការកាត់តែងមែក បើសង្កេតឃើញថាមានអង្រ្កងច្រើន គួរមានការកចាត់ដោយធ្វើការបាញ់ថ្នាំសម្លាប់សត្វល្អិតជាមុន

សិន ដើម្បីងាយស្រួលក្នុងការអនុវត្តការងារ ដោយផ្តើមចេញពីមែកដែលស្ថិតនៅក្រោមបំផុត ហើយដេញទៅមែកលើៗជាបន្តបន្ទាប់ដែលមែកនីមួយៗផ្តើមកាត់តែងពីបរិវេណគល់មែកទៅចុងមែករហូតគ្រប់មែក ខណៈពេលក្រោយការកាត់តែងមែក ត្រូវធ្វើការថែទាំដើមមៀន ដោយធ្វើយ៉ាងណាឱ្យដើមមៀនចាប់ផ្តើមលូតលាស់និងផ្តល់ផ្លែផ្កាដូចរដូវមុនៗ។ ការកាត់តែងមែក ក្រោយការប្រមូលផលនេះ គួរកាត់មែកណាដែលបាក់មុន ចំពោះមែកណាដែលមិនមានផ្លែផ្កាទេ ត្រូវកាត់ចោលត្រឹមគល់មែកតែម្តង ចំណែកមែកសម្រាប់ឱ្យបែកត្រួយថ្មី ដើម្បីចេញផ្លែត្រូវឱ្យនៅសល់វែងៗ មែកបន្តដែលត្រូវកាត់គឺ មែកដែលមិនធំធាត់ រឹងមាំ មែកនៅក្នុងម្លប់ទម្រង់ដើមមិនរីកលូតលាស់មកក្រៅ ទម្រង់មែករលយខ្លាំង មែកដែលមានរោគ និងសត្វល្អិតចូលបំផ្លាញ មែកស្ងិតងាប់ មែកដែលប្រេះជាំ មែកដែលទើសទែងគ្នា និងមែកដែលចង្អៀតជាដើម ដោយកាត់ឱ្យគល់មែក ឬគល់ដើមមិនឱ្យមានសល់បន្ត។ ត្រូវប្រុងប្រយ័ត្នក្នុងការកាត់តែងមែកមៀន ធ្វើយ៉ាងណាកុំឱ្យមែកជាំ ឬរហែកច្រើនពេក សម្ភារដែលប្រើ ត្រូវសមស្របជាមួយទំហំមែក ដូចជាមែកទំហំមុខកាត់មិនលើសពីកន្លះស.ម ត្រូវប្រើកន្ត្រៃកាត់តែងមែកនោះ តែបើមែកធំជាង១,៥ស.មត្រូវប្រើរណារកាត់តែងជំនួស ព្រោះអាចធ្វើឱ្យមុខស្នាមពីការកាត់តែងស្អាត ពេលសំបកដុះចេញមកថ្មីក៏រុំព័ទ្ធមុខស្នាមជិត ក្រោយពីការកាត់តែងមែករួចហើយ ត្រូវលាបថ្នាំនៅស្នាមមុខកាត់ដោយប្រើកំបោរស កំបោរក្រហម ឬសារធាតុការពារ មេរោគ ឬផ្សិត តែទោះជាយ៉ាងណា ដើម្បីការពារការជ្រាតចូលបំផ្លាញពីពពួកមេរោគ និងសត្វល្អិត ក្រោយពីការលាបហើយ គួរត្រួតពិនិត្យមើលស្នាមមុខមួយចំនួនដែលមិនបានលាបសព្វ ត្រូវលាបឱ្យសព្វឡើងវិញ។ មៀន ដែលមានទំហំធំ ហើយអាយុច្រើនពេក បើមិនមានការកាត់តែងមែកទេ ធ្វើឱ្យដើមមានមានផ្លែតូច និងគុណភាពមិនល្អ ការកាត់តែងមែក ដើម្បីឱ្យដើមមៀនមានលទ្ធភាព បែកមែកថ្មី ជាមែកដែលអាចផ្តល់ផលបន្តទៀតច្រើនឆ្នាំ។ វិធីសាស្ត្រការកាត់តែងមែកមៀនអាយុច្រើនអាចធ្វើទៅបាន ដោយការកាត់ដើមត្រឹមកម្ពស់ពីដីប្រមាណ ១,៥ ទៅ ២ ម៉ែត្រ ។ គួររក្សាទុកមែកដែលល្អដើម្បីជួយស្រូបយកសារធាតុចិញ្ចឹមពីក្នុងដីទៅចិញ្ចឹមដងដើម១ទៅ២មែក បើមិនដូច្នោះទេ ដើមមៀន ដែលកាត់នោះ អាចមិនបែកមែក ឬអាចងាប់បាន មុនកាត់គួរលើកចង្អូរជុំវិញដើមក្រោយពីកាត់ហើយ ត្រូវដាក់ជីក្នុងចង្អូរដែលបានធ្វើ ហើយស្រោចទឹកឱ្យជោគដើម្បីឱ្យដើមបែកមែកថ្មីច្រើន ធ្វើការជ្រើសរើសមែកល្អ (ថ្លោស) ទុក ៣ ទៅ ៤ មែក ដោយជ្រើសរើសទុក មែកតាមតម្រូវការប្រកបដោយថាមពល ក្រោយពីនោះត្រូវថែរក្សា ហើយកាត់តែងមែក ដូចវិធីការកាត់តែងមែកដើម្បីសាងទម្រង់មែក ប្រមាណ ៣ ឆ្នាំ ដើមមៀននឹងផ្តល់ផលផ្លែផ្កាថ្មី ទិន្នផលដែលទទួលបានមានកម្រិតខ្ពស់ និងគុណភាពល្អ។

## ៦-៧. វិធីការពារការរហែក បាក់មែក និង ដួលរលំ

ក្នុងចន្លោះពេលដែលមៀនចេញផ្កាកាន់ផ្លែ ប្រជាកសិករអ្នកចម្ការនឹងមានជួបបញ្ហាដើមមៀនបាក់រលំ មែករហែក ឬបាក់ ធ្វើឱ្យមានការខូចខាត ដោយសារការដាំមៀនក្នុងពេលបច្ចុប្បន្ន ភាគច្រើនគេនិយមដាំដោយមែកសាកផ្សាំ ដែលមិនមាន ឫសកែវសម្រាប់ចាក់ជម្រៅចុះក្នុងដីមានតែឫសខ្នែងលូតលាស់បានតែបរិវេណរាក់ៗប៉ុណ្ណោះ។ ព្រមជាមួយនឹងមៀនបែកមែកជាងឆ្ងាយៗពីគល់ដើមមានទំរង់មែកស៊ុបទ្រុប មែក និងដើមស្រួយប្រេះដាច់ ពេលមានខ្យល់បក់ខ្លាំងធ្វើឱ្យមានការដួលរលំ រយាស់បាក់មែកបានយ៉ាងងាយ ជាពិសេសក្នុងចន្លោះពេលដែលមានការកាន់ផ្លែ ។ ម៉្យាងវិញទៀត ផ្ទៃដីដែលដាំមៀន ច្រើនតែជាដីធូរ ដីល្បាយខ្សាច់ជិតមាត់ស្ទឹង ឬទន្លេជាដីដែលមានសភាពធូរខ្លាំង ការស្អិតជាប់មានតិច ធ្វើឱ្យដើមមៀនអាចរលំដួលងាយ។ សម្រាប់វិធីសាស្ត្រក្នុងការការពារការដួលរលំ និងរហែកមែកអាចធ្វើទៅបានច្រើនយ៉ាងគឺ ៖

- ការដាំដើមឈើបាំងខ្យល់:ដោយសារតំបន់ខ្ពង់រាបនៃទឹកដីខេត្តប៉ៃលិន និងបាត់ដំបងត្រូវបានជួបប្រទះ បញ្ហាខ្យល់ព្យុះ ចាប់ពី ២ ទៅ ៣ លើកក្នុងមួយឆ្នាំៗ ដែលកើតឡើងចន្លោះរដូវភ្លៀង ក្នុងឆ្នាំនីមួយៗ ដើមមៀន ឬដើមរុក្ខជាតិ គ្មានឫសកែវមួយចំនួនត្រូវរលំដួល និងរហែកបាក់មែកដោយខ្យល់ព្យុះ ក្នុងចន្លោះពេលនេះ គឺស្រមពេលដែលដើមមៀន កំពុងមានផ្លែធំល្មមតែនៅមិនទាន់បានប្រមូលផលបាននៅឡើយ ដែលជាហេតុធ្វើឱ្យបាត់បង់ទិន្នផល មិនតិចប៉ុន្មានទេក្នុងមួយឆ្នាំៗ ។ ដូច្នេះដើម្បីការពារ ទុកជាមុន ទើបប្រជាកសិករអ្នកចម្ការ គួរដាំដើមឈើបាំងខ្យល់ ព្រមជាមួយនឹងការដាំមៀន

តែម្ដង ។ ការដែលបានដាំដើមឈើបាំងខ្យល់ទុក ដើម្បីជួយបន្ថយកម្លាំងខ្យល់ ការពារមិនឱ្យដើមមៀនដួល ព្រមនឹងការបាក់មែក ក្រៅពីនេះនៅអាចទាញយកផលប្រយោជន៍ពីដើមឈើរបាំងខ្យល់ទាំងនេះមកប្រើជាឈើជន្ទល់ និងជួយក្នុងការការពារការរំហួតសារធាតុទឹកពីស្រទាប់ដីទៅបរិយាកាសបានទៀតផង ។ ដើមឈើរបាំងខ្យល់ដែលត្រូវបាននាំយកមកដាំគួរតែជាឈើដែលមានការលូតលាស់លឿន មែកធាងតិចកម្ពស់ខ្ពស់ ធន់ជាមួយស្ថានភាពបរិស្ថាន ជាពិសេសធានាខ្យល់បានល្អ អាចជាឈើប្រភេទផ្សេងៗគ្នា ដែលរឹងមាំឬមានស្លឹកធំគួរសម ឈើបាំងខ្យល់ដែលគេនិយមដាំមានដូចជាឫស្សីពីងពុង ស្ដៅ ស្រល់ កន្ធំថេត ខ្នុរបណ្ដុះគ្រាប់ ស្វាយដើមក្រដាស ជាដើម ។ ការដាំដើមឈើរបាំងខ្យល់អាចដាំជា២ជួរឆ្លាស់គ្នា តាមជួររបង ឬព្រំដីជាដើម ហើយត្រូវដាំឈើរបាំងខ្យល់មុនដាំមៀនយ៉ាងតិចមួយឆ្នាំ ដោយដាំជុំវិញចំការ ឬទិសដែលខ្យល់បក់ខ្លាំង ដាំជួរដំបូងឱ្យឃ្លាតពីដើមមៀនប្រមាណ ៦ទៅ១០ ម៉ែត្រ អាស្រ័យតាមសភាពចំការ ការដាំត្រូវមើលទិសខ្យល់ ពិសេសខ្យល់តែងផាត់មកពីទិសខាងជើង ខាងត្បូង និងនិរតី ចន្លោះរវាងដើមឈើរបាំងខ្យល់ជាមួយដើមមៀន គួរជីកចង្អូរជម្រៅប្រមាណ១ម៉ែត្រ ដោយឱ្យចង្អូរឬប្រឡាយ ឃ្លាតពីជួរដើមឈើរបាំងខ្យល់ប្រមាណ១ម៉ែត្រ ដើម្បីការពារឫសរបស់ដើមឈើរបាំងខ្យល់ចាក់ទៅរំខាន ឬទៅដណ្ដើមសារធាតុចិញ្ចឹម ទឹកពីដើមមៀន ។

• វិធីសាស្ត្របន្ថែមឫសមៀន អាចចាត់ជាវិធីដែលអាចជួយសម្រួលមិនមានការរលំដួលពីព្រោះដើមមៀន អាចមានប្រព័ន្ធឫសកែវជ្រៅ ចាក់ចុះទៅក្នុងដីជួយរក្សាលំនឹងដើម បឺតជញ្ជក់សារធាតុចិញ្ចឹមបានច្រើន សំរាប់ផ្ដល់ឱ្យដងដើមជំរុញការផ្ដល់ទិន្នផលខ្ពស់ វិធីនេះអាចធ្វើបានដោយងាយ មិនមានភាពស្មុកស្មាញ ។ សម្រាប់បច្ចេកទេសក្នុងការបន្ថែមឫសមៀន មានដូចជា៖

- ដាំដើមមៀនដោយប្រើវិធីបន្ថែមឫស ដែលបានមកពីការបណ្ដុះគ្រាប់ទំហំប៉ុនប៊ិចដាំឱ្យគៀកជាមួយដើមពូជ ឃ្លាតគ្នាក្នុងចន្លោះប្រមាណ២០ ស.ម ដាំ ២ ទៅ ៣ ដើមជុំវិញដើមពូជល្អ។

- ពេលដើមទាំងពីរលូតលាស់ល្អហើយ ទាញក្ដោបដើមដែលបានដាំសម្រាប់យកឫស មកភ្ជាប់ជាមួយដើមពូជល្អ រួចហើយធ្វើសញ្ញាសម្គាល់ចំណុចដែលភ្ជាប់ជាមួយគ្នាទុក ។

- ចៀរសំបកដើមពូជល្អ និងដើមឫសរៀងជាចំណិតត្រសក់ ហើយចៀរដើមបន្ថែមជារូបលំពែងប្រវែងប្រមាណ ៣ ទៅ ៤ សង្ទីម៉ែត្រ ត្រូវធ្វើឱ្យចំនួនស្នាមលើដើមពូជល្អ ឱ្យត្រូវគ្នាជាមួយនឹងដើម ដែលបានដាំសម្រាប់បន្ថែមឫស ។

- យកស្នាមដានដើមពូជល្អ និងដើមពូជបន្ថែម មកភ្ជាប់គ្នា ដោយទាញដើមបន្ថែមមកភ្ជាប់ជាមួយស្នាមដាន ដើមពូជល្អ រៀបចំកោសិកាឱ្យជាប់គ្នា ហើយរុំដោយប្លាស្ទិកឱ្យណែនទុកចោលប្រមាណ ២,៥ ទៅ ៣ ខែ ពេលឃើញថាសាច់ទាំងពីរជាប់គ្នាល្អហើយ ទើបបកចង់ប្លាស្ទីកចេញ បន្ទាប់មកចាប់ផ្ដើមកាត់ចុងដើមបន្ថែម ដែលមានសាច់ស្នាមដានចេញ។ដើមមៀនមួយដើម អាចធ្វើការបន្ថែមឫស បានពី ៣ ទៅ ៥ ឫសក៏បាន ចំពោះវិធីធ្វើមានដូចជា ការប៉ាតស្នាមបរិវេណបន្ថែមឫស កុំឱ្យត្រង់គ្នា ត្រូវចិតប៉ាតលើខ្លះ ក្រោមខ្លះ នៅជុំវិញដើម ហើយដើម្បីធ្វើឱ្យការបន្ថែមឫសមៀនបានទទួលផលល្អ ចំណុចដែលសំខាន់បំផុតគឺ ត្រូវរុំប្លាស្ទីក ឬខ្សែវ៉ែរឱ្យណែនដើម្បីឱ្យសាច់ដើមពូជល្អ និងដើមឫសស្និទ្ធគ្នា។ គួរធ្វើការបន្ថែមឫសមៀនក្នុងរដូវភ្លៀង ពីព្រោះជាអំឡុងពេលដែល ដើមឈើកំពុងមានការលូតលាស់ល្អ ។

- ការទាញមែក មានទាំងការទាញ ពីខាងក្នុងដើម ហើយនឹងខាងក្រៅដើម តែភាគច្រើនគេនិយមទាញ តែពីខាងក្នុងដើម ដោយប្រើសំបកកៅស៊ូកង់ ម៉ូតូ មករុំជុំវិញមែកមៀន ហើយប្រើលួសលេខ ៨ ចងទុកគ្រប់មែក ប្រការសំខាន់ត្រូវ



បន្តទៅលេខ ៥៤

# បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

## បច្ចេកទេសចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារក្នុងស្រះក្រាលកម្រាលកៅស៊ូប្លាស្ទិក

**បន្តពីលេខ៥២** រៀបចំដោយ: នាយកដ្ឋានអភិវឌ្ឍវារីវប្បកម្ម នៃរដ្ឋបាលជលផល

### ១.ការជ្រើសរើសទីតាំងជីកស្រះចិញ្ចឹមត្រី

**គោលបំណង៖**

ជ្រើសរើសទីតាំងជីកស្រះចិញ្ចឹមត្រីអណ្តែង

- បានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីអនុវត្តទទួលបានជោគជ័យ
- និងបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង។

គួរជ្រើសរើសទីតាំងសម្រាប់ជីកស្រះចិញ្ចឹមត្រីឱ្យមានលក្ខណៈល្អសមស្របតាមបច្ចេកទេស ឬ ស្របទៅនឹងលក្ខណៈជីវសាស្ត្រប្រភេទត្រីដែលយើងចង់ចិញ្ចឹម។ ដោយឡែក ចំពោះប្រភេទត្រីអណ្តែង ដើម្បីងាយស្រួលក្នុងការចិញ្ចឹម និងទទួលបានជោគជ័យ យើងគួរតែជ្រើសរើសទីតាំងសម្រាប់ជីកស្រះឱ្យមានលក្ខណៈល្អសមស្របដោយគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោមនេះ :

- នៅជិតផ្ទះងាយស្រួលគ្រប់គ្រង ដូចជាការផ្តល់ចំណី ការគ្រប់គ្រងគុណភាពទឹក និងមើលថែទាំ តាមដានសកម្មភាព និងសុខភាពត្រី ។
- មានទីតាំងស្ថិតនៅទីវាលខ្ពស់ស្រឡះ មិនលិចទឹកនៅរដូវវស្សា ហើយមានខ្យល់ និងពន្លឺអាចចេញ-ចូលបានល្អគ្រប់គ្រាន់ ។
- ជាពិសេសបើអាចធ្វើបាន គួរជ្រើសរើសទីតាំងជីកស្រះនៅជិតប្រភពទឹក ដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្លាស់ប្តូរទឹកថ្មី ក្នុងករណីចាំបាច់ ពិសេសនៅពេលត្រីពុល និងមានជំងឺ ។ ម៉្យាងទៀត ក្នុងករណីយើងអាចធ្វើការផ្លាស់ប្តូរទឹកថ្មីបានញឹកញាប់ ជាពិសេសនៅពេលទឹកស្រះមានក្លិនស្អុយ ឬ ក្រខ្វក់ នូវកម្រិតបរិមាណទឹកពីមួយភាគបី ( ១/៣ ) ទៅពាក់កណ្តាល ( ៥០% ) នៃបរិមាណទឹកសរុបទាំងអស់ក្នុងស្រះនោះនឹងធ្វើឲ្យត្រីធំធាត់លឿន អាចជៀសផុតពីជំងឺបាន និងទទួលបានទិន្នផលត្រីខ្ពស់។ ប្រភពទឹកទាំងនេះរួមមាន: ទន្លេ បឹងបួរ ត្រពាំង ស្រះ ប្រឡាយ និងអណ្តូង ជាដើម ។ល។ ដែលជាប្រភពទឹកស្អាត និងគ្មានជាតិពុល ។



*ទីតាំងដែលមានប្រភពទឹកអាចជីកស្រះចិញ្ចឹមបាន*



*ជីកស្រះជិតផ្ទះងាយស្រួលគ្រប់គ្រង*

## ២. លក្ខណៈស្រះចិញ្ចឹមត្រី

### គោលបំណង៖

### ដើម្បីយល់ច្បាស់ពី

- ទ្រង់ទ្រាយ ឬរូបរាង និងទំហំស្រះដែលអាចចិញ្ចឹមត្រីអណ្តែងបាន
- លក្ខណៈបច្ចេកទេសនៃស្រះចិញ្ចឹមត្រីអណ្តែង
- ការរៀបចំស្រះចិញ្ចឹមត្រីអណ្តែងឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ។

ជាទូទៅស្រះចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ ដោយក្រាលកម្រាលកៅស៊ូប្លាស្ទិកមានលក្ខណៈដូចខាងក្រោមៈ

- មានរាងជាចតុកោណកែង ភាគច្រើនមានទំហំតូច អាស្រ័យដោយកសិករម្នាក់ៗដែលមានលទ្ធភាពជីក។ ទំហំស្រះទាំងនោះមានដូចខាងក្រោម៖
  - បណ្តោយ ៦ ម៉ែត្រ ទទឹង ៤ ម៉ែត្រ ជម្រៅ ១ ម៉ែត្រ = ផ្ទៃសរុប ២៤ ម៉ែត្រការ៉េ
  - បណ្តោយ ៦ ម៉ែត្រ ទទឹង ៣ ម៉ែត្រ ជម្រៅ ១ ម៉ែត្រ = ផ្ទៃសរុប ១៨ ម៉ែត្រការ៉េ
  - បណ្តោយ ៤ ម៉ែត្រ ទទឹង ២ ម៉ែត្រ ជម្រៅ ០.៨ ម៉ែត្រ= ផ្ទៃសរុប ៨ ម៉ែត្រការ៉េ
  - បណ្តោយ ៣ ម៉ែត្រ ទទឹង ២ ម៉ែត្រ ជម្រៅ ០.៨ ម៉ែត្រ= ផ្ទៃសរុប ៦ ម៉ែត្រការ៉េ។
- ស្រះចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ ដោយក្រាលកម្រាលកៅស៊ូប្លាស្ទិក មានទំហំប៉ុណ្ណា ក៏អាចចិញ្ចឹមត្រីបានដែរ អាស្រ័យទៅតាមលទ្ធភាពរបស់កសិករម្នាក់ៗ។ ជាទូទៅកសិករជីកស្រះមានទំហំប៉ុនទំហំស្រះខាងលើ ពីព្រោះងាយស្រួលរកទំហំកម្រាលកៅស៊ូប្លាស្ទិកក្រាលពីលើស្រះ
- ស្រះត្រូវរៀបចំឱ្យមានទំនប់ ឬភ្លឺស្រះ ដើម្បីទប់សង្កត់កម្រាលកៅស៊ូប្លាស្ទិកដែលក្រាលក្នុងបាតស្រះ និងការពារកុំឱ្យទឹកលិចស្រះនៅពេលមានភ្លៀងធ្លាក់ខ្លាំង។
- បើកសិករមានលទ្ធភាព គួរព័ទ្ធសំណាញ់ជុំវិញស្រះចិញ្ចឹមត្រីកាន់តែប្រសើរ ដើម្បីការពារកុំឱ្យទឹកលិចស្រះនៅពេលមានភ្លៀងធ្លាក់ខ្លាំង។
- ម្យ៉ាងទៀតត្រូវរៀបចំបង្កប់ទុយោបង្ហូរទឹកសម្រាប់បញ្ចេញបញ្ចូលទឹកពីស្រះ ជាពិសេសការពារទឹកលិចស្រះនៅពេលមានភ្លៀងធ្លាក់ខ្លាំង។





## ៣. របៀបជីកស្រះចិញ្ចឹមត្រី

### គោលបំណង៖

### ដើម្បីយល់ច្បាស់ពី

- របៀបជីកស្រះក្រាលកម្រាលកៅស៊ូប្លាស្ទីក សម្រាប់ចិញ្ចឹមត្រីអណ្តែង
- របៀបរៀបចំស្រះចិញ្ចឹមត្រី តាមលក្ខណៈបច្ចេកទេសដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ។

### ស្រះចិញ្ចឹមត្រីអណ្តែងអាចជីកបាន តាមរបៀបដូចខាងក្រោម ៖

- ដំបូងយើងត្រូវវាស់ប្រវែងបណ្តោយនិងទទឹងស្រះដែលត្រូវជីក ដោយបោះបង្គោលនៅជ្រុងទាំង ៤ នៃស្រះ រួចចងខ្សែព័ទ្ធជុំវិញ។
- បន្ទាប់មក ចាប់ផ្តើមជីកស្រះឱ្យមានជើងទេរ ដើម្បីការពារកុំឱ្យដីបាក់ធ្លាក់ពីជញ្ជាំងស្រះចូលក្នុងបាតស្រះ។
- រួចវាស់ជម្រៅបាតស្រះដែលបានជីក ឱ្យមានជម្រៅដូចនឹងជម្រៅស្រះដែលចង់ជីក។
- បន្ទាប់មកត្រូវរំលីង ឬសំអាតបាតស្រះ និងជញ្ជាំងស្រះ កុំឲ្យមានចំណាំង ឬកំទេចឈើ ឬដុំថ្ម ដើម្បីការពារកុំឱ្យធ្លាយរហែកកម្រាលកៅស៊ូប្លាស្ទីក។
- រួចចាប់ផ្តើមក្រាលកម្រាលកៅស៊ូប្លាស្ទីកពីលើស្រះដែលបានជីកហើយ ដោយយកខ្សាច់ ឬ អាចម៍ដីមកក្រាលសង្កត់ពីលើជ្រុងទាំង៤ នៃបាតស្រះដើម្បីកុំឱ្យកម្រាលកៅស៊ូប្លាស្ទីកប៉ើងពីបាតស្រះ។ រួចយកអាចម៍ដីមកសង្កត់ពីលើជ្រុងទាំង ៤នៃគែមមាត់ស្រះ ដើម្បីកុំឱ្យកម្រាលកៅស៊ូប្លាស្ទីករបើកចេញ។





*របៀបជីកស្រះ និងរៀបចំស្រះក្រាលកម្រាលកៅស៊ូប្លាស្ទីក*

## ៤. ការរៀបចំស្រះមុនពេលដាក់កូនត្រីចិញ្ចឹម

### គោលបំណង៖

### ដើម្បីទទួលបាននូវ

- ទឹកក្នុងស្រះមានគុណភាពល្អ មុនពេលដាក់កូនត្រីចិញ្ចឹម
- កូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹម
- កូនត្រីមានការលូតលាស់ល្អ។

ដើម្បីដាក់កូនត្រីចិញ្ចឹមមានអត្រារស់ច្រើន និងកូនត្រីលូតលាស់ល្អ ចាំបាច់យើងត្រូវរៀបចំស្រះឱ្យបានស្អាតល្អជាមុនសិន។ បច្ចេកទេសនៃការរៀបចំស្រះ គួរអនុវត្តដូចខាងក្រោមនេះ :

- ចំពោះស្រះថ្មី ក្រោយពីជីករួច ត្រូវសម្អាតបាតស្រះ និងជញ្ជាំងស្រះឱ្យបានរលីងស្អាត ដើម្បីកុំឱ្យមានដុំថ្ម អំបែងកែវ មែកឈើ ឫសឈើ ឬដែក ដែលអាចឱ្យមានបញ្ហាដល់ការធ្លុះធ្លាយកម្រាលកៅស៊ូប្លាស្ទិក ក្រោយពេលក្រាល និងបញ្ចូលទឹករួច ។
- ចំពោះស្រះចាស់វិញ ក្រោយពីប្រមូលផលត្រីរួច យើងត្រូវបូមទឹកពង្រីងឱ្យអស់ពីស្រះ រួចត្រូវលាងសម្អាតកម្រាលកៅស៊ូប្លាស្ទិកឱ្យបានស្អាត និងត្រូវពិនិត្យមើលកម្រាលកៅស៊ូប្លាស្ទិក កុំឱ្យមានស្នាមរហែកឬធ្លាយ មុននឹងក្រាលរៀបចំដាក់កូនត្រីចិញ្ចឹមឡើងវិញ។ បន្ទាប់មក ការពារកុំឱ្យមានដុំថ្ម អំបែងកែវ មែកឈើ ឫសឈើ ឬដែក ធ្លាក់ចូលក្នុងបាតស្រះ ដែលអាចធ្វើឱ្យធ្លុះធ្លាយកម្រាលកៅស៊ូប្លាស្ទិក ក្រោយពេលក្រាល និងបញ្ចូលទឹកថ្មីរួច ។
- បន្ទាប់មក ត្រូវរៀបចំភ្លឺស្រះ ដែលមានទទឹងឱ្យបាន០.៥ ម៉ែត្រ កម្ពស់ពី ០.២ ទៅ ០.៣ ម៉ែត្រ និងមានបណ្ដោយជុំវិញស្រះ ដើម្បីការពារកុំឱ្យស្រះលិចទឹក និងត្រីអណ្ដែងវារចេញពីស្រះបាននៅពេលមានភ្លៀងធ្លាក់ ។
- បន្ទាប់ពីបានក្រាលកម្រាលកៅស៊ូប្លាស្ទិករួច យើងគប្បីយកភក់បាតត្រពាំង ឬបឹងមកក្រាលពីលើបាតស្រះឱ្យមានកម្រាស់ប្រហែលពី ០.៥ តឹក រួចបន្ថែមលាមកសត្វស្ងួត ដូចជា លាមកគោ ក្របី ជ្រូក មាន់ ឬទា បាចពង្រាយនៅបាតស្រះ នូវកម្រិតបរិមាណ ០.៥ គីឡូក្រាម ក្នុង ១ ម៉ែត្រការេស្រះ រួចបញ្ចូលទឹកនៅដំណាក់កាលដំបូងនេះជម្រៅពី ០.២-០.៤ ម៉ែត្រ ហើយត្រាំវាទុកក្នុងរយៈពេលពី ៣ ទៅ ៥ថ្ងៃ ដើម្បីឱ្យលាមកសត្វមានប្រតិកម្មរលាយសព្វ កែប្រែគុណភាពទឹកបានល្អ មានពណ៌ត្រួយចេកខ្ចី ដែលធ្វើឱ្យចំណីធម្មជាតិកើតលូតលាស់មានឡើងច្រើន សម្រាប់កូនត្រីស៊ី បន្ទាប់ពីលែងចូលស្រះដំបូង ។
- បន្ទាប់ពីបានបញ្ចូលទឹករយៈពេលពី ៣ ទៅ ៥ថ្ងៃរួច យើងត្រូវបញ្ចូលទឹកបន្ថែមរហូតដល់ជិតពេញដល់មាត់ស្រះដោយប្រើតម្រងស្បៃច្រោះ រួចយកដើមកំប្លោកមកត្រាំបណ្ដែតលើផ្ទៃទឹក ប្រមាណ ១ ភាគ ៣ នៃផ្ទៃទឹកស្រះនោះ សម្រាប់ជាប្រយោជន៍ដល់កូនត្រីចូលជ្រកនៅពេល អាកាសធាតុក្ដៅ ជាពិសេសពេលថ្ងៃត្រង់ ។
- បន្ទាប់ពីបានបញ្ចប់នូវរាល់កិច្ចការសំខាន់ៗខាងលើ នោះយើងគួរគប្បីធ្វើរបង ឬរបាំង ដោយប្រើប្រាស់ស្បៃហាប៉ា និងព្រួលឫស្សីព័ទ្ធជុំវិញនៅពីលើភ្លឺស្រះ សម្រាប់ការពារត្រីអណ្ដែងវារចេញ និងការពារមាន់ទា ជ្រូក ឬគោ ក្របី ចូលជាន់កៅស៊ូប្លាស្ទិករហែក ។
- ម្យ៉ាងទៀត កសិករគួររៀបចំជាទ្រើងដំណាំពីលើស្រះចិញ្ចឹមត្រីប្រមាណពាក់កណ្ដាល នៃផ្ទៃស្រះទាំង

មូល ដើម្បីជាប្រយោជន៍កាត់បន្ថយការរំហួតទឹកស្រះ នៅពេលអាកាសធាតុក្តៅខ្លាំង។ ប៉ុន្តែកុំគប្បីធ្វើទ្រឿងដំណាំគ្របពីលើផ្ទៃស្រះទាំងមូល ព្រោះបាំងពន្លឺថ្ងៃព្រះអាទិត្យ។



ស្រះចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ



## ៧. ប្រភេទចំណី និងការផ្ដល់ចំណី

### គោលបំណង៖

**ដើម្បីទទួលបាននូវ**

- កសិករបានយល់ដឹងច្បាស់ពីប្រភេទចំណីដែលមានក្នុងធម្មជាតិ និងចំណីផ្សំ សម្រាប់ត្រីអណ្ដែង ទៅតាមទំហំ ឬការលូតលាស់របស់កូនត្រីអណ្ដែង និងរបៀបផ្ដល់ចំណី។

### ប្រភេទចំណី៖

នៅក្នុងធម្មជាតិ ត្រីអណ្ដែងក្រោយពេលញាស់រយៈពេលបីថ្ងៃប្រើប្រាស់អស់អាហារបម្រុង នោះវានឹងចាប់ផ្ដើមស្វែងរកចំណីអាហារនៅខាងក្រៅ ។ ចំណីអាហារនៅខាងក្រៅក្នុងធម្មជាតិដែលវាចូលចិត្តស៊ីរួមមាន ចៃទឹកប្រភេទដាប់ញ៉ា ម៉ូយណា កូបប៉េប៉ូដា ជន្លេនក្រហម និងពពួកសត្វល្អិតផ្សេងៗទៀត ដែលរស់នៅបាតស្រះ។ នៅពេលវាធំពេញវ័យ ចូលចិត្តស៊ីចំណីចម្រុះ ហើយស៊ីសាច់ជាអាហារសំខាន់។

ដោយឡែក ចំពោះចំណីផ្សំសម្រាប់ត្រីអណ្ដែង អាចផ្សំពីរុក្ខជាតិ រួមមានច្រើនប្រភេទដូចជា ត្រកួន ពោតស្លឹកដំឡូងជ្វា សណ្ដែកសៀង និងសមាសធាតុផ្សំផ្សេងៗទៀត ដូចជា កន្ទក់ ចុងអង្ករ កាកសំណល់ផ្ទះបាយ លាយផ្សំជាមួយ ម្សៅត្រី ឬត្រីជី ។ល។ រាល់សមាសធាតុចំណីទាំងនេះ យើងអាចលាយផ្សំបញ្ចូលគ្នា រួចចំអិនឱ្យឆ្អិន ទុកឲ្យត្រជាក់មុនពេលដាក់ឱ្យត្រីស៊ី ។

ចំពោះចំណីប្រូតេអ៊ីនពីជាតិសាច់រួមមានដូចជា ពោះវៀនមាន់ ពោះវៀនត្រី កណ្ដៀរ អង្រ្កង ជន្លេន កាកសំណល់ទីសត្តឃាត និងចំណីគ្រាប់ ។ល។

### ការផ្ដល់ចំណី៖



ជន្លេនដី



ជន្លេនទឹកក្រហម



កណ្ដៀរ



កាកសំណល់ត្រីបាល



ចំណីគ្រាប់

ដើម្បីថែរក្សាសុខភាពកូនត្រីឱ្យបានល្អ នោះយើងមិនត្រូវផ្តល់ចំណីឱ្យកូនត្រីស៊ីភ្លាមៗនោះទេ បន្ទាប់ដឹកជញ្ជូន និងលែងចូលស្រះដាក់ចិញ្ចឹម។ យើងអាចផ្តល់ចំណីឱ្យវាស៊ីបាននៅពេលបន្ទាប់ពីលែងចូលស្រះរយៈពេលពី ២-៣ ម៉ោង នូវបរិមាណចំណីតិចតួចបំផុត ។

- នៅថ្ងៃបន្ទាប់យើងអាចចាប់ផ្តើមដាក់ចំណីឱ្យកូនត្រីស៊ីតាមបច្ចេកទេសធម្មតាបាន នូវបរិមាណចំណីពី ៣-៥ ភាគរយ ធៀបទៅនឹងទម្ងន់ដងខ្លួនត្រីសរុបទាំងអស់នៅក្នុងស្រះ ដោយផ្តល់ឱ្យវាស៊ីចំនួនពី ២ ទៅ ៣ដង ក្នុង ១ថ្ងៃ នៅពេលព្រឹកម៉ោង ៨ និងរសៀលម៉ោង ៤ ។
- ត្រូវផ្តល់ចំណីឱ្យត្រីស៊ីបានគ្រប់គ្រាន់ និងទៀងទាត់ពេលវេលា
- គួរបង្ហាត់ត្រីឱ្យចេះស៊ីចំណី ដោយគោះ ឬកូរទឹកធ្វើជាសញ្ញាឱ្យត្រីចំណាំឡើងមករកចំណី។
- គួរដាក់ចំណីឱ្យត្រីស៊ីបានច្រើនកន្លែង ឬច្រើនទីតាំងនៅក្នុងស្រះតែមួយ ដើម្បីឱ្យត្រីបានស៊ីឆ្អែតគ្រប់ៗគ្នា។ គួរចៀសវាងការផ្តល់ចំណីឱ្យត្រីអណ្តែងស៊ីមិនគ្រប់គ្រាន់ នាំឲ្យវាអាចស៊ីគ្នាវា ត្រីកើតជំងឺ និងកូនត្រីមានអត្រារសត្រី។



## ៨. ការតាមដាន និងគ្រប់គ្រងស្រះចិញ្ចឹមត្រី

ក្នុងរយៈពេលចិញ្ចឹមត្រី ចាំបាច់ត្រូវយកចិត្តទុកដាក់តាមដាន និងអនុវត្តនូវរាល់សកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម ដើម្បីធានាឱ្យការចិញ្ចឹមត្រីទទួលបានជោគជ័យ។

- ត្រូវឧស្សាហ៍ត្រួតពិនិត្យមើលគុណភាពទឹកក្នុងស្រះចិញ្ចឹមត្រី ក្នុងករណីទឹកក្នុងស្រះមានពណ៌បៃតងខ្លាំង ឬមានពណ៌ខ្មៅ ឬមានក្លិនស្អុយ ត្រូវផ្លាស់ប្តូរទឹកក្រខ្វក់នេះចេញប្រមាណពី ៣០ ទៅ ៥០ ភាគរយនៃបរិមាណទឹកស្រះសរុប ទៅតាមលទ្ធភាពរបស់កសិករម្នាក់ៗ ដោយបូមយកទឹកក្រខ្វក់នេះពីបាតស្រះចេញ។
- ជាទូទៅក្រោយពីដាក់កូនត្រីចិញ្ចឹមបានរយៈពេល ១ខែ កសិករគួរយកចិត្តទុកដាក់ធ្វើការផ្លាស់ប្តូរទឹកក្រខ្វក់ពីក្នុងស្រះចេញ ដើម្បីឱ្យកូនត្រីមានការលូតលាស់លឿន និងមានសុខភាពល្អ។ ត្រូវប្រាកដថា ទឹកផ្លាស់ប្តូរថ្មីនេះ ជាប្រភពទឹកស្អាតល្អ គ្មានជាតិពុល។
- យកចិត្តទុកដាក់ពិនិត្យសកម្មភាពត្រីស៊ីចំណីរៀងរាល់ថ្ងៃ។ ក្នុងករណីត្រីឈប់ស៊ីចំណី ត្រូវឈប់ផ្តល់ចំណីឱ្យត្រីស៊ី។ ក្នុងករណីពិនិត្យឃើញថា មានកាកសំណល់ចំណីនៅសល់ច្រើនធ្លាក់ក្នុងបាតស្រះ ត្រូវប្រញាប់បឺតយកកាកសំណល់ចំណីនេះចេញ ដើម្បីកុំឱ្យទឹកស្រះឆាប់ក្រខ្វក់ មានក្លិនស្អុយ ត្រីងាយកើតជំងឺ និងខាតបង់ថវិកាទិញចំណីឱ្យត្រីស៊ី។
- ត្រូវការពារកុំឱ្យមានសត្វគោ ក្របី ជ្រូក ឬក្មេងចុះក្នុងស្រះចិញ្ចឹមត្រី ដើម្បីកុំឱ្យកម្រាលកៅស៊ូ ប្លាស្ទិកធ្លុះធ្លាយ រហែក។
- ត្រូវការពារកុំឱ្យដើមកំប្លោកដុះច្រើនក្នុងស្រះលើសពី ១ភាគបី នៃផ្ទៃស្រះទាំងមូល



## ៩. វិធីការពារជំងឺ

ការការពារគឺជាប្រការមួយដ៏ប្រសើរបំផុត ដូចពាក្យចាស់បានពោលថា ការពារវាប្រសើរជាងការព្យាបាល ។ អាស្រ័យហេតុនេះ ដើម្បីការពារជាមុន និងជៀសវាងបានពីបញ្ហាដែលបង្កឱ្យត្រីមានជំងឺ នោះយើងត្រូវធ្វើការមើលថែទាំ និងតាមដានសកម្មភាពត្រីជាប្រចាំ ។ ចំណុចសំខាន់ៗ ជាគន្លឹះមួយចំនួនដែលយើងត្រូវតែអនុវត្តន៍ធ្វើតាមដូចបានបង្ហាញជូនខាងក្រោមនេះ:

- ជាពិសេស នៅពេលផ្តល់ចំណីត្រីម្តងៗ យើងត្រូវជៀសវាងកុំឱ្យចំណីសល់ច្រើននៅបាតស្រះ ដែលបង្កឱ្យទឹកស្រះខូចគុណភាព ទៅជាស្អុយ ហើយបង្កបញ្ហាឱ្យត្រីកើតជំងឺបាន។ ម្យ៉ាងទៀត ក៏យើងត្រូវជៀសវាងផងដែរ ការផ្តល់ចំណីដល់ត្រីស៊ីមិនគ្រប់គ្រាន់ នោះនឹងធ្វើឱ្យខ្វះចំណី ដែលបណ្តាលឱ្យត្រីចឹក ឬស៊ីគ្នាវាបង្ករស្នាមរបួស ដំបៅ ហើយបណ្តាលឱ្យត្រីកើតជំងឺ ។
- ត្រូវតាមដាន និងគ្រប់គ្រងគុណភាពទឹកស្រះជាប្រចាំ ដើម្បីធានាឱ្យបានគុណភាពទឹកល្អជានិច្ច
- ត្រូវតាមដាន និងការពារកុំឱ្យមានកាកសំណល់ទឹកមិនល្អហូរចូលស្រះ
- គួរប្រើទឹកមេបំបែ ឬអ៊ីអឹម ផ្សំពីផ្លែឈើលាយបាចចូលស្រះត្រីនូវកម្រិតបរិមាណ ១០ មីលីលីត្រ ក្នុង ១ ម៉ែត្រគូបទឹក ដើម្បីកែប្រែគុណភាពទឹក និងជួយសម្លាប់ពពួកបាក់តេរីចង្រៃពីក្នុងទឹកស្រះ បន្ថយជាតិស្អុយនៃទឹកក្នុងស្រះចិញ្ចឹមត្រី ។
- ត្រូវត្រួតពិនិត្យផងដែរ គុណភាពកូនត្រីពូជ ( សុខភាពកូនត្រីល្អ គ្មានស្នាមរបួស និងស្គាល់ ប្រភពកូនត្រីនោះពិតប្រាកដ ) មុនពេលលែងចូលស្រះចិញ្ចឹម ។ ត្រូវយកចិត្តទុកដាក់ចំណុចសំខាន់ៗមួយចំនួនផ្សេងទៀត ដូចបានបង្ហាញជូនស្រាប់នៅក្នុងចំណុចមេរៀនទី ៧ ការគ្រប់គ្រង និងមើលថែទាំ ។





*ការរៀបចំដាក់មេអ៊ីអឹម(EM)សម្អាតគុណភាពទឹកស្រះ និងសម្លាប់មេរោគ*

## ១០. ការប្រមូលផល

### ១ ការប្រមូលផលរំលស់

ជាទូទៅ ការចិញ្ចឹមត្រីអណ្ដែងនៅក្នុងស្រះក្រាលកម្រាលកៅស៊ូប្លាស្ទីកនៅក្នុងប្រទេសកម្ពុជាយើង នាពេលបច្ចុប្បន្ននេះកសិករចិញ្ចឹមតែក្នុងរយៈពេលខ្លីពី ២ ទៅ ៤ ខែប៉ុណ្ណោះនឹងត្រូវប្រមូលផលត្រីយកទៅលក់នៅទីផ្សារ និងប្រើប្រាស់សម្រាប់ការហូបចុកក្នុងគ្រួសារ ។

ចំពោះការប្រមូលផលរំលស់ គឺគួរចាប់ផ្ដើមដំណើរការបន្ទាប់ពីបានចិញ្ចឹមរយៈពេលពី ២ ទៅ ៣ខែជាបណ្ដើរៗ ដោយចាប់រំលស់យកចេញនូវរាល់ត្រីណាដែលមានទំហំធំជាងគេ សម្រាប់ហូបក្នុង គ្រួសារ និងលក់ទៅទីផ្សារ ហើយរក្សាទុកចិញ្ចឹមបន្តត្រីដែលមានទំហំតូចៗ ដើម្បីមានការលូតលាស់ ធំធាត់លឿនជាងមុន ខណៈពេលដែលទីធ្លាក្នុងទឹកស្រះចិញ្ចឹមមានលក្ខណៈទូលាយជាងមុន ។

### ២ ការប្រមូលផលសរុប

ចំពោះការប្រមូលផលសរុប យើងគួរចាប់ផ្ដើមដំណើរការចិញ្ចឹមរយៈពេលពី ៣ ទៅ ៤ ខែ ដែលខណៈពេលនោះ ត្រីមានទំហំកាន់តែធំ ជាមធ្យមទម្ងន់ចាប់ពី ២០០ ក្រាម ទៅ ៣០០ ក្រាម ក្នុងមួយក្បាល អាចយកទៅលក់លើទីផ្សារបាន ហើយមានតម្លៃសេដ្ឋកិច្ចខ្ពស់ ។ ការប្រមូលផលសរុបនេះ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ និងកម្រៃច្រើននោះយើងគួរធ្វើឡើងនៅពេល :

- ត្រីចិញ្ចឹមបានរយៈពេលពី ២ ទៅ ៤ ខែ
- ត្រីទម្ងន់ចាប់ពី ១០០ ទៅ ៣០០ ក្រាមក្នុង ១ក្បាល
- ប្រមូលផលត្រីនៅរដូវខ្សត់ត្រី ឬបិទនេសាទ ឬរដូវប្រាំងខ្សត់ត្រីករណីនៅតាមជនបទឆ្ងាយពី ដែននេសាទត្រីធម្មជាតិ។ជាពិសេសនៅពេលដែលតម្លៃត្រីនៅលើទីផ្សារឡើងដល់កម្រិតខ្ពស់ ។




*ការប្រមូលផលត្រីអណ្ដែង*

## ឯកសារយោងៈ


- លោក អ៊ូច ឡង់ ១៩៩៥ បច្ចេកទេសផលិតកូនត្រីពូជ អណ្ដែងកូនកាត់ (សារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ) មហាវិទ្យាល័យវារីវប្បកម្ម នៃសាកលវិទ្យាល័យជលផលញ៉ាត្រាងទីក្រុងញ៉ាត្រាងប្រទេសវៀតណាម ។
- លោក អ៊ូច ឡង់ ២០០៥ មេរៀនទ្រឹស្ដី ស្ដីពី បច្ចេកទេសចិញ្ចឹមត្រីអណ្ដែងកូនកាត់ជាលក្ខណៈគ្រួសារ
- សៀវភៅបច្ចេកទេសស្ដីពីសារប្រយោជន៍នៃសត្វប្លង់តុងសម្រាប់ការបំប៉នកូនត្រី ២០០៩ (FAIEX 1)-JICA
- សៀវភៅផ្សព្វផ្សាយបច្ចេកទេសផលិតកូនត្រីពូជនៅទីជនបទប្រទេសកម្ពុជា ២០១២ (FAIEX 1)-JICA
- **OUCH Lang**, 2008. Technical Information of Hybrid Catfish culture has been using in Cambodia, Phnom Penh, Cambodia.
- **Bach Thi Quynh Mai, 1994. Ky Thuat nuoi ca tre vang lai, Nha Xuat Ban Nong Nghiep, Vietnam**
- **Ngo Trong Lu & Le Dang Khuyen, 2006. Ky Thuat nuoi ca tre, luon, giun dat, Nha Xuat Ban Nong Nghiep, Ha Noi, Vietnam Nguyen Duy Khoat, 2005. Ky Thuat nuoi ca tre lai, ech dong, ba ba, Nha Xuat Ban Nong Nghiep, Ha Noi, Vietnam**
- **A Hatchery Manual for common, chirese and Indian major carps-1985 V.G. Jhingoan and R.S.V. Pullin**




# បច្ចេកទេសចិញ្ចឹមគោជាលក្ខណៈគ្រួសារ

**បន្តពីលេខ ៥២**

រៀបចំដោយ: នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល



*ចំណុចដំណុះរបស់ស្មៅ*

### ៣.៤.ការថែទាំ

មុនពេលដាំត្រូវភ្ជួររាស់ហាលដីឱ្យបាន ២ ទៅ ៣ដងដើម្បីសម្លាប់ស្មៅចង្រៃ។ ត្រូវតាមដានការលូតលាស់របស់ស្មៅ ហើយបោចស្មៅចង្រៃ និងស្រោចទឹកនៅពេលដីស្ងួត។

ករណីដាំគ្រាប់ត្រូវសំអាតស្មៅធម្មជាតិឱ្យបានញឹកញាប់ ព្រោះស្មៅនេះអាចលូតសង្កត់លើស្មៅដាំដែលទើបចាប់ផ្ដើមលូតលាស់ដំបូង។

### ៣.៥. ការប្រមូលផល

ស្មៅចំណីសត្វ អាចកាត់លើកដំបូងក្រោយពីដាំ ៣០ ទៅ ៤៥ ថ្ងៃ និងប្រមូលផលជាបន្តបន្ទាប់រៀងរាល់ ១៥ ថ្ងៃម្ដង។ ប៉ុន្តែនៅរដូវប្រាំងត្រូវពន្យាការច្រូតកាត់យូរជាងនេះ ឬមិនច្រូតកាត់រហូតដល់មានទឹកស្រោចស្រព។

គេអាចច្រូតបានពេញមួយឆ្នាំ ដោយនៅរដូវគ្មានភ្លៀងត្រូវស្រោចទឹកស្មៅ ២ ទៅ ៣ដងក្នុង ១ខែ។

## ៤. ពពួកស្មៅ និងអត្ថប្រយោជន៍ :

### ៤.១. មុលឡាតូ ( Mulato ) :

ជាប្រភេទស្មៅកូនកាត់ ។ នៅប្រទេសកម្ពុជាយើង មិនអាចផលិតគ្រាប់បានទេ ។ ជាស្មៅដែលមានលក្ខណៈធន់ទ្រាំបំផុតនៅរដូវក្ដៅ សមស្របនឹងការកាត់ឱ្យជាចំណីសត្វ ។ វាមានគុណភាពល្អជាងពពួកស្មៅដទៃទៀត ។

ការដាំដុះគឺការបំបែកដើមដាំនៅរដូវវស្សាវាត្រូវការប្រភេទដីដែលមានជីវជាតិសមល្មម ។

### ៤.២. ម៉ារ៉ាន់ឌូ ( Marandu ) :

ជាប្រភេទស្មៅផ្ដល់ជាចំណីសត្វពេញវ័យ ។ ជាស្មៅដែលដុះលូតលាស់ល្អ នៅលើដីដែលមានជីជាតិ ពិសេសលើប្រភេទដីក្រហម វាលូតលាស់ល្អ បំផុត ។ ប៉ុន្តែបើដាំនៅលើដីឥដ្ឋខ្មៅ វាដុះលូតលាស់ល្អបង្គួរ ។ ស្មៅនេះ មានលក្ខណៈធន់ទ្រាំទៅនឹង រដូវប្រាំង ប្រហាក់ប្រហែលនឹងមុលឡាតូដែរ ។

គេអាចដាំវាដោយគ្រាប់ និងដោយបំបែកដើមដាំនៅរដូវវស្សា ។



### ៤.៣. ហ្គាមបា ( Gamba ) :

ជាប្រភេទស្មៅដែលសត្វចូលចិត្តស៊ីជាងប្រភេទស្មៅ



## ៥. ពពួកលេហ្គឹម និងអត្ថប្រយោជន៍ :

### ៥.១. ស្តាយឡូ ១៨៤ (Stylo 184) :

ដំណាំប្រភេទនេះសម្រាប់ផ្តល់ឱ្យសត្វទំពារអៀងទូទៅ និងជាចំណីសំខាន់សម្រាប់ជ្រូក បក្សី និងត្រីផងដែរ ។ គេអាចដាំវាបានស្ទើរនៅលើគ្រប់ប្រភេទដី ។

វាជាចំណី ដែលផ្តល់ជាតិប្រូតេអ៊ីនខ្ពស់ ។ គេអាចផ្តល់ឱ្យសត្វស៊ីទាំងនៅស្រស់ ឬក៏ហាលធ្វើជាម្សៅ។



## ៦. ប្រភេទដំណាំផ្សេងៗទៀត និងអត្ថប្រយោជន៍

### ៦.១. កន្ធំថេត (Leucaena) :

វាស្ថិតនៅក្នុងគ្រួសារតែមួយ គ្រាន់តែមានពូជខុសៗគ្នា ។

ស្លឹកកន្ធំថេតជាប្រភពប្រូតេអ៊ីន ដ៏ប្រសើរបំផុតសម្រាប់គោ។ គេអាចឱ្យគោស៊ីដោយផ្ទាល់ ឬកាត់ឱ្យស៊ីទាំងស្រស់ ឬស្ងួត ។

ជាប្រភេទឈើដែលដុះល្អ ហើយអាចធន់ទ្រាំទៅនឹងការលែងឱ្យស៊ីសត្វដែរ ។ វាអាចដុះលូតលាស់ឡើងវិញបន្ទាប់ពីការកាត់ និងសត្វស៊ីរួច ។



### ៦.២. ដំឡូងមី

ស្លឹកដំឡូងមីផ្តល់នូវប្រូតេអ៊ីន សារធាតុរ៉ែ និងថាមពល ព្រមទាំងជួយកាត់បន្ថយពពួកប៉ារ៉ាស៊ីតខាងក្នុង ។

គេអាចកែច្នៃមើម និងស្លឹកដំឡូងមីសម្រាប់ធ្វើជាចំណីគោបានយ៉ាងល្អ ។ សារជាតិដែលមាននៅក្នុងដំឡូងមី អាចជួយឱ្យសត្វមានការលូតលាស់ល្អ រឹងមាំ និងមានសមត្ថភាពបន្តពូជល្អ ។



### ៦.៣. ដើមពោត

ដើមពោត ជាចំណីផ្តល់ជាតិសរសៃសំខាន់សម្រាប់គោ ជាពិសេសជាចំណីធំសម្រាប់កូនគោ និងមេគោដែលមិនផលិតទឹកដោះ ។



### ៦.៤. សណ្តែកប្រេង

ជាប្រភេទបន្លែ វាចាប់ផ្តើមចេញផ្កានៅអាយុ ៣-៤ខែ ហើយអាចប្រមូលផលផ្លែនៅអាយុ ៥ខែ ។

ស្លឹក និងដើមសណ្តែកមានជាតិប្រូតេអ៊ីនពី ១៦-២០% និងអាចផ្តល់ជាចំណីគោបាន ។

# ជំពូក ៣
# បច្ចេកទេសកែច្នៃចំណីសត្វ

## ១. ការធ្វើផ្អកស្មៅជាចំណីបំប៉នគោក្របី
(Silage Making for Ruminant Feed):

### ១.១. តើផ្អកស្មៅ (Silage) ជាអ្វី?

ផ្អកស្មៅគឺជាស្មៅ ឬរុក្ខជាតិនៅស្រស់ដែលកាត់ជាកំណាត់ល្អិតៗ ហើយរក្សាទុកកន្លែងគ្មានខ្យល់ ដោយដាក់ក្នុងធុងបិទជិត ឬថង់ប្លាស្ទិកបិទជិត។

### ១.២. ផលប្រយោជន៍ផ្អកស្មៅ

- មានសារធាតុបំប៉ន និងជួយឱ្យគោក្របីលូតលាស់លឿន
- អាចរក្សាទុកបានយូរ ជាពិសេសទុកប្រើប្រាស់នៅរដូវខ្វះចំណី

### ១.៣. ការផលិតទឹកមេផ្អកស្មៅ

កសិករអាចផលិតបរិមាណទឹកមេផ្អកស្មៅដោយខ្លួនឯងអាស្រ័យលើតម្រូវការជាក់ស្តែងផលិតផ្អកស្មៅជាចំណីគោ ឬក្របី។ ទឹកមេផ្អកស្មៅនេះអាចរក្សាទុកបានត្រឹមតែ ១អាទិត្យប៉ុណ្ណោះ។

**សមាសធាតុផលិតទឹកមេផ្អកស្មៅ**

- ស្មៅស្រស់ ទម្ងន់ ០,៥គីឡូក្រាម
- ស្ករ ទម្ងន់ ២ក្រាម (០,២ខាំ)
- ទឹកសុទ្ធ ចំណុះ ០,៥លីត្រ
- ដបទឹក មានចំណុះ ១លីត្រ
- ប្រដាប់វាស់កំហាប់ ប៉េហាស់ (Ph)




ស្ករ

**របៀបធ្វើទឹកមេផ្អកស្មៅ**

បុកស្មៅស្រស់ចំនួន ០,៥គីឡូក្រាមឱ្យម៉ត់រួចពូតយកទឹកស្មៅ និងច្រោះឱ្យបានស្អាត (ថ្លាល្អ) ជាមួយតម្រងក្រណាត់ស្អាតដែលមិនមានជាប់សារធាតុផ្សេងៗ (ឧទាហរណ៍៖ ជាតិប្រៃ សាប៊ូ.....)។

**របៀបធ្វើ**

យកទឹកស្មៅដែលច្រោះបានទៅលាយជាមួយស្ករ ០,២ខាំ និងទឹកចំណុះ០,៥លីត្រ បន្ទាប់មកច្រកចូលទៅក្នុងដបកែវស្អាត រួចបិទដបឱ្យជិតមិនឱ្យមានខ្យល់ចេញចូល។






**ការរក្សាទុក និងត្រួតពិនិត្យពីគុណភាពទឹកមេផ្អកស្មៅ**

ទឹកមេផ្អកស្មៅ ត្រូវរក្សាទុកកន្លែងត្រជាក់ល្មម (មិនក្តៅ មិនត្រជាក់) ក្នុងរយៈពេល ៣ថ្ងៃ បន្ទាប់មកត្រូវយក ដបមកពិនិត្យមើលគុណភាព និងវាស់កំហាប់របស់ទឹកមេផ្អកស្មៅ ។ កំហាប់ល្អស្ថិតក្នុងចន្លោះពី ៣ ទៅ ៤,៥ ។



មេផ្អកស្មៅ

**របៀបលាយមេផ្អកស្មៅសម្រាប់ធ្វើផ្អកស្មៅ**

យើងមិនអាចយកទឹកមេផ្អកស្មៅមកប្រើដោយ

ផ្ទាល់ទេ ។ ទឹកមេផ្អកស្មៅ១ដប (បរិមាណលាយខាងលើ) ត្រូវយកទៅលាយទឹកបន្ថែមចំណុះ ១០លីត្រជាមុនសិនទើបអាចលាយធ្វើជាផ្អកស្មៅបាន។

ដំណើរការនៃការធ្វើផ្អកស្មៅ

- ច្រូតស្មៅស្រស់រួចដាក់ហាលឱ្យស្រពាប់
- ហាន់ ឬកាប់ចិញ្ច្រាំឱ្យល្អិតតូចៗ
- ប្រោះ ឬបាញ់ទឹកមេផ្អកស្មៅដែលលាយទឹករួចឱ្យសព្វល្អ ក្នុងបរិមាណ ០,៥លីត្រ ក្នុងស្មៅ ២០ គីឡូក្រាម
- ច្រកស្មៅចូលក្នុងថង់ប្លាស្ទិក ឬធុងមានថង់ប្លាស្ទិកខាងក្នុង បន្តិចម្តងៗដោយជាន់បង្ហាប់ឱ្យណែន
- ចងមាត់ថង់ប្លាស្ទិកដោយមិនឱ្យមានខ្យល់ខាងក្នុង។ បើអាច បឺតខ្យល់ចេញពីថង់ រួចចងកុំឱ្យខ្យល់ចូល
- រក្សាទុកយ៉ាងតិចចំនួន ៣អាទិត្យ ទើបអាចយកទៅផ្តល់ឱ្យគោក្របីស៊ី

**សម្គាល់៖**

ផ្អកស្មៅដែលល្អមានពណ៌លឿងចាស់ និងមានក្លិនឈ្ងុល។ ប្រសិនបើផ្អកស្មៅមានពណ៌ក្រម៉ៅ ប្រផេះ ឬដុះផ្សិត មិនត្រូវផ្តល់ឱ្យគោក្របីស៊ីទេ ។



ច្រូតស្មៅរួចហាលឱ្យស្រពាប់បន្តិច



ការកាត់ចិញ្ច្រាំស្មៅជាកំណាត់ខ្លីៗ



ការហាលសម្ងួតកំណាត់ស្មៅឱ្យស្រពាប់



រៀបចំថង់ប្លាស្ទិកសម្រាប់ជាន់បង្ហាប់ផ្អកស្មៅ



ការប្រោះទឹកមេផ្អកស្មៅ និងស្មៅពេលជាន់បង្ហាប់



ការបង្ហាប់ស្មៅក្នុងថង់ប្លាស្ទិក



ការចងថង់ប្លាស្ទិកឱ្យតឹងកុំឱ្យមានខ្យល់នៅខាងក្នុង



ការរក្សាទុកផ្អកស្មៅ

### ១.៤. ការផ្តល់ឱ្យគោ ឬក្របីស៊ី

កសិករអាចផ្តល់ចំណីផ្អកស្មៅឱ្យគោក្របីស៊ីជារៀងរាល់ថ្ងៃទៅតាមបរិមាណដែលមាន។ គោក្របី ១ក្បាលអាចស៊ីផ្អកស្មៅចំនួន ១គីឡូក្រាម ក្នុង ១ថ្ងៃ ដោយលាយជាមួយចំណីផ្សេងៗទៀត ដូចជា ចំបើង ស្មៅ ជាដើម។

គួរផ្តល់ផ្អកស្មៅដល់សត្វមេកំពុងបំបៅកូន ភ្ជួររាស់ អូសទាញ និងបំប៉នសាច់លក់ជាដើម។

## ២. ការធ្វើចំបើងផ្អាប់ជាចំណីគោ

ស្មៅសម្រាប់គោក្របីស្ទើរគ្រប់កន្លែងមានការខ្វះខាតពិសេសនៅរដូវប្រាំង ដូច្នេះកសិករត្រូវកែច្នៃចំណីដែលមាន ឱ្យមានរសជាតិ និងមានសារជាតិបំប៉នគ្រប់គ្រាន់ ។ ការផ្តល់ចំបើងធម្មតា តែមួយមុខមិនអាចជួយឱ្យគោក្របីទទួលបានសារជាតិគ្រប់គ្រាន់សម្រាប់លូតលាស់ឡើយ ព្រោះវាគ្រាន់តែជួយឱ្យបានត្រឹមបំពេញក្រពះ និងបំបាត់ឃ្លានតែប៉ុណ្ណោះ ។

### ២.១. គុណប្រយោជន៍ចំបើងផ្អាប់

តាមរយៈការពិសោធន៍បង្ហាញថា៖

**ក**.ចំបើងស្ងួតធម្មតាមានប្រូតេអ៊ីន ១% ទៅ ៤% ចំណែកចំបើងផ្អាប់មាន៨% ទៅ ១០% និងបន្ថែមអាម៉ូញ៉ាក់នីត្រូសែន ក្នុងក្រពះគោទៅតាមតម្រូវការ។

**ខ**.បន្ថែមការរំលាយអាហារ (ចំបើងស្ងួត) បានរហូតដល់ ១០% ទៅ ១៥%

**គ**.គោស៊ីចំបើងច្រើនជាងមុន ៣០% ទៅ ៤០%

**ឃ**.គោមានកម្លាំងខ្លាំងសម្រាប់អូសទាញបានល្អ

**ង**.ផ្តល់ចំបើងផ្អាប់ជាមួយចំណីគ្រាប់ ធ្វើឱ្យគោមានការធំធាត់លឿន។



## ២.២. បច្ចេកទេសនៃការកែច្នៃចំបើងផ្អាប់ជាចំណីបំប៉នគោក្របី

ក.ឧបករណ៍ និងសម្ភារសម្រាប់កែច្នៃធ្វើចំបើងផ្អាប់

- ចំបើង ១០០ គ.ក្រ
- ទឹក ១០០ លីត្រ
- ធុងទឹកមានចំពួយផ្កាឈូក
- ជញ្ជីង
- ក្រណាត់តង់ ឬក្រណាត់កៅស៊ូ ឬអាង
- ជីអ៊ុយរ៉េ ២ គ.ក្រ
- កំបោរស (កំបោរថ្ម) ២ គ.ក្រ
- ខ្សែសម្រាប់ចងចំបើង

**ខ. វិធីធ្វើចំបើងផ្អាប់**

- លាយជីអ៊ុយរ៉េ ២គ.ក្រ និងកំបោរថ្ម ២គ.ក្រ ជាមួយទឹក ១០០លីត្រ រួចកូរឱ្យសព្វ
- រៀបចំបើងជាស្រទាប់ក្នុងអាង ឬថង់ បន្ទាប់មកស្រោចទឹកជីអ៊ុយរ៉េពីលើ។ ត្រូវធ្វើដូចគ្នារហូតដល់អស់ចំបើង ១០០គ.ក្រ។
- ចងមាត់ថង់ ឬគ្របមាត់អាងឱ្យជិត ដោយមិនឲ្យទឹកភ្លៀងហូរចូល
- ផ្អាប់ទុករយៈពេល ១០ថ្ងៃទើបយកមកឱ្យគោក្របីស៊ី។ ត្រូវយកឱ្យស៊ីតាមស្រទាប់ចំបើង ហើយពេលយកចេញរួចត្រូវគ្របវិញឱ្យបានត្រឹមត្រូវ។

**សម្គាល់៖**

ប្រសិនបើកចំហរ ធ្វើឱ្យចំបើងហើរក្លិន ព្រមទាំងរក្សាមិនបានយូរ។



តម្រៀប និងជាន់បង្អាប់ចំបើង



ស្រោចទឹកជីអ៊ុយរ៉េលើចំបើង



គ្របកៅស៊ូលើអាងចំបើងដើម្បីផ្អាប់ចំបើង



ផ្អាប់ចំបើងច្រើនដោយធ្វើដំបូលពីលើ

**គ. ចំបើងផ្អាប់ដែលមានលក្ខណៈល្អ**

- មានពណ៌ក្រហមចាស់ បើប្រៀបធៀបជាមួយចំបើងធម្មតា
- មានក្លិនក្រអូបឈ្ងុល
- មានសំណើមប្រមាណ ៤០% ទៅ ៥០%
- មានលក្ខណៈទន់គួរឱ្យចង់ស៊ី
- មិនមានដុះផ្សិត (ប្រសិនបើមានដុះផ្សិត ត្រូវយកទៅហាលថ្ងៃ)

### ឃ. ការផ្តល់ឱ្យសត្វស៊ី

កសិករអាចធ្វើចំបើងផ្ទាប់បន្តបន្ទាប់គ្នា ដើម្បីឱ្យស៊ីបានយូរ ។ បើមានផ្សិតច្រើន ត្រូវយកចំបើងហាលថ្ងៃឱ្យស្ងួតមុននឹងឱ្យសត្វស៊ី ។ ចំបើងផ្ទាប់នៅសល់ពីសត្វស៊ី ត្រូវយកទៅលាយជាមួយនឹងចំបើងថ្មី ព្រោះវាចំណេញពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។

- ត្រូវដាក់ចំបើងផ្ទាប់ឱ្យគោស៊ីបន្តិចម្តងៗ ហើយវា នឹងស៊ីច្រើនឡើងៗ ក្នុងរយៈពេល ៣ ទៅ ៤ ថ្ងៃ យើងអាចឱ្យគោស៊ីឱ្យឆ្អែតជារៀងរាល់ថ្ងៃ ដោយលាយជាមួយចំបើងធម្មតា
- ផ្តល់ចំបើងផ្ទាប់ឱ្យគោស៊ីពេលយប់ច្រើនជាងពេលថ្ងៃ
- ត្រូវដាក់ទឹកឱ្យគោផឹករហូត ក្នុងពេលដាក់ចំបើងផ្ទាប់ឱ្យគោស៊ី



*ការដាក់ចំបើងផ្ទាប់ឱ្យគោស៊ី*

## ៣. ការកែច្នៃស្លឹកដំឡូងមី

### ៣.១. ការហាលឱ្យស្ងួត

ការផ្តល់ស្លឹកដំឡូងមីស្ងួតជាចំណីគោជួយកាត់បន្ថយការចំណាយដើមទុន និងពេលវេលាក្នុងការចិញ្ចឹមគោ ជាពិសេសកសិករអាចប្រើប្រាស់មើមជាចំណីអាហារផ្ទាល់ខ្លួន និងជាចំណីសត្វដ៏ល្អ ។ ការប្រើប្រាស់ស្លឹកដំឡូងមីស្ងួតជាចំណីគោ ជួយធ្វើឱ្យចំណីមានគុណភាពល្អ និងមានប្រូតេអ៊ីនខ្ពស់ ។

**ផលប្រយោជន៍ស្លឹកដំឡូងមី**

- ផ្តល់ប្រូតេអ៊ីន សារធាតុរ៉ែ និងថាមពល
- កាត់បន្ថយពពួកប៉ារ៉ាស៊ីតខាងក្នុង
- ជាចំណីបន្ថែមជំនួយដល់ការរំលាយអាហាររបស់សត្វទំពារអៀង

**ការប្រមូលផលស្លឹកដំឡូងមី**

### ក. ពេលវេលាប្រមូលផលស្លឹកដំឡូងមី

ការប្រមូលផលស្លឹកដំឡូងមីសម្រាប់ធ្វើជាស្លឹកដំឡូងមីស្ងួតក្រោយពេលដាំបាន ៤ខែ និងបន្ទាប់មកទៀតអាចប្រមូលផលបាន ២ខែម្តង រហូតដល់ប្រមូលផលមើម ។

### ខ. របៀបប្រមូលផលស្លឹកដំឡូងមី

ពេលប្រមូលផលលើកទី១ ត្រូវកាត់ដើមកម្ពស់ពីដីប្រមាណ ៣ ទៅ ៦តឹក ហើយជាបន្តបន្ទាប់ត្រូវកាត់ដើមដំឡូងមីរម្កិលឡើងលើពីកន្លែងកាត់មុន ៣សង្ទីម៉ែត្ររាល់ពេលកាត់មួយលើកៗ ។



*របៀបកាត់ដើមដំឡូងមីធ្វើជាចំណីសត្វ*

**ការយកស្លឹក និងមើមដំឡូងមីមកហាលឱ្យស្ងួតដើម្បីធ្វើចំណីគោ**

### ក. របៀបចិញ្ច្រាំចុង និងស្លឹកដំឡូងមី

មែកខាងចុង និងស្លឹកដំឡូងមីដែលកាត់បានត្រូវចិញ្ច្រាំឱ្យល្អិតៗ ឬកំណាត់ខ្លីៗ ។

**ចំណាំ៖**

កសិករមិនត្រូវទុកស្លឹកដំឡូងមី ឡើងពណ៌លឿង

ដែលនាំឱ្យខូចគុណភាពនោះទេ ។



*រូបភាពចញ្ច្រាំស្លឹកដំឡូងមី*

## ខ. របៀបហាលថ្ងៃ

ក្រោយពីចិញ្ច្រាំរួច ត្រូវយកមកហាលលើកម្រាល ដោយពង្រាយស្តើងៗ ឱ្យបានស្ងួតល្អ ។ គួរហាលលើកៅស៊ូតង់ ឬសង្កសី ឬកម្រាលផ្សេងដែលឆាប់ស្ងួត ។



*ចិញ្ច្រាំស្លឹកដំឡូងមីល្អិតៗ រួចហាលឱ្យស្ងួត*

### ការរក្សាទុកស្លឹកដំឡូងមីស្ងួត



*ស្លឹកដំឡូងមីស្ងួតច្រកបាវ រក្សាទុកជាចំណីគោ*

ស្លឹកដំឡូងមីស្ងួតត្រូវច្រកបាវ ឬការ៉ុង រក្សាទុកឱ្យបានល្អ ។ បើស្លឹកដំឡូងមីស្ងួត មិនត្រូវទឹក ឬសើមទេ វាអាចទុកបានរហូតដល់ ៦ខែ ដោយមិនខូចគុណភាព ។

### ការផ្តល់ឱ្យគោស៊ី

កសិករអាចយកស្លឹកដំឡូងមីស្ងួតចំនួន ២០ ទៅ ៣០គីឡូក្រាម លាយជាមួយចំបើងផ្អាប់ ចំនួន ១០០គីឡូក្រាម ឱ្យគោស៊ី ។

គោក្របី ១ក្បាលអាចស៊ីស្លឹកដំឡូងមីស្ងួតចំនួន ២០០ ក្រាម ក្នុង ១ថ្ងៃ ។



### ការផ្អាប់

ការផ្អាប់ ជាវិធីសាស្ត្រមួយដ៏មានប្រសិទ្ធភាព និងងាយស្រួល ដើម្បីរក្សាស្លឹកដំឡូងមីឱ្យនៅមានគុណភាពល្អ សម្រាប់ធ្វើជាចំណីសត្វ ។

## របៀបធ្វើ

បេះស្លឹក និងទងពីដើមដំឡូង រួចយកទៅហាលថ្ងៃបន្តិច (ពី៣-៤ម៉ោង អាស្រ័យលើអាកាសធាតុ) ។ ក្នុងស្លឹកដំឡូង ១០គក្រ លាយជាមួយស្ករត្នោត ០.៥គក្រ និងទឹក ០.៥លីត្រ ។ ច្របល់ចូលគ្នាឱ្យសព្វ ច្រកចូលទៅក្នុងថង់ប្លាស្ទិក រួចច្របាច់យកខ្យល់ចេញឱ្យអស់ពីក្នុងថង់ ។ បន្ទាប់មកចងមាត់ថង់ជាមួយពោះវៀនកៅស៊ូកង់ ដាក់ចូលក្នុងពាង ឬកប់ក្នុងដី ។



ការលាយស្ករត្នោតជាមួយទឹក



ការច្របល់ស្លឹកដំឡូងជាមួយទឹកស្ករ



ការច្រកល្បាយស្លឹកដំឡូងចូលក្នុងថង់



ការចងមាត់ថង់

**ការផ្តល់ឱ្យសត្វស៊ី**

ក្រោយពេលផ្អាប់ពី ២៥-៣០ ថ្ងៃ អាចយកស្លឹកដំឡូងផ្អាប់ឱ្យសត្វស៊ីបាន ។ ក្នុងគោ មួយក្បាលអាចផ្តល់ពី ៣-៥គក្រ ក្នុងមួយថ្ងៃ ។

ស្លឹកដំឡូងផ្អាប់ អាចរក្សាទុកបានរយៈ ពេល ៦ ខែ ។



ការផ្តល់ឱ្យគោស៊ី

### ៣.២. ការធ្វើចំណីផ្សំតាមផ្ទះកសិករ សម្រាប់ជាចំណីបំប៉នគោ

ចំណីផ្សំនេះមានសារជាតិខ្ពស់គ្រប់គ្រាន់ ដូចជាៈ ប្រូតេអ៊ីន វីតាមីន ថាមពល និងសារធាតុរ៉ែ ដែលធ្វើឱ្យគោក្របីលូតលាស់ធំធាត់លឿន ឆាប់រកឈ្មោល មានកម្លាំងមាំមួន ។

កសិករអាចទិញគោស្គមៗ មកចិញ្ចឹមបំប៉នសម្រាប់លក់បន្ត ។

### ៣.៣. ការធ្វើស្លឹក និងចំណិតមើមដំឡូងមីស្ងួត

ដូចគ្នានឹងការផលិតស្លឹកដំឡូងមីស្ងួតដែរ គឺស្លឹក



ការហាលស្លឹកដំឡូងមី



ការហាលចំណិតមើមដំឡូងមី



ការច្របល់ចំណីផ្សំចូលគ្នា

និងចុងដំឡូងមីត្រូវចិញ្ច្រាំឱ្យល្អិត រួចហាលឱ្យស្ងួត ។ ចំណែកមើមដំឡូងត្រូវចិតស្តើងៗរួចហាលឱ្យស្ងួតល្អ ។ ស្លឹក និងមើមដំឡូងស្ងួតច្រកទុកក្នុងបាវ ឬការ៉ុងដើម្បីទុកលាយជាមួយចំណីផ្សំផ្សេងៗទៀតសម្រាប់បំប៉នគោ ។

### ៣.៤. រូបមន្តលាយចំណី

- ចំណិតមើមដំឡូងមីស្ងួត ៧ គីឡូក្រាម
- ស្លឹកដំឡូងមីស្ងួត ៣ គីឡូក្រាម
- កន្ទក់ ១២ គីឡូក្រាម
- ជីអ៊ុយរ៉េ ៣០០ ក្រាម (៣ខាំ)
- អំបិល ២៥០ ក្រាម (២,៥ ខាំ)
- ស្ករ ២៥០ ក្រាម (២,៥ ខាំ)
- ទឹក ២៥០ ក្រាម (២,៥ ខាំ)

**ចំណាំ៖**

ចំពោះស្ករ និងទឹក ត្រូវកូរលាយគ្នាឱ្យសព្វជាមុន រួចប្រោះ ឬលាស់លើចំណីផ្សំ ហើយកូរច្របល់ឱ្យសព្វ។

### ៣.៥. របៀបផ្តល់ចំណី

- មេដើម និងមេកំពុងបៅដោះកូន៖ ឱ្យស៊ី ៣០០ ក្រាម (៣ខាំ) ក្នុង១ក្បាល ក្នុង១ថ្ងៃ
- គោអូសទាញ (ទឹម)និងគោបំប៉នយកសាច់៖ ៥០០ក្រាម (៥ខាំ) ទៅ ១គីឡូក្រាម ក្នុង ១ ក្បាល ក្នុង១ថ្ងៃ







ការច្របល់ចំណីផ្សំចូលគ្នា

នៅមានតទៅលេខ ៥៤

**មាត្រា ៨២.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីនីតិវិធីនៃការបញ្ចូលគ្នារបស់សហគមន៍កសិកម្ម ។

## ផ្នែកទី ១០
## ការបំបែកសហគមន៍កសិកម្ម

**មាត្រា ៨៣.-**

សហគមន៍កសិកម្មមួយអាចធ្វើការបំបែកបាន ក្នុងករណីមានការផ្លាស់ប្តូរដែនសមត្ថកិច្ចរដ្ឋបាល និងភូមិសាស្ត្ររដ្ឋបាល ឬមានការបែងចែករចនាសម្ព័ន្ធមុខរបរនៅក្នុងសហគមន៍កសិកម្ម ដែលចាំបាច់ត្រូវធ្វើការបំបែក ។

ការស្នើសុំបំបែកសហគមន៍កសិកម្មអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការស្នើសុំពីសមាជិកចាប់ពី ១ ភាគ ២ (មួយភាគពីរ) នៃចំនួនសមាជិកសហគមន៍កសិកម្មទាំងអស់ ។

**មាត្រា ៨៤.-**

ក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មត្រូវកោះប្រជុំមហាសន្និបាតក្នុងករណីមានសំណើសុំបំបែកសហគមន៍កសិកម្ម ។ មហាសន្និបាតត្រូវពិនិត្យលើសំណើបំបែកសហគមន៍កសិកម្ម ដោយពិចារណាលើការបែងចែកទ្រព្យសម្បត្តិនិងកាតព្វកិច្ចផ្សេងទៀតរបស់សហគមន៍កសិកម្មដែលត្រូវបំបែក ។

មហាសន្និបាតអាចសម្រេចលើការបំបែកសហគមន៍កសិកម្មបាន លុះត្រាតែមានសំឡេងគាំទ្រយ៉ាងតិច ២ ភាគ ៣ (ពីរភាគបី) នៃសមាជិក ឬប្រតិភូតំណាងដែលមានវត្តមានក្នុងអង្គមហាសន្និបាត ។

**មាត្រា ៨៥.-**

ក្រោយកាលបរិច្ឆេទសម្រេចបំបែកសហគមន៍កសិកម្ម ក្រុមប្រឹក្សាភិបាលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់បំណុលស្តីពីចំណែកនៃបំណុលដែលត្រូវបែងចែក។ ក្នុងករណីម្ចាស់បំណុលមានការជំទាស់ត្រូវជូនព័ត៌មានទៅសហគមន៍កសិកម្មក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹង ។

**មាត្រា ៨៦.-**

សហគមន៍កសិកម្មថ្មីដែលត្រូវបង្កើតឡើងដោយសារការបំបែកសហគមន៍កសិកម្មចាស់ត្រូវចុះបញ្ជីដោយអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ។

សំណើសុំចុះបញ្ជីត្រូវភ្ជាប់ឯកសារបន្ថែមដូចខាងក្រោម ៖

-សហគមន៍កសិកម្មខិតស្នើសុំបំបែកនិងកំណត់ហេតុនៃអង្គប្រជុំមហាសន្និបាតដែលសម្រេចបំបែកសហគមន៍កសិកម្ម ។

២- លិខិតជូនព័ត៌មានដល់ម្ចាស់បំណុលពាក់ព័ន្ធនិងសក្ខីបត្រដែលបញ្ជាក់ថាបំណុលត្រូវបានដោះស្រាយរួចរាល់ ។

**មាត្រា ៨៧.-**

ទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មចាស់ ដែលត្រូវបែងចែកឲ្យសហគមន៍កសិកម្មថ្មីរួមជាមួយបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិនេះ ត្រូវប្រគល់ឲ្យសហគមន៍កសិកម្មថ្មីនៅពេលដែលការចុះបញ្ជីសហគមន៍កសិកម្មថ្មីចូលជាធរមាន ។

**មាត្រា ៨៨.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីនីតិវិធីនៃការបំបែកសហគមន៍កសិកម្ម ។

## ជំពូកទី ៤
## សហភាពសហគមន៍កសិកម្ម

**មាត្រា ៨៩.-**

សហគមន៍កសិកម្មចំនួន ២ (ពីរ) ឡើងទៅដែលមានសកម្មភាពសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា ឬមានទំនាក់ទំនងសេដ្ឋកិច្ចស្ថិតនៅក្នុងប្រព័ន្ធប្រតិបត្តិការមុខរបររួមគ្នាអាចចូលរួមគ្នាដោយស្ម័គ្រចិត្តបង្កើតជា "សហភាពសហគមន៍កសិកម្ម" ដើម្បីប្រមូលផ្តុំកម្លាំងផលិតកម្ម មធ្យោបាយផលិតកម្ម និងពង្រីកសមត្ថភាពនៅក្នុងផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធវិស័យកសិកម្ម ។

នីតិបុគ្គលឯកជនក្រៅពីសហគមន៍កសិកម្មដែលមានមុខរបរចម្បងនៅក្នុងក្របខ័ណ្ឌនៃផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធវិស័យកសិកម្មអាចដាក់ពាក្យសុំចូលជាសមាជិកសហភាពសហគមន៍កសិកម្មបានដោយស្ម័គ្រចិត្ត ។

**មាត្រា ៩០.-**

សហភាពសហគមន៍កសិកម្មត្រូវបង្កើតឡើង ដោយមិនអាស្រ័យដែនភូមិសាស្ត្ររដ្ឋបាល ដែលសហគមន៍កសិកម្មជាសមាជិកតាំងនៅឡើយ ។

សហភាពសហគមន៍កសិកម្មត្រូវបានចាត់ថ្នាក់ជា ៣ (បី) កម្រិត រួមមាន ៖

១- សហភាពសហគមន៍កសិកម្មកម្រិតជាតិដែលធ្វើសកម្មភាពសេដ្ឋកិច្ចក្នុងគ្រប់តំបន់ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

២- សហភាពសហគមន៍កសិកម្មកម្រិតភូមិភាគ ដែលធ្វើសកម្មភាពសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌភូមិភាគណាមួយនៃព្រះរាជាណាចក្រកម្ពុជា ។

៣- សហភាពសហគមន៍កសិកម្មកម្រិតមូលដ្ឋានដែលធ្វើសកម្មភាពសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌនៃភូមិ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្តណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE LE MINISTRE du PALAIS ROYAL

Kol

៣០/៣៧

**មាត្រា ៩១.-**

សហភាពសហគមន៍កសិកម្មត្រូវបង្កើតឡើង តាមរយៈសេចក្តីសម្រេចនៃមហាសន្និបាត របស់សហគមន៍កសិកម្មនីមួយៗ ដែលចូលរួមគ្នាបង្កើតសហភាពសហគមន៍កសិកម្ម ។

ក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្មនីមួយៗត្រូវចាត់តាំងតំណាងមួយរូប ដើម្បីបង្កើតជាគណៈកម្មការរៀបចំឲ្យបំពេញភារកិច្ច ក្នុងការបង្កើតជាសហភាពសហគមន៍កសិកម្មនិងត្រូវអនុវត្តតាមនីតិវិធីដូចគ្នានៃមហាសន្និបាតកំណើតដំបូងក្នុងការបង្កើតសហគមន៍កសិកម្មដែរ ។

**មាត្រា ៩២.-**

សហភាពសហគមន៍កសិកម្មដែលបង្កើតឡើងត្រូវចុះបញ្ជីទទួលស្គាល់នីត្យានុកូលភាពនៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការបញ្ជាក់របស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្តសាមី លើពាក្យស្នើសុំរបស់សហភាពសហគមន៍កសិកម្ម ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីនីតិវិធីនៃការបង្កើតនិងចុះបញ្ជីសហភាពសហគមន៍កសិកម្ម ។

**មាត្រា ៩៣.-**

សហភាពសហគមន៍កសិកម្មបំពេញភារកិច្ចដូចខាងក្រោម ៖

១- ធ្វើសកម្មភាពសេដ្ឋកិច្ចចម្រុះរវាងសមាជិកក្នុងក្របខ័ណ្ឌផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម ។

២- បង្កើតនិងគ្រប់គ្រងមូលនិធិនានាសម្រាប់ទ្រទ្រង់ប្រតិបត្តិការមុខរបររបស់សមាជិក ។

៣- ធ្វើការងារទីផ្សារកសិកម្ម វិភាគតម្រូវការ និងធ្វើការផ្គត់ផ្គង់ជាតុចូលកសិកម្មរួមគ្នា ព្រមទាំងផ្តល់ព័ត៌មានទាំងឡាយដែលបម្រើឲ្យផលិតកម្មនិងប្រតិបត្តិការមុខរបររបស់សមាជិក ។

៤- ទ្រទ្រង់និងលើកកម្ពស់បច្ចេកទេសឬវិជ្ជាជីវៈដល់សមាជិក ។

៥- ទទួលខុសត្រូវនិងការពារផលប្រយោជន៍របស់សមាជិកចំពោះមុខអាជ្ញាធរសាធារណៈ និង ដៃគូឯកជន ។

៦- ជួយសម្រុះសម្រួលវិវាទដែលអាចកើតមានរវាងសមាជិកនិងសមាជិករបស់ខ្លួនឬវិវាទជាមួយតតិយជន ។

៧- ផ្តល់ជំបូន្មាននិងតម្រង់ទិសដល់ប្រតិបត្តិការមុខរបររបស់សមាជិកដើម្បីពង្រីកសកម្មភាពសេដ្ឋកិច្ចរបស់សហភាពសហគមន៍កសិកម្ម ។

៨- បំពេញភារកិច្ចដទៃទៀតដែលបម្រើឲ្យប្រតិបត្តិការមុខរបរនិងផលប្រយោជន៍របស់សមាជិកក្រោមវិសាលភាពនៃច្បាប់នេះ ។

៣១/ ៣៧

**មាត្រា ៩៤.-**

នៅក្នុងមហាសន្និបាតនៃសហភាពសហគមន៍កសិកម្ម ត្រូវមានវត្តមានប្រតិភូតំណាងឲ្យសហគមន៍កសិកម្មដែលជាសមាជិករបស់សហភាពសហគមន៍កសិកម្មនោះ ដោយអនុលោមតាមលក្ខន្តិកៈរបស់សហភាពសហគមន៍កសិកម្មសាមី ។

នីតិបុគ្គលឯកជនក្រៅពីសហគមន៍កសិកម្មដែលជាសមាជិកសហភាពសហគមន៍កសិកម្ម មានសំឡេងឆ្នោតតែ១(មួយ)គត់នៅក្នុងមហាសន្និបាតនៃសហភាពសហគមន៍កសិកម្ម ។

**មាត្រា ៩៥.-**

នីតិវិធីនៃការបង្កើតនិងការប្រព្រឹត្តទៅរបស់សហភាពសហគមន៍កសិកម្មត្រូវអនុវត្តដូចគ្នាចំពោះនីតិវិធីសម្រាប់សហគមន៍កសិកម្មដូចមានចែងក្នុងផ្នែកទី ១ រហូតដល់ផ្នែកទី ១០ ជំពូកទី ៣ នៃច្បាប់នេះ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្ដីពីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងគំរូរបស់សហភាពសហគមន៍កសិកម្ម ។

## ជំពូកទី ៥
## សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

**មាត្រា ៩៦.-**

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ជារចនាសម្ព័ន្ធចាត់តាំងកំពូលរបស់សហគមន៍កសិកម្មដែលត្រូវបង្កើតឡើងតាមរយៈមហាសន្និបាតតំណាងរបស់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មក្រោមការសម្របសម្រួលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ។

បណ្ដាសហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាសមាជិកស្វ័យប្រវត្តិរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

**មាត្រា ៩៧.-**

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាបំពេញភារកិច្ចដូចខាងក្រោម ៖

១- ធ្វើជាតំណាងស្របច្បាប់របស់សហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍របស់សមាជិក ។

២- ផ្ដល់ប្រឹក្សាបច្ចេកទេសដល់សហគមន៍កសិកម្មនិងសម្របសម្រួលទំនាក់ទំនងរវាងសមាជិករបស់ខ្លួនជាមួយស្ថាប័នរាជរដ្ឋាភិបាលឬផ្នែកឯកជន ឬដៃគូអភិវឌ្ឍ ។

៣- ផ្ដល់សេវាបណ្ដុះបណ្ដាលពីបច្ចេកទេសដែលពាក់ព័ន្ធនឹងការងារសហគមន៍កសិកម្ម ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៣២/៣៧

៤- ផ្តល់សេវាសវនកម្មដល់សមាជិកក្នុងគោលបំណងផ្តល់ដំបូន្មាននិងជួយតម្រង់ទិសសម្រាប់អភិវឌ្ឍប្រតិបត្តិការមុខរបរ ។

៥- លើកកម្ពស់ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងបណ្តាសហគមន៍កសិកម្មនៅក្នុងប្រទេសនិងក្រៅប្រទេស ឬជាមួយសម្ព័ន្ធសហគមន៍កសិកម្មក្រៅប្រទេស ឬអង្គការអន្តរជាតិផ្សេងទៀតដែលមានគោលដៅសកម្មភាពដូចគ្នា ។

៦- ជួយដល់សមាជិកក្នុងការដោះស្រាយបញ្ហានិងឧបសគ្គដែលពាក់ព័ន្ធនឹងការងារសហគមន៍កសិកម្ម ។

៧- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ននៅក្នុងការលើកកម្ពស់ផលប្រយោជន៍ពិតរបស់សហគមន៍កសិកម្មស្របតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍសហគមន៍កសិកម្ម ។

៨- បំពេញភារកិច្ចផ្សេងទៀតដែលមានគោលដៅបម្រើផលប្រយោជន៍របស់សមាជិក ។

**មាត្រា ៩៨.-**

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាអាចបង្កើតមូលនិធិដែលមានប្រភពដូចខាងក្រោម ៖

- ប្រាក់សមាជិកភាពរបស់បណ្តាសហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម
- ការជួយឧបត្ថម្ភជាថវិការបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ
- អំណោយជាប្រាក់ឬទ្រព្យសម្បត្តិរបស់សប្បុរសជន
- សំណល់ជាប្រាក់ឬទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មឬសហភាពសហគមន៍កសិកម្មដែលត្រូវរំលាយស្របតាមច្បាប់នេះ
- ចំណូលបានពីការធ្វើសេវាកម្មផ្សេងៗរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ចំណូលឬទ្រព្យសម្បត្តិផ្សេងទៀតរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

**មាត្រា ៩៩.-**

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលដែលមានសមាជិកមិនលើសពី ១៥ (ដប់ប្រាំ) រូប ចេញពីប្រតិភូតំណាងនៃបណ្តាសហគមន៍កសិកម្ម ឬសហភាពសហគមន៍កសិកម្មជាសមាជិកដែលត្រូវសម្រេចដោយមហាសន្និបាតនៃសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

សមាជិកក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាមានអាណត្តិរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

សមាជិកក្រុមប្រឹក្សាភិបាលចាស់អាចឈរឈ្មោះឲ្យគេបោះឆ្នោតឡើងវិញបានដោយអនុលោមតាមលក្ខន្តិកៈរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៣៣/៣៧

**មាត្រា ១០០.-**

ក្រុមប្រឹក្សាភិបាលនៃសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវចាត់តាំងនាយកប្រតិបត្តិ ១ (មួយ) រូបដើម្បីបំពេញតួនាទីជាលេខាធិការនៃក្រុមប្រឹក្សាភិបាល ។

នាយកប្រតិបត្តិនៃសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាមានភារកិច្ចគ្រប់គ្រងរាល់ការងាររបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដោយអនុលោមតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធសហគមន៍កម្ពុជា ។

**មាត្រា ១០១.-**

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវចុះបញ្ជីទទួលស្គាល់នីត្យានុកូលភាពនៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

នីតិវិធីនៃការបង្កើតនិងការប្រព្រឹត្តទៅរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវអនុវត្តដូចគ្នាចំពោះនីតិវិធីសម្រាប់សហគមន៍កសិកម្មដូចមានចែងក្នុងផ្នែកទី១ រហូតដល់ផ្នែកទី ១០ ជំពូកទី ៣ នៃច្បាប់នេះ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងគំរូរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

## ជំពូកទី ៦
## ការតាមដាននិងការដោះស្រាយវិវាទ

**មាត្រា ១០២.-**

អង្គភាពចុះបញ្ជីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចក្នុងការតាមដានលើរាល់ដំណើរការប្រតិបត្តិការមុខរបរនិងការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម សហភាព សហគមន៍កសិកម្ម សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ក្នុងគោលបំណងជំរុញនិងតម្រង់ទិស ក្នុងការអភិវឌ្ឍសហគមន៍កសិកម្ម ។

**មាត្រា ១០៣.-**

វិវាទទាំងឡាយដែលកើតចេញពីសមាជិកនិងសមាជិកសហគមន៍កសិកម្ម រវាងសមាជិកនិងសហគមន៍កសិកម្ម ត្រូវដោះស្រាយដោយមហាសន្និបាតប្រចាំឆ្នាំឬមហាសន្និបាតវិសាមញ្ញរបស់សហគមន៍កសិកម្មសាមីនោះ ។

ក្នុងករណីមហាសន្និបាតមិនអាចដោះស្រាយវិវាទបាន ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមីត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ ។

ករណីក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមីមិនអាចដោះស្រាយវិវាទបានមន្ទីរកសិកម្មរាជធានី ខេត្ត និងគណៈអភិបាលរាជធានីខេត្តសាមី ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។

៣៤/៣៧

ក្នុងករណីវិវាទនៅតែមិនអាចដោះស្រាយបាន នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើអន្តរាគមន៍ សម្របសម្រួលដោះស្រាយ ។

**មាត្រា ១០៤.-**

វិវាទទាំងឡាយដែលកើតរវាងសហគមន៍កសិកម្មនិងសហគមន៍កសិកម្ម មន្ទីរកសិកម្មរាជធានីខេត្ត និងគណៈអភិបាលរាជធានីខេត្តសាមីត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ ។

ក្នុងករណីវិវាទនៅតែមិនអាចដោះស្រាយបាន នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើអន្តរាគមន៍ សម្របសម្រួលដោះស្រាយ ។

**មាត្រា ១០៥.-**

វិវាទទាំងឡាយដែលកើតចេញពីសហគមន៍កសិកម្មជាសមាជិកនិងសហភាពសហគមន៍កសិកម្ម ឬសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ត្រូវដោះស្រាយដោយមហាសន្និបាតប្រចាំឆ្នាំ ឬមហាសន្និបាតវិសាមញ្ញនៃសហភាពសហគមន៍កសិកម្មសាមី ឬសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

ក្នុងករណីមហាសន្និបាតនៅមិនអាចដោះស្រាយបាន គណៈអភិបាលរាជធានី ខេត្តសាមីនិងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ ។

**មាត្រា ១០៦.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយរាល់វិវាទទាំងឡាយដែលមិនអាចបញ្ចប់បានរវាង៖

ក- សមាជិកនិងសមាជិកសហគមន៍កសិកម្ម

ខ- សមាជិកនិងសហគមន៍កសិកម្ម

គ- សហគមន៍កសិកម្មនិងសហគមន៍កសិកម្ម

ឃ- សហគមន៍កសិកម្មជាមួយសហភាពសហគមន៍កសិកម្ម

ង- សហគមន៍កសិកម្មឬសហភាពសហគមន៍កសិកម្មជាមួយសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ឬអង្គភាពក្រៅណាមួយជាមួយសហគមន៍កសិកម្ម ។

ក្នុងករណីភាគីពាក់ព័ន្ធដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិធ្វើបណ្ដឹងទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ឬតុលាការរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងពីសេចក្ដីសម្រេច ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ១០៧.-**

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមានការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូតវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជី និងទោសព្រហ្មទណ្ឌ ។

៣៥/៣៧

ក្នុងករណីវិវាទនៅតែមិនអាចដោះស្រាយបាន នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើអន្តរាគមន៍ សម្របសម្រួលដោះស្រាយ ។

**មាត្រា ១០៤.-**

វិវាទទាំងឡាយដែលកើតរវាងសហគមន៍កសិកម្មនិងសហគមន៍កសិកម្ម មន្ទីរកសិកម្មរាជធានី ខេត្ត និងគណៈអភិបាលរាជធានីខេត្តសាមីត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ ។

ក្នុងករណីវិវាទនៅតែមិនអាចដោះស្រាយបាន នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើអន្តរាគមន៍ សម្របសម្រួលដោះស្រាយ ។

**មាត្រា ១០៥.-**

វិវាទទាំងឡាយដែលកើតចេញពីសហគមន៍កសិកម្មជាសមាជិកនិងសហភាពសហគមន៍កសិកម្ម ឬសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ត្រូវដោះស្រាយដោយមហាសន្និបាតប្រចាំឆ្នាំ ឬមហាសន្និបាតវិសាមញ្ញនៃសហភាពសហគមន៍កសិកម្មសាមី ឬសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

ក្នុងករណីមហាសន្និបាតនៅមិនអាចដោះស្រាយបាន គណៈអភិបាលរាជធានី ខេត្តសាមីនិងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ ។

**មាត្រា ១០៦.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយរាល់វិវាទទាំងឡាយដែលមិនអាចបញ្ចប់បានរវាង៖

ក- សមាជិកនិងសមាជិកសហគមន៍កសិកម្ម

ខ- សមាជិកនិងសហគមន៍កសិកម្ម

គ- សហគមន៍កសិកម្មនិងសហគមន៍កសិកម្ម

ឃ- សហគមន៍កសិកម្មជាមួយសហភាពសហគមន៍កសិកម្ម

ង- សហគមន៍កសិកម្មឬសហភាពសហគមន៍កសិកម្មជាមួយសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ឬអង្គភាពក្រៅណាមួយជាមួយសហគមន៍កសិកម្ម ។

ក្នុងករណីភាគីពាក់ព័ន្ធដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទមានសិទ្ធិធ្វើបណ្តឹងទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ឬតុលាការរយៈពេល ៣០ (សាមសិប) ថ្ងៃ គិត ចាប់ពីថ្ងៃបានទទួលដំណឹងពីសេចក្តីសម្រេច ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ១០៧.-**

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមានការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូតវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជី និងទោសព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៣៥/៣៧

# ឧបសម្ព័ន្ធនៃច្បាប់ស្ដីពីសហគមន៍កសិកម្ម
## សទ្ទានុក្រម

១ – **ការជម្រះបញ្ជីសហគមន៍កសិកម្ម** សំដៅដល់ដំណើរការជម្រះទ្រព្យសម្បត្តិទាំងអស់របស់សហគមន៍កសិកម្មដែលត្រូវបានរំលាយដើម្បីសងទៅម្ចាស់បំណុលរបស់សហគមន៍កសិកម្ម សងដើមទុនរបស់សមាជិកសហគមន៍កសិកម្ម និងបែងចែងទ្រព្យសម្បត្តិដែលនៅសល់អនុលោមតាមច្បាប់ឬលក្ខន្តិកៈរបស់សហគមន៍កសិកម្ម ។

២ – **កសិពាណិជ្ជកម្ម** សំដៅដល់សកម្មភាពប្រតិបត្តិការមុខរបរដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ដូចជាការផ្គត់ផ្គង់សម្ភារៈកសិកម្ម(ពូជ ជី ថ្នាំកសិកម្ម) ការផ្គត់ផ្គង់គ្រឿងយន្តនិងឧបករណ៍កសិកម្មការលក់ដុំ ការលក់រាយ ការបង្កើតទីផ្សារ និងការជញ្ជូនលក់កសិផល ។ល។

៣ – **កសិឧស្សាហកម្ម** សំដៅដល់គ្រប់សកម្មភាពមុននិងក្រោយពេលប្រមូលផលកសិផលដូចជាការធ្វើចំណាត់ថ្នាក់ ការវេចខ្ចប់ ការដឹកជញ្ជូន ការទុកដាក់ ការកែច្នៃវត្ថុធាតុដើមនៃផលិតផលកសិកម្មទាំងអស់ដើម្បីបង្កើនគុណភាពនិងតម្លៃសម្រាប់បម្រើទីផ្សារក្នុងប្រទេសនិងការនាំចេញ ។

៤ – **តារាងតុល្យការសហគមន៍កសិកម្ម** សំដៅដល់តារាងរបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញពីស្ថានភាពនៃទ្រព្យសកម្មនិងទ្រព្យអកម្មរបស់សហគមន៍កសិកម្ម ។

៥ – **ប្រាក់ចំណេញសរុបសហគមន៍កសិកម្ម** សំដៅដល់លទ្ធផលសេដ្ឋកិច្ចសរុបនៅចុងការិយបរិច្ឆេទដែលបានមកពីការធ្វើប្រតិបត្តិការមុខរបររបស់សហគមន៍កសិកម្ម ។

៦ – **ប្រាក់ចំណេញសុទ្ធសហគមន៍កសិកម្ម** សំដៅដល់ប្រាក់នៅសល់នៅចុងការិយបរិច្ឆេទដែលបានមកពីប្រាក់ចំណេញសរុប ដកមូលនិធិបម្រុង មូលនិធិបណ្ដុះបណ្ដាល និងមូលនិធិផ្សេងទៀតដែលត្រូវបង្កើតឡើងដោយសហគមន៍កសិកម្ម ។

៧ – **ប្រព័ន្ធផលិតកម្មកសិកម្ម** សំដៅការងារផលិតកម្មកសិកម្មដែលរួមមានការដាំដំណាំគ្រប់ប្រភេទ ការចិញ្ចឹមសត្វ វារីវប្បកម្ម រុក្ខវប្បកម្ម និងវប្បកម្មផ្សេងទៀតដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃវិស័យកសិកម្ម ។

៨ – **ភាគហ៊ុនសហគមន៍កសិកម្ម** សំដៅដល់ទុនមួយផ្នែកនៃដើមទុនរបស់សហគមន៍កសិកម្មដែលសមាជិកសហគមន៍កសិកម្មម្នាក់ៗបានទិញនិងបង់នៅក្នុងសហគមន៍កសិកម្ម សម្រាប់ធ្វើប្រតិបត្តិការមុខរបររួមគ្នា ។

៩ – **សហគ្រាសសេដ្ឋកិច្ចកសិកម្ម** សំដៅដល់សហគ្រាសកសិកម្មដែលធ្វើសកម្មភាពសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌនៃប្រព័ន្ធផលិតកម្មកសិកម្ម កសិពាណិជ្ជកម្ម កសិឧស្សាហកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

- i -

១០- **សេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម** សំដៅដល់សេវាកម្មនានាដែលគាំទ្រដល់ការលើកកម្ពស់ផលិតកម្មកសិកម្ម ដូចជាសេវាកម្មឥណទាន សន្សំ បញ្ញើ ដឹកជញ្ជូនកសិផល ផ្សព្វផ្សាយឬបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម សេវាកម្មផ្គត់ផ្គង់សម្ភារៈ កសិកម្ម សេវារៀបចំដី សេវាកម្មផ្គត់ផ្គង់ប្រេងឥន្ធនៈ សេវាកម្មកម្ចាត់សមាសភាពចង្រៃ និងសេវាកម្មផ្សេងទៀតដែលអនុវត្តនៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម ។

១១- **សវនកម្មសហគមន៍កសិកម្ម** សំដៅដល់ការត្រួតពិនិត្យនិងការណែនាំសហគមន៍កសិកម្ម ផ្តោតលើសកម្មភាពសេដ្ឋកិច្ច បញ្ជីគណនេយ្យ និងសកម្មភាពជំនួញរបស់សហគមន៍កសិកម្ម

១២- **អង្គភាពចុះបញ្ជី** សំដៅដល់មន្ទីរកសិកម្មរាជធានី ខេត្ត និងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មដែលមានភារកិច្ចចុះបញ្ជីសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្មនិង សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

**គោលការណ៍គ្រឹះសហគមន៍កសិកម្ម ៖**

**គោលការណ៍ទី១ ការចូលរួមដោយស្ម័គ្រចិត្តនិងបើកចំហសមាជិកភាព**

សហគមន៍កសិកម្មត្រូវបានបង្កើតឡើងតាមលក្ខណៈស្ម័គ្រចិត្ត បើកចំហចំពោះមនុស្សទាំងអស់ដើម្បីប្រើប្រាស់សេវាកម្មនិងសុខចិត្តទទួលខុសត្រូវចំពោះសមាជិកភាពដោយមិនរើសអើងចំពោះយេនឌ័រ សង្គម ពូជសាសន៍ នយោបាយ និងសាសនាឡើយ ។

**គោលការណ៍ទី២ ការគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យដោយសមាជិក**

សហគមន៍កសិកម្មត្រូវដឹកនាំនិងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យដោយសមាជិកដែលបានចូលរួមក្នុងការកំណត់គោលនយោបាយនិងក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា។ បុរសនិងនារីដែលត្រូវបានបោះឆ្នោតជាប់ក្នុងរចនាសម្ព័ន្ធដឹកនាំត្រូវតែមានគណនេយ្យភាពចំពោះសមាជិក ។ សមាជិករបស់សហគមន៍កសិកម្មមានសិទ្ធិបោះឆ្នោត ស្មើភាពគ្នា គឺសមាជិកម្នាក់មានសំឡេងឆ្នោតមួយ ។

**គោលការណ៍ទី៣ ការចូលរួមផ្នែកសេដ្ឋកិច្ចរបស់សមាជិក**

សមាជិកទាំងអស់ត្រូវចូលរួមដើមទុនដល់សហគមន៍ដោយលក្ខណៈសមភាពនិងត្រូវ គ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ ។ មួយចំណែកនៃដើមទុនរបស់សមាជិកត្រូវក្លាយជាទ្រព្យសម្បត្តិរួមរបស់សហគមន៍កសិកម្ម។ សមាជិកសហគមន៍កសិកម្មត្រូវបែងចែកប្រាក់ចំណេញខ្លះឬទាំងអស់ដើម្បី (ក) អភិវឌ្ឍសហគមន៍កសិកម្មនិងត្រូវបង្កើតមូលនិធិបម្រុង (ខ) បែងចែកដល់សមាជិកសហគមន៍កសិកម្មដោយផ្អែកតាមសមាមាត្រសកម្មភាព ធ្វើជំនួញរបស់គេជាមួយសហគមន៍កសិកម្មនិង (គ) គាំទ្រសកម្មភាពផ្សេងៗទៀតដែលត្រូវសម្រេចដោយសមាជិកសហគមន៍កសិកម្ម ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- ii -

## គោលការណ៍ទី៤ ស្វ័យភាពនិងឯករាជ្យ

សហគមន៍កសិកម្មត្រូវមានលក្ខណៈស្វយ័ត ជួយខ្លួនឯង និងគ្រប់គ្រងដោយសមាជិក ។ ប្រសិនបើសហគមន៍កសិកម្មមានកិច្ចព្រមព្រៀងឬកិច្ចសន្យាណាមួយជាមួយស្ថាប័នពាក់ព័ន្ធរួមមានរាជរដ្ឋាភិបាល ឬការទទួលបានហិរញ្ញវត្ថុពីប្រភពខាងក្រៅ សហគមន៍កសិកម្មអាចធ្វើបាននៅក្នុងលក្ខខណ្ឌដែលអាចធានាបាននូវការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យដោយសមាជិក និងរក្សាបាននូវស្វ័យភាពរបស់ខ្លួន ។

## គោលការណ៍ទី៥ ការអប់រំ ការបណ្ដុះបណ្ដាល និងការផ្ដល់ព័ត៌មាន

សហគមន៍កសិកម្មត្រូវផ្ដល់ការអប់រំនិងការបណ្ដុះបណ្ដាលទៅដល់សមាជិករបស់ខ្លួនដល់អ្នកតំណាងដែលបានជាប់ឆ្នោតនិងបុគ្គលិក ដើម្បីធ្វើឲ្យគេអាចចូលរួមយ៉ាងសកម្មនិងមានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសហគមន៍កសិកម្មរបស់ខ្លួន និងធ្វើឲ្យពួកគេអាចផ្សព្វផ្សាយជាសាធារណៈ ជាពិសេសដល់ក្រុមយុវជននិងអ្នកមានគំនិតជាអ្នកដឹកនាំអំពីកម្មវត្ថុនិងផលប្រយោជន៍របស់សហគមន៍កសិកម្ម។

## គោលការណ៍ទី៦ ការធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍កសិកម្មផ្សេងទៀត

សហគមន៍កសិកម្មត្រូវបម្រើសមាជិករបស់ខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់និងត្រូវពង្រឹងតាមរយៈការធ្វើការរួមគ្នាជារចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ។

## គោលការណ៍ទី៧ ការគិតគូរដល់សហគមន៍

សហគមន៍កសិកម្មត្រូវគិតគូរដល់ប្រយោជន៍រួម ធ្វើយ៉ាងណាឲ្យមានការអភិវឌ្ឍសហគមន៍ប្រកបដោយចីរភាពស្របតាមគោលបំណងនិងទិសដៅរបស់សមាជិកសហគមន៍កសិកម្ម ។

# សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Jean-Francois Cautain ឯកអគ្គរដ្ឋទូតសហគមអឺរ៉ុប ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា



កិច្ចសវនាការជាមួយឯកឧត្តមឯកអគ្គរដ្ឋទូតនូវែលហ្សេឡង់ Reuben Levermore



ជំជួបសវនាការជាមួយលោក Yium Tavarolit នាយកប្រតិបត្តិនៃសមាគមកៅស៊ូអន្តរជាតិ




ជំជួបសវនាការជាមួយឯកឧត្តម PROCESO“ PROCY ”J. ALCALA រដ្ឋមន្ត្រីក្រសួងកសិកម្ម នៃសាធារណរដ្ឋហ្វីលីពីន និងសហការី



សេចក្តីថ្លែងការក្នុងឱកាសសិក្ខាសាលាថ្នាក់តំបន់ស្តីពីការប្រែក្លាយតំបន់ជនបទចត្តាឡីស័យជាយុទ្ធសាស្ត្រសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក នៅខេត្តសៀមរាប



ជំនួបសវនាការជាមួយឯកឧត្តម Qin Ruixiang អនុប្រធានគណៈកម្មការអចិន្ត្រៃយ៍សភាប្រជាជនខេត្តក្វាងស៊ីនៃសាធារណរដ្ឋប្រជាមានិតចិន



ពិធីជួបសំណេះសំណាលជាមួយមន្ត្រីរាជការ នៅខេត្តបន្ទាយមានជ័យ



ការជួបសំណេះសំណាលជាមួយប្រជាកសិករបង្កបង្កើនផលស្រូវ នៅខេត្តកណ្តាល



ការពិនិត្យស្ថានភាពការផាររចិញ្ចឹមសត្វរបស់ប្រជាកសិករ នៅខេត្តព្រៃវែង



ការជួបសំណេះសំណាលជាប្រជាកសិករដាំដំណាំបន្លែនៅខេត្តព្រៃវែង





ឯកឧត្តម **ទី សុគន្ធ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជួបសវនាកា ជាមួយប្រតិភូអង្គការ Action Aid




ឯកឧត្តម **ម៉ម អំណាត់** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងកិច្ចប្រជុំគណៈកម្មាការដឹកនាំគម្រោងថ្នាក់ជាតិកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា



ឯកឧត្តម **ម៉ម អំណាត់** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសចុះចែកស្រូវពូជ នៅខេត្តព្រៃវែង







ឯកឧត្តម **សាន វណ្ណទី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុង *Regional Forum Standard and Roadmaps for their Implementation*





ឯកឧត្តម **តង់ ចាន់** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាព ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និងលើកទិសដៅឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានកសិកម្ម





ឯកឧត្តម **អ៊ាង សុផល្លែត** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការី បានទទួលជួបសវនាការជាមួយនឹងលោក Carlos Manuel Rodriguez អនុប្រធានផ្នែកគោលនយោបាយអភិរក្សនៃអង្គការអភិរក្សអន្តរជាតិ និងសហការី





លោកជំទាវ **ម៉ុម ថានី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជួបសំណេះសំណាលជាមួយមន្ត្រីរាជការ នៅខេត្តកណ្តាល



សិល្បកំណាព្យ

# ដំបូន្មានមុនពេលប្រើថ្នាំពុល

## គពីទស្សនាវដ្តីសមិទ្ធផលកសិកម្មប្រចាំឆ្នាំ២០១៤

មុននឹងប្រើថ្នាំ ត្រូវមើលដំណាំ ខូចកម្រិតណា
កុំជឿតាមចិន គាត់ចេះតែថា មិនស្គាល់បញ្ហា
ថាតាមផ្លូវកាត់។

មុននឹងប្រើថ្នាំ ត្រូវកត់ចំណាំ ពីស្ថានភាពសត្វ
ចង្រៃប្រយោជន៍ ទើបបាញ់កម្ចាត់ ដើម្បីទប់ស្កាត់
ការវាយប្រហារ។

មុននឹងប្រើថ្នាំ អ្នកត្រូវចងចាំ អានស្លាកសញ្ញា
តើថ្នាំមួយនេះ សម្លាប់សត្វណា ទើបចាយថវិកា
បានល្អប្រពៃ។

មុននឹងប្រើថ្នាំ គិតពីភាពស៊ាំ នៃសត្វចង្រៃ
បើចេះតែប្រើ ឱ្យតែឈ្នះដៃ ខាតប្រាក់កម្រៃ
ល្ងង់គ្មានចំណេះ។

មុននឹងប្រើថ្នាំ ត្រូវស្ដាំបណ្ដាំ អ្នកបច្ចេកទេស
ការពារសុវត្ថិភាព កុំប្រហេសធ្វេស បើមិនដូច្នេះ
ក្ស័យទាំងអាត្មា។

មុននឹងប្រើថ្នាំ គិតពីផលកម្ម តាមធម៌សាសនា
សម្លាប់មនុស្ស គ្មានធម៌មេត្តា ត្រូវពិចារណា
ឱ្យគ្រប់ជ្រុងជ្រោយ។



និពន្ធដោយៈ លោក [illegible] ឆាយ
ប្រធាននាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម



